# ធរណីមាត្រ

GEOMETRY -- GRADE 12

ថ្នាក់ទី ១២ • GRADE 12

## ទ្រឹស្តីសង្ខេប • វិធីសាស្ត្រគណនា • លំហាត់ និង ដំណោះស្រាយ

ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) និងប្រឡងសិស្សពូកែ

### រូបមន្តគ្រឹះនៃធរណីមាត្រក្នុងលំហ • CORE SOLID GEOMETRY FORMULAS

$$\vec{u}\cdot\vec{v} = xx' + yy' + zz' = |\vec{u}||\vec{v}|\cos\theta$$

$$S_{\text{ប្រលេឡូក្រាម}} = |\vec{u}\times\vec{v}|, \quad S_{\triangle} = \frac{1}{2}|\vec{u}\times\vec{v}|$$

$$\vec{u}\times\vec{v} = (u_y v_z - u_z v_y)\vec{i} - (u_x v_z - u_z v_x)\vec{j} + (u_x v_y - u_y v_x)\vec{k}$$

$$V_{\text{ប្រលេពីប៉ែត}} = |\vec{u}\cdot(\vec{v}\times\vec{w})|, \quad V_{\text{តេត្រាអ៊ែត}} = \frac{1}{6}|\vec{u}\cdot(\vec{v}\times\vec{w})|$$

$$(P): a(x-x_0) + b(y-y_0) + c(z-z_0) = 0$$

$$d(M_0,(P)) = \frac{|ax_0 + by_0 + cz_0 + d|}{\sqrt{a^2+b^2+c^2}}$$



អ្នករៀបរៀង ៖ លោកគ្រូ ខែម ពុទ្ធី

បោះពុម្ពលើកទី១ ឆ្នាំ ២០២៦

# គណៈកម្មការរៀបរៀង និងត្រួតពិនិត្យ


| | |
|---|---|
| គណៈកម្មការរៀបរៀង | លោកគ្រូ ខែម ពុទ្ធី |
| | លោកគ្រូ ឡាយ ចាន់ហេន |
| ត្រួតពិនិត្យខ្លឹមសារ | លោកគ្រូ ឡាយ ចាន់ហេន |
| រៀបចំខ្លឹមសារ | លោកគ្រូ ខែម ពុទ្ធី |
| រចនាគម្រប និងទំព័រ | លោកគ្រូ ខែម ពុទ្ធី |
| រូបភាព និងតារាង | លោកគ្រូ ខែម ពុទ្ធី |
| កែសម្រួលអក្ខរាវិរុទ្ធ | លោកគ្រូ ខែម ពុទ្ធី |
| គណៈកម្មការពិនិត្យចុងក្រោយ | លោកគ្រូ ខែម ពុទ្ធី |
| | លោកគ្រូ ឡាយ ចាន់ហេន |


សៀវភៅនេះត្រូវបានរៀបចំឡើងយ៉ាងសម្រិតសម្រាំង សម្រាប់សិស្សានុសិស្សថ្នាក់ទី១២ ក្នុងការស្វ័យសិក្សា និងត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) ព្រមទាំងការប្រឡងសិស្សពូកែទូទាំងប្រទេស។


ព័ត៌មានសៀវភៅ

កំណែសាកល្បង © ២០២៦

**ធរណីមាត្រ ថ្នាក់ទី១២**

**GEOMETRY - GRADE 12**

រៀបរៀងដោយ **លោកគ្រូ ខែម ពុទ្ធី**

សម្រាប់បោះពុម្ពផ្សាយៈ **បណ្ណាគារអង្គរ**

# ប្រសិទ្ធពរ និងការឧទ្ទិស

សៀវភៅ «**ធរណីមាត្រ ថ្នាក់ទី១២**» មួយក្បាលនេះ
ត្រូវបានបង្កើតឡើង និងឧទ្ទិសជូនយ៉ាងស្មោះស្ម័គ្រចំពោះ ៖

## មាតាបិតាជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ដែលបានលះបង់កម្លាំងកាយចិត្ត ឧបត្ថម្ភគាំទ្រ និងផ្តល់ក្តីស្រឡាញ់ឥតព្រំដែន
ក្នុងការផ្តល់ឱកាសឱ្យកូនបានក្រេបជញ្ជក់ចំណេះវិជ្ជា និងរីកចម្រើនរហូតមកដល់បច្ចុប្បន្ន។

## លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យគ្រប់ជំនាន់

ដែលជាអ្នកផ្តល់ពន្លឺប្រាជ្ញា ណែនាំមាគ៌ាដ៏ត្រចះត្រចង់
និងបណ្តុះបណ្តាលសិស្សានុសិស្សឱ្យក្លាយជាទំពាំងស្នងឫស្សីដ៏មានសមត្ថភាព។

## ប្អូនៗសិស្សានុសិស្សថ្នាក់ទី១២ ទាំងអស់

ដែលកំពុងខិតខំប្រឹងប្រែងរៀនសូត្រ ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
និងការប្រឡងសិស្សពូកែទូទាំងប្រទេស សូមឱ្យទទួលបានជោគជ័យគ្រប់ៗគ្នា!

ដោយសេចក្តីគោរព និងស្រឡាញ់ដ៏ជ្រាលជ្រៅ

**លោកគ្រូ ខែម ពុទ្ធី**

# អារម្ភកថា

គណិតវិទ្យា គឺជាមូលដ្ឋានគ្រឹះដ៏មានសារៈសំខាន់បំផុត ក្នុងការអភិវឌ្ឍការគិតបែបស៊ីជម្រៅ ការវិភាគសមហេតុផល និងការដោះស្រាយបញ្ហាក្នុងវិទ្យាសាស្ត្រ បច្ចេកវិទ្យា សេដ្ឋកិច្ច និងជីវភាពរស់នៅជាក់ស្តែង។ ក្នុងចំណោមប្រធានបទគណិតវិទ្យាថ្នាក់ទី១២ «**ធរណីមាត្រក្នុងលំហ**» (Solid Geometry) ឬ «**វ៉ិចទ័រក្នុងលំហ**» គឺជាផ្នែកមួយដ៏មានអត្ថន័យ និងជាស្ពានតភ្ជាប់យ៉ាងរឹងមាំរវាងពិជគណិត និងធរណីមាត្រ។ ការសិក្សាអំពីវ៉ិចទ័រក្នុងលំហ មិនត្រឹមតែបណ្តុះនូវការស្រមើស្រមៃក្នុងលំហវិមាត្របី និងការគិតបែបតក្កវិជ្ជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាមូលដ្ឋានគ្រឹះមិនអាចខ្វះបានសម្រាប់រូបវិទ្យា វិស្វកម្ម ស្ថាបត្យកម្ម បច្ចេកវិទ្យាកុំព្យូទ័រ និងការស្រាវជ្រាវវិទ្យាសាស្ត្រទំនើប។ លើសពីនេះ ប្រធានបទធរណីមាត្រក្នុងលំហតែងតែមានវត្តមានជាប្រចាំនៅក្នុងវិញ្ញាសាប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) និងការប្រឡងសិស្សពូកែទូទាំងប្រទេស។

សៀវភៅ «**ធរណីមាត្រ ថ្នាក់ទី១២**» មួយក្បាលនេះ ត្រូវបានរៀបចំឡើងយ៉ាងហ្មត់ចត់ ស្របតាមកម្មវិធីសិក្សាផ្លូវការនៃក្រសួងអប់រំ យុវជន និងកីឡា ដោយបែងចែកខ្លឹមសារជា ៣ មេរៀនចម្បងៗ ៖

- **មេរៀនទី១ ៖ វ៉ិចទ័រក្នុងលំហ** — សិក្សាលម្អិតអំពីប្រព័ន្ធកូអរដោនេក្នុងលំហ, លក្ខណៈនៃកូអរដោនេ, ទិសដៅកូស៊ីនុសនៃវ៉ិចទ័រ, ផលគុណស្កាលែនៃពីរវ៉ិចទ័រ និងលក្ខណៈរបស់វា, ផលគុណស្កាលែក្នុងគោលអរតូណរម៉ាល់, កូអរដោនេចំណុចកណ្តាល ព្រមទាំងលំហាត់អនុវត្តន៍គ្រឹះជាច្រើន។
- **មេរៀនទី២ ៖ ផលគុណនៃពីរវ៉ិចទ័រក្នុងលំហ** — ផ្តោតលើនិយមន័យផលគុណនៃពីរវ៉ិចទ័រ (ផលគុណវ៉ិចទ័រ), លក្ខណៈធរណីមាត្រ និងពិជគណិត, ការគណនាផ្ទៃក្រឡាប្រលេឡូក្រាម និងផ្ទៃក្រឡាត្រីកោណ, ផលគុណចម្រុះនៃបីវ៉ិចទ័រ (Mixed Product) និងការគណនាមាឌប្រលេពីប៉ែត និងមាឌតេត្រាអែត (ចតុមុខ)។
- **មេរៀនទី៣ ៖ អនុវត្តន៍នៃផលគុណវ៉ិចទ័រ** — អនុវត្តផលគុណវ៉ិចទ័រក្នុងការរកសមីការបន្ទាត់ក្នុងលំហ (សមីការប៉ារ៉ាម៉ែត្រ និងសមីការឆ្លុះ), សមីការប្លង់, សមីការស្វ៊ែ, ចម្ងាយរវាងពីរចំណុច, ចម្ងាយពីចំណុចមួយទៅបន្ទាត់, ចម្ងាយពីចំណុចមួយទៅប្លង់, ចម្ងាយរវាងបន្ទាត់ពីរស្របគ្នា និងបន្ទាត់ពីរខ្វែងគ្នា, មុំរវាងបន្ទាត់និងប្លង់, មុំរវាងប្លង់ពីរ ព្រមទាំងកម្រងលំហាត់វិញ្ញាសាប្រឡងបាក់ឌុបជាក់ស្តែងរាប់សិបឆ្នាំ។

សៀវភៅនេះត្រូវបានរចនាឡើងយ៉ាងយកចិត្តទុកដាក់តាមក្បួនខ្នាតបោះពុម្ពទំនើប មានគំនូសក្រាហ្វិក TikZ 3D ច្បាស់ត្រឹមត្រូវ ប្លង់ទំព័រស្អាតបាត និងមានក្រឡាក្នុងការអនុវត្តដោះស្រាយ (Workspace Grid) យ៉ាងងាយស្រួលដល់ការសិក្សាស្រាវជ្រាវ។

ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា សៀវភៅនេះនឹងក្លាយជាមគ្គុទេសក៍ និងជាកម្រងឯកសារជំនួយស្មារតីដ៏មានតម្លៃបំផុតសម្រាប់លោកគ្រូ អ្នកគ្រូ និងប្អូនៗសិស្សានុសិស្សក្នុងការបង្រៀននិងរៀន។ ទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងណាក្តី ក៏សៀវភៅនេះប្រាកដជាមិនអាចជៀសផុតពីកំហុសអចេតនាណាមួយឡើយ។ ខ្ញុំបាទរង់ចាំទទួលនូវរាល់មតិរិះគន់ស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ និងមិត្តអ្នកអានដោយក្តីរីករាយជានិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២៦

**លោកគ្រូ ខែម ពុទ្ធី**

# សេចក្តីថ្លែងអំណរគុណ

ដើម្បីសម្រេចបាននូវស្នាដៃសៀវភៅ «**ធរណីមាត្រ ថ្នាក់ទី១២**» មួយក្បាលនេះឡើង ប្រកបដោយគុណភាព និងភាពសុក្រឹត ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

- **ក្រសួងអប់រំ យុវជន និងកីឡា** ដែលបានបង្កើតកម្មវិធីសិក្សាគណិតវិទ្យា និងឯកសារមេរៀនគ្រឹះដ៏មានតម្លៃសម្រាប់សិស្សានុសិស្សទូទាំងប្រទេសកម្ពុជា។
- **គណៈកម្មការរៀបរៀង និងត្រួតពិនិត្យខ្លឹមសារ** ជាពិសេស លោកគ្រូ **ឡាយ ចាន់ហេន** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយពិនិត្យ កែលម្អ និងផ្តល់នូវជាតុចូលយ៉ាងល្អិតល្អន់ទាំងផ្នែកទ្រឹស្តី និងលំហាត់។
- **លោកគ្រូ-អ្នកគ្រូគណិតវិទ្យាគ្រប់រូប** ដែលតែងតែបានលះបង់កម្លាំងកាយចិត្តក្នុងការបណ្តុះបណ្តាលចំណេះដឹង និងផ្តល់ការគាំទ្រ លើកទឹកចិត្តដល់ការស្រាវជ្រាវ និងចងក្រងឯកសារនេះ។
- **ក្រុមគ្រួសារ និងមិត្តភក្តិទាំងអស់** ដែលតែងតែផ្តល់នូវការលើកទឹកចិត្ត ភាពកក់ក្តៅ និងការគាំទ្រគ្រប់បែបយ៉ាងជានិច្ចកាល។

ដោយក្តីគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅ

**លោកគ្រូ ខែម ពុទ្ធី**

# តារាងនិមិត្តសញ្ញាគណិតវិទ្យា

| និមិត្តសញ្ញា | អត្ថន័យ និងនិយមន័យ |
| --- | --- |
| $\mathbb{R}$, $\mathbb{R}^3$ | សំណុំចំនួនពិត និងលំហវិមាត្របី |
| $(O,\vec{i},\vec{j},\vec{k})$ | តម្រុយអរតូណរម៉ាល់ក្នុងលំហ |
| $M(x,y,z)$ | កូអរដោនេនៃចំណុច $M$ ក្នុងលំហ ($x$: អាប់ស៊ីស, $y$: អរដោនេ, $z$: កូត) |
| $\vec{u},\vec{v},\vec{w}$ | វ៉ិចទ័រក្នុងលំហ |
| $\overrightarrow{AB}$ | វ៉ិចទ័រមានចំណុចដើម $A$ និងចំណុចចុង $B$ |
| $\lvert\vec{u}\rvert$ ឬ $\lVert\vec{u}\rVert$ | ណម ឬប្រវែងនៃវ៉ិចទ័រ $\vec{u}$ |
| $\vec{u}\cdot\vec{v}$ | ផលគុណស្កាលែនៃពីរវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ |
| $\vec{u}\times\vec{v}$ | ផលគុណនៃពីរវ៉ិចទ័រ (ផលគុណវ៉ិចទ័រ) នៃ $\vec{u}$ និង $\vec{v}$ |
| $\vec{u}\cdot(\vec{v}\times\vec{w})$ | ផលគុណចម្រុះនៃបីវ៉ិចទ័រ $\vec{u},\vec{v},\vec{w}$ |
| $\vec{u}\perp\vec{v}$ | វ៉ិចទ័រ $\vec{u}$ កែងនឹងវ៉ិចទ័រ $\vec{v}$ $(\vec{u}\cdot\vec{v}=0)$ |
| $\vec{u}\parallel\vec{v}$ | វ៉ិចទ័រ $\vec{u}$ ស្របនឹងវ៉ិចទ័រ $\vec{v}$ $(\vec{u}\times\vec{v}=\vec{0})$ |
| $(L)$ | បន្ទាត់ក្នុងលំហ |
| $(P)$ ឬ $(\alpha)$ | ប្លង់ក្នុងលំហ |
| $(S)$ | ស្វ៊ែក្នុងលំហដែលមានផ្ចិត $I$ និងកាំ $R$ |
| $d(A,B)$ | ចម្ងាយរវាងពីរចំណុច $A$ និង $B$ |
| $d(M,(P))$ | ចម្ងាយពីចំណុច $M$ ទៅប្លង់ $(P)$ |
| $d(M,(L))$ | ចម្ងាយពីចំណុច $M$ ទៅបន្ទាត់ $(L)$ |
| $d((L_1),(L_2))$ | ចម្ងាយរវាងបន្ទាត់ពីរខ្វែងគ្នា $(L_1)$ និង $(L_2)$ |
| $S$ | ផ្ទៃក្រឡា (ត្រីកោណ, ប្រលេឡូក្រាម, ...) |
| $V$ | មាឌ (ប្រលេពីប៉ែត, តេត្រាអ៊ែត, ស្វ៊ែ, ...) |
| $\cos\alpha,\cos\beta,\cos\gamma$ | កូស៊ីនុសទិសដៅនៃវ៉ិចទ័រធៀបនឹងអ័ក្សកូអរដោនេទាំងបី |

# មាតិការ

ខ្លឹមសារ ទំព័រ


**មេរៀនទី ១ : មេរៀនទី១ វ៉ិចទ័រក្នុងលំហ . . . 8**

១ និយមន័យកូអរដោនេ . . . 8

២ លក្ខណៈកូអរដោនេ . . . 9

៣ ទិសដៅកូស៊ីនុស . . . 10

៤ និយមន័យផលគុណស្កាលែនៃវ៉ិចទ័រក្នុងលំហ . . . 11

៥ លក្ខណៈនៃផលគុណស្កាលែ . . . 11

៦ ផលគុណស្កាលែក្នុងគោលអរតូកូណាល់ . . . 12

៧ កូអរដោនេចំណុចកណ្តាលនៃពីរចំណុច . . . 14

៨ សំណួរពហុជ្រើសរើស (Multiple Choice Questions) . . . 16

**មេរៀនទី ២ : មេរៀនទី២ ផលគុណនៃពីរវ៉ិចទ័រក្នុងលំហ . . . 36**

១ ផលគុណនៃពីរវ៉ិចទ័រក្នុងលំហ . . . 36

២ លក្ខណៈផលគុណនៃពីរវ៉ិចទ័រ . . . 39

៣ ផលគុណចម្រុះនៃបីវ៉ិចទ័រ . . . 39

៤ សំណួរពហុជ្រើសរើស (Multiple Choice Questions) . . . 40

**មេរៀនទី ៣ : មេរៀនទី៣ អនុវត្តន៍នៃផលគុណវ៉ិចទ័រ . . . 58**

១ ចម្ងាយរវាងពីរចំណុច . . . 58

២ សមីការបន្ទាត់ក្នុងលំហ . . . 58

៣ សមីការបន្ទាត់កាត់តាមមួយចំណុច និងស្គាល់វ៉ិចទ័រប្រាប់ទិស . . . 59

៤ សមីការបន្ទាត់កាត់តាមពីរចំណុចក្នុងលំហ . . . 60

៥ សមីការបន្ទាត់ដែលកំណត់ដោយប្លង់ពីរប្រសព្វគ្នា . . . 61

៦ សមីការបន្ទាត់កាត់តាមចំណុចមួយហើយកែងទៅនឹងប្លង់មួយ . . . 62

៧ សមីការប្លង់ . . . 63

៨ មុំរវាងប្លង់ពីរ . . . 74

៩ ចម្ងាយពីចំណុចមួយទៅប្លង់មួយ . . . 76

១០ ចម្ងាយពីចំណុចមួយទៅបន្ទាត់មួយក្នុងលំហ . . . 77

១១ សមីការស្វ៊ែ . . . 77

១២ វិសមីការតំបន់ផ្នែកខាងក្នុង . . . 80

១៣ វិសមីការតំបន់ផ្នែកខាងក្រៅ . . . 80

១៤ ទីតាំងរវាងស្វ៊ែ $(S)$ និងប្លង់ $(P)$ . . . 82

១៥ ទីតាំងរវាងស្វ៊ែពីរមានកាំ $r$ និង $r'$ . . . 82

១៦ សំណួរពហុជ្រើសរើស (Multiple Choice Questions) . . . 83

**ផ្នែកដំណោះស្រាយ . . . 192**

**ឧបសម្ពន្ធ . . . 257**

**ឯកសារយោង . . . 265**




## ១ និយមន័យកូអរដោនេ

**និយមន័យ ១**

គេ មាន តម្រុយ $\left(O,\vec{i},\vec{j},\vec{k}\right)$ មួយ ក្នុង លំហ។
ចំពោះគ្រប់ចំណុច $P$ មានត្រីធាតុ $(x,y,z)$ តែមួយគត់ ដែល $\overrightarrow{OP}=x\cdot\vec{i}+y\cdot\vec{j}+z\cdot\vec{k}$។

ត្រីធាតុ $(x,y,z)$ ហៅថា **កូអរដោនេនៃចំណុច** $P$ គេកំណត់សរសេរដោយ $\mathbf{P}(\mathbf{x},\mathbf{y},\mathbf{z})$ ដែល៖

- $x$ ជាអាប់ស៊ីស
- $y$ ជាអរដោនេ
- $z$ ជាកូត




**សម្គាល់៖** $\vec{i}=(1,0,0)$; $\vec{j}=(0,1,0)$ ; $\vec{k}=(0,0,1)$ ហៅថា **វិចទ័រឯកតា**។

**លំហាត់គំរូ ១**

គេឲ្យចំណុច $A(1,2,3), B(2,3,5), C(-3,2,4)$ និង $D(-3,1,4)$។ ចូរដៅចំណុចទាំងនេះនៅក្នុងតម្រុយអរតូណរមេ $(O,\vec{i},\vec{j},\vec{k})$

**ដំណោះស្រាយ**

ដើម្បីដៅចំណុច $M(x,y,z)$ ក្នុងតម្រុយអរតូណរមេ $(O,\vec{i},\vec{j},\vec{k})$ យើងអនុវត្តដូចខាងក្រោម៖

- រាប់ប្រវែង $x$ ឯកតាតាមបណ្តោយអ័ក្ស $(Ox)$
- រាប់ប្រវែង $y$ ឯកតាស្របតាមទិសដៅអ័ក្ស $(Oy)$
- រាប់ប្រវែង $z$ ឯកតាស្របតាមទិសដៅអ័ក្ស $(Oz)$។




## ២ លក្ខណៈកូអរដោនេ

**ជាទូទៅ ១**

គេមានចំណុច $A(x_A, y_A, z_A)$ និង $B(x_B, y_bB, z_B)$ នោះកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB}(x_B - x_A, y_B - x_A, z_B - z_A)$។

**ជាទូទៅ ២**

បើ $\vec{u}(x,y,z)$ និង $\vec{u}'(x',y',z')$ ជាពីរវ៉ិចទ័រក្នុងលំហ គេបាន

- $\vec{u}=\vec{u}' \quad \Leftrightarrow \begin{cases} x=x' \\ y=y' \\ z=z' \end{cases}$
- $\vec{u}\neq\vec{u}' \quad \Leftrightarrow \left[\begin{array}{l} x\neq x' \\ y\neq y' \\ z\neq z' \end{array}\right.$
- $\vec{u}+\vec{u}'=(x+x',y+y',z+z')$
- $\vec{u}-\vec{u}'=(x-x',y-y',z-z')$
- $\forall k\in\mathbb{R} \quad \Rightarrow \; k\cdot\vec{u}=(kx,ky,kz)$
- $\forall (k,k')\in\mathbb{R}^{\nvDash} \quad \Rightarrow \; k\vec{u}+k'\vec{u}'=(kx+k'x',ky+k'y',kz+k'z')$
- ចំណាំ៖ ប្រវែងនៃវ៉ិចទ័រ $\vec{u}$ គឺ ណមនៃ$\vec{u}$ កំណត់ដោយ $|u|=\sqrt{x^2+y^2+z^2}$

## ៣ ទិសដៅកូស៊ីនុស

**ជាទូទៅ ៣**

គេឲ្យវ៉ិចទ័រ $\vec{u}=(x,y,z)$ មួយ និងចំណុច $P$ នៅក្នុងលំហដែល $\vec{u}=\overrightarrow{OP}$។




- $\alpha$ ជាមុំដែលកើតឡើងដោយ $\overrightarrow{OP}$ និងអ័ក្ស $(Ox)$
- $\beta$ ជាមុំដែលកើតឡើងដោយ $\overrightarrow{OP}$ និងអ័ក្ស $(Oy)$
- $\gamma$ ជាមុំដែលកើតឡើងដោយ $\overrightarrow{OP}$ និងអ័ក្ស $(Oz)$ (មានបង្ហាញក្នុងរូប)

តាមទំនាក់ទំនងត្រីកោណមាត្រយើងបាន៖

- $\cos\alpha=\frac{x}{|\overrightarrow{OP}|} \quad \Rightarrow \; x=\left|\overrightarrow{OP}\right|\cos\alpha$
- $\cos\beta=\frac{y}{|\overrightarrow{OP}|} \quad \Rightarrow \; y=\left|\overrightarrow{OP}\right|\cos\beta$

- $\cos\gamma = \frac{z}{\left|\overrightarrow{OP}\right|} \quad \Rightarrow \quad z = \left|\overrightarrow{OP}\right|\cos\gamma$

គេបាន

$$\left|\overrightarrow{OP}\right|^2 = x^2+y^2+z^2 = \left|\overrightarrow{OP}\right|^2\left(\cos^2\alpha+\cos^2\beta+\cos^2\gamma\right)$$

$$\Rightarrow \cos^2\alpha+\cos^2\beta+\cos^2\gamma = \frac{\left|\overrightarrow{OP}\right|^2}{\left|\overrightarrow{OP}\right|^2} = 1$$

តម្លៃ $\cos\alpha$ ; $\cos\beta$ និង $\cos\gamma$ នេះ គឺបញ្ជាក់ពីទិសដៅកូស៊ីនុសនៃវ៉ិចទ័រ $\vec{u} = \overrightarrow{OP}$ ។

## ៤ និយមន័យផលគុណស្កាលែនៃវ៉ិចទ័រក្នុងលំហ

**និយមន័យ ២**

ផលគុណស្កាលែនៃពីរវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ក្នុងលំហ គឺជាចំនួនពិត $k$ មួយដែលកំណត់ដោយ៖

- $\vec{u}\cdot\vec{v} = |\vec{u}|\cdot|\vec{v}|\cos\theta$ ដែល $\theta$ ជាមុំផ្គុំឡើងដោយវ៉ិចទ័រ $\vec{u}$ និង $\vec{v}$




## ៥ លក្ខណៈនៃផលគុណស្កាលែ

**ជាទូទៅ ៤**

- ចំពោះបីចំណុច $A$ ; $B$ ; $C$ ដែល $A \neq B$ និង $A \neq C$ គេបាន
$\overrightarrow{AB}\cdot\overrightarrow{AC} = \left|\overrightarrow{AB}\right|\cdot\left|\overrightarrow{AC}\right|\cos\theta$ ដែល $\theta$ ជាមុំផ្គុំឡើងដោយវ៉ិចទ័រ $\overrightarrow{AB}$ និង $\overrightarrow{AC}$

  – ចំណុច $A(x_A, y_A, z_A)$ ; $B(x_B, y_B, z_B)$ $\Rightarrow$ $\overrightarrow{AB}(x_B - x_A, y_B - y_A, z_B - z_A)$

– ណមនៃវ៉ិចទ័រ $\overrightarrow{AB}$ គឺជាចម្ងាយពី $A$ ទៅ $B$៖
$$\left|\overrightarrow{AB}\right| = AB = d(A,B) = \sqrt{(x_B - x_A)^2 + (y_B - y_A)^2 + (z_B - z_A)^2}$$

- $\overrightarrow{u}\cdot\overrightarrow{v} = \overrightarrow{v}\cdot\overrightarrow{u}$
- $\overrightarrow{u}\perp\overrightarrow{v} \Leftrightarrow \overrightarrow{u}\cdot\overrightarrow{v} = 0 \quad (\overrightarrow{u}\neq 0;\ \overrightarrow{v}\neq 0)$
- $(m\overrightarrow{u})\cdot\overrightarrow{v} = m(\overrightarrow{u}\cdot\overrightarrow{v})$
- $|\overrightarrow{u}\cdot\overrightarrow{v}| \leq |\overrightarrow{u}|\cdot|\overrightarrow{v}|$ ហៅថា **វិសមភាពកូស៊ី**
- $|\overrightarrow{u}+\overrightarrow{v}| \leq |\overrightarrow{u}|+|\overrightarrow{v}|$ ហៅថា **វិសមភាពត្រីកោណ**

## ៦ ផលគុណស្កាលែក្នុងគោលអរតូណរម៉ាល់

**និយមន័យ ៣**

**គោលអរតូណរម៉ាល់នៃវ៉ិចទ័រ** គឺគ្រប់ត្រីធាតុ $\left(\overrightarrow{i},\overrightarrow{j},\overrightarrow{k}\right)$ ដែល $\left|\overrightarrow{i}\right| = \left|\overrightarrow{j}\right| = \left|\overrightarrow{k}\right| = 1$
និង $\overrightarrow{i}\cdot\overrightarrow{j} = \overrightarrow{j}\cdot\overrightarrow{k} = \overrightarrow{k}\cdot\overrightarrow{i} = 0$

**ជាទូទៅ ៥**

គេមានពីរវ៉ិចទ័រ $\overrightarrow{u} = (x,y,z)$ និង $\overrightarrow{v} = (x',y',z')$ ស្ថិតក្នុងគោលអរតូណរម៉ាល់នៃលំហ គេបាន

- $\overrightarrow{u} = (x,y,z) = x\,\overrightarrow{i} + y\,\overrightarrow{j} + z\,\overrightarrow{k}$
- $\overrightarrow{u}\cdot\overrightarrow{v} = xx' + yy' + zz'$
- $\overrightarrow{u} /\!/ \overrightarrow{v} \Leftrightarrow \overrightarrow{u} = k\cdot\overrightarrow{v} \Leftrightarrow \frac{x}{x'} = \frac{y}{y'} = \frac{z}{z'}$
- $\overrightarrow{u}\perp\overrightarrow{v} \Leftrightarrow xx' + yy' + zz' = 0$
- $|\overrightarrow{u}| = \sqrt{x^2+y^2+z^2}$
- $\overrightarrow{u}\cdot\overrightarrow{v} = |\overrightarrow{u}|\cdot|\overrightarrow{v}|\cos\theta \implies \cos\theta = \frac{\overrightarrow{u}\cdot\overrightarrow{v}}{|\overrightarrow{u}|\cdot|\overrightarrow{v}|} = \frac{xx'+yy'+zz'}{\sqrt{x^2+y^2+z^2}\sqrt{x'^2+y'^2+z'^2}}$

**ខាទូនៅ ៦**

- $\vec{u}\cdot(\vec{v}+\vec{w})=\vec{u}\cdot\vec{v}+\vec{u}\cdot\vec{w}$
- $\vec{u}\cdot(m\vec{v})=m(\vec{u}\cdot\vec{v})$
- $(\vec{u}+\vec{v})\cdot\vec{w}=\vec{u}\cdot\vec{w}+\vec{v}\cdot\vec{w}$
- $(m\vec{u})\cdot\vec{v}=m(\vec{u}\cdot\vec{v})$

**លំហាត់គំរូ ២**

នៅក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេឱ្យពីរវ៉ិចទ័រ $\vec{u}=\vec{i}+\vec{j}+\vec{k}$ និង $\vec{v}=\vec{i}-\vec{j}+\sqrt{6}\vec{k}$។

ក. គណនា $|\vec{u}|,|\vec{v}|$ និង $\vec{u}\cdot\vec{v}$ ។

ខ. គណនាមុំស្រួចដែលផ្គុំដោយវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ។

**ដំណោះស្រាយ**

ក. គណនា $|\vec{u}|,|\vec{v}|$ និង $\vec{u}\cdot\vec{v}$ ៖

- វ៉ិចទ័រ $\vec{u}=\vec{i}+\vec{j}+\vec{k}=(1,1,1)$

$$|\vec{u}|=\sqrt{1^2+1^2+1^2}=\sqrt{3}$$

- វ៉ិចទ័រ $\vec{v}=\vec{i}-\vec{j}+\sqrt{6}\vec{k}=(1,-1,\sqrt{6})$

$$|\vec{v}|=\sqrt{1^2+(-1)^2+(\sqrt{6})^2}=\sqrt{1+1+6}=\sqrt{8}=2\sqrt{2}$$

- ផលគុណស្កាលែ $\vec{u}\cdot\vec{v}$ ៖

$$\vec{u}\cdot\vec{v}=(1)(1)+(1)(-1)+(1)(\sqrt{6})=1-1+\sqrt{6}=\sqrt{6}$$

ខ. គណនាមុំស្រួច $\theta$ ដែលផ្គុំដោយវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ៖

តាមរូបមន្តកូស៊ីនុសនៃមុំរវាងពីរវ៉ិចទ័រ៖

$$\cos\theta=\frac{\vec{u}\cdot\vec{v}}{|\vec{u}|\cdot|\vec{v}|}=\frac{\sqrt{6}}{\sqrt{3}\cdot2\sqrt{2}}=\frac{\sqrt{6}}{2\sqrt{6}}=\frac{1}{2}$$

ដោយសារ $\theta$ ជាមុំស្រួច $(0^\circ\leq\theta\leq90^\circ)$ នាំឱ្យយើងបាន៖

$$\theta=60^\circ \quad \left(\text{ឬ } \theta=\frac{\pi}{3} \text{ រ៉ាដ្យង់}\right)$$

# ៧ កូអរដោនេចំណុចកណ្ដាលនៃពីរចំណុច

**ជាទូទៅ ៧**

គេមានចំណុច $A(x_1,y_1,z_1)$; $B(x_2,y_2,z_2)$ យើងបាន កូអរដោនេចំណុចកណ្ដាលនៃអង្កត់ $[AB]$ គឺ ៖

$$I\left(\frac{x_A+x_B}{2},\frac{y_A+y_B}{2},\frac{z_A+z_B}{2}\right)$$

**លំហាត់គំរូ ៣**

រកកូអរដោនេចំណុចកណ្ដាលនៃពីរចំណុចខាងក្រោម៖

ក. $A(2,1,1)$ និង $B(4,3,1)$

ខ. $A(-2,3,5)$ និង $B(3,-1,1)$

គ. $A(-2,-3,0)$ និង $B(0,-1,-3)$

ឃ. $A(3,-11,-6)$ និង $B(-4,0,1)$

ង. $A(-\sqrt{3},1,\sqrt{2})$ និង $B(3\sqrt{3},3,2\sqrt{2})$

ច. $A(-2,-3,4)$ និង $B(2,-1,-3)$

**ដំណោះស្រាយ**

រូបមន្តកូអរដោនេចំណុចកណ្ដាល $I$ នៃអង្កត់ $[AB]$ គឺ $I\left(\frac{x_A+x_B}{2},\frac{y_A+y_B}{2},\frac{z_A+z_B}{2}\right)$ ៖

ក. ចំពោះ $A(2,1,1)$ និង $B(4,3,1)$ ៖

$$I\left(\frac{2+4}{2},\frac{1+3}{2},\frac{1+1}{2}\right) \Longrightarrow I(3,2,1)$$

ខ. ចំពោះ $A(-2,3,5)$ និង $B(3,-1,1)$ ៖

$$I\left(\frac{-2+3}{2},\frac{3+(-1)}{2},\frac{5+1}{2}\right) \Longrightarrow I\left(\frac{1}{2},1,3\right)$$

គ. ចំពោះ $A(-2,-3,0)$ និង $B(0,-1,-3)$ ៖

$$I\left(\frac{-2+0}{2},\frac{-3+(-1)}{2},\frac{0+(-3)}{2}\right) \Longrightarrow I\left(-1,-2,-\frac{3}{2}\right)$$

ឃ. ចំពោះ $A(3,-11,-6)$ និង $B(-4,0,1)$ ៖

$$I\left(\frac{3+(-4)}{2},\frac{-11+0}{2},\frac{-6+1}{2}\right) \Longrightarrow I\left(-\frac{1}{2},-\frac{11}{2},-\frac{5}{2}\right)$$

ង. ចំពោះ $A(-\sqrt{3},1,\sqrt{2})$ និង $B(3\sqrt{3},3,2\sqrt{2})$ ៖

$$I\left(\frac{-\sqrt{3}+3\sqrt{3}}{2},\frac{1+3}{2},\frac{\sqrt{2}+2\sqrt{2}}{2}\right) \Longrightarrow I\left(\sqrt{3},2,\frac{3\sqrt{2}}{2}\right)$$

ច. ចំពោះ $A(-2,-3,4)$ និង $B(2,-1,-3)$ ៖

$$I\left(\frac{-2+2}{2},\frac{-3+(-1)}{2},\frac{4+(-3)}{2}\right) \Longrightarrow I\left(0,-2,\frac{1}{2}\right)$$

## ៨ សំណួរពហុជ្រើសរើស (Multiple Choice Questions)

ចូរបញ្ជាក់ចម្លើយត្រឹមត្រូវតែមួយគត់ក្នុងចំណោមជម្រើស ក, ខ, គ, និង ឃ ៖

១. ក្នុងតម្រុយ $(O,\vec{i},\vec{j},\vec{k})$ ចំណុច $M(2,-3,5)$ មានកូអរដោនេតាមអ័ក្សកូត $(z)$ ស្មើនឹង៖

ក. $2$ ខ. $-3$ គ. $5$ ឃ. $-5$

២. ចំណោលកែងនៃចំណុច $A(3,4,-2)$ លើប្លង់ $(Oxy)$ គឺ៖

ក. $(3,4,0)$ ខ. $(3,0,-2)$ គ. $(0,4,-2)$ ឃ. $(0,0,-2)$

៣. ចំណោលកែងនៃចំណុច $B(-1,5,7)$ លើប្លង់ $(Oyz)$ គឺ៖

ក. $(-1,5,0)$ ខ. $(0,5,7)$ គ. $(-1,0,7)$ ឃ. $(0,0,7)$

៤. ចំណោលកែងនៃចំណុច $C(6,-2,4)$ លើប្លង់ $(Oxz)$ គឺ៖

ក. $(6,0,4)$ ខ. $(6,-2,0)$ គ. $(0,-2,4)$ ឃ. $(0,0,4)$

៥. ចំណោលកែងនៃចំណុច $M(4,-5,3)$ លើអ័ក្ស $(Ox)$ គឺ៖

ក. $(0,-5,3)$ ខ. $(4,0,0)$ គ. $(0,-5,0)$ ឃ. $(0,0,3)$

៦. ចំណោលកែងនៃចំណុច $N(-2,8,-6)$ លើអ័ក្ស $(Oy)$ គឺ៖

ក. $(-2,0,0)$ ខ. $(0,0,-6)$ គ. $(0,8,0)$ ឃ. $(0,-8,0)$

៧. ចំណោលកែងនៃចំណុច $P(7,1,-9)$ លើអ័ក្ស $(Oz)$ គឺ៖

ក. $(0,0,-9)$ ខ. $(7,0,0)$ គ. $(0,1,0)$ ឃ. $(7,1,0)$

៨. ចំណុចឆ្លុះនៃ $A(1,-2,3)$ ធៀបនឹងគល់តម្រុយ $O$ គឺ៖

ក. $(-1,2,-3)$ ខ. $(-1,-2,3)$ គ. $(1,2,-3)$ ឃ. $(1,-2,-3)$

៩. ចំណុចឆ្លុះនៃ $M(3,4,5)$ ធៀបនឹងប្លង់ $(Oxy)$ គឺ៖

ក. $(-3,-4,5)$ ខ. $(3,4,-5)$ គ. $(-3,4,5)$ ឃ. $(3,-4,5)$

១០. ចម្ងាយពីចំណុច $A(3,-4,0)$ ទៅគល់តម្រុយ $O(0,0,0)$ គឺ៖

ក. $7$ ខ. $5$ គ. $25$ ឃ. $\sqrt{7}$

១១. ចម្ងាយពីចំណុច $M(1,2,2)$ ទៅគល់តម្រុយ $O$ គឺ៖

ក. $3$ ខ. $5$ គ. $9$ ឃ. $\sqrt{5}$

១២. ចម្ងាយពីចំណុច $P(2,3,6)$ ទៅគល់តម្រុយ $O$ គឺ៖

ក. $7$ ខ. $6$ គ. $11$ ឃ. $\sqrt{13}$

១៣. ចម្ងាយពីចំណុច $M(a,b,c)$ ទៅប្លង់ $(Oxy)$ ស្មើនឹង៖

ក. $|a|$ ខ. $|b|$ គ. $|c|$ ឃ. $\sqrt{a^2+b^2}$

១៤. ចម្ងាយពីចំណុច $M(2,-3,4)$ ទៅអ័ក្ស $(Oz)$ ស្មើនឹង៖

ក. $4$ ខ. $\sqrt{2^2+(-3)^2}=\sqrt{13}$ គ. $\sqrt{2^2+4^2}=\sqrt{20}$ ឃ. $3$

១៥. ចំណុចណាដែលស្ថិតនៅលើប្លង់ $(Oxz)$ ក្នុងចំណោមចំណុចខាងក្រោម?

ក. $A(1,2,0)$ ខ. $B(0,3,4)$ គ. $C(5,0,-2)$ ឃ. $D(0,0,7)$

១៦. គេឱ្យចំណុច $A(1,2,3)$ និង $B(4,6,8)$។ កូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB}$ គឺ៖

ក. $(3,4,5)$ ខ. $(-3,-4,-5)$ គ. $(5,8,11)$ ឃ. $(4,12,24)$

១៧. គេឱ្យ $A(-2,3,1)$ និង $B(1,-1,5)$។ វ៉ិចទ័រ $\overrightarrow{BA}$ គឺ៖

ក. $(3,-4,4)$ ខ. $(-3,4,-4)$ គ. $(-1,2,6)$ ឃ. $(1,-2,-6)$

១៨. គេឱ្យ $\vec{u}=(2,-1,3)$ និង $\vec{v}=(1,4,-2)$។ វ៉ិចទ័រ $\vec{u}+\vec{v}$ គឺ៖

ក. $(3,3,1)$ ខ. $(1,-5,5)$ គ. $(3,-5,1)$ ឃ. $(2,-4,-6)$

១៩. គេឱ្យ $\vec{u}=(4,-2,6)$ និង $\vec{v}=(1,3,-1)$។ វ៉ិចទ័រ $\vec{u}-\vec{v}$ គឺ៖

ក. $(3,-5,7)$ ខ. $(5,1,5)$ គ. $(3,1,7)$ ឃ. $(-3,5,-7)$

២០. គេឱ្យ $\vec{u}=(-3,2,-1)$។ វ៉ិចទ័រ $2\vec{u}$ គឺ៖

ក. $(-6,4,-2)$ ខ. $(-1,4,1)$ គ. $(-6,2,-2)$ ឃ. $(6,-4,2)$

២១. គេឱ្យ $\vec{u}=(1,-2,3)$ និង $\vec{v}=(3,0,-1)$។ វ៉ិចទ័រ $2\vec{u}-3\vec{v}$ គឺ៖

ក. $(-7,-4,9)$ ខ. $(11,-4,3)$ គ. $(-7,-4,3)$ ឃ. $(7,4,-9)$

២២. បើ $\overrightarrow{AB}=(2,-1,4)$ និង $A(1,3,-2)$ នោះកូអរដោនេនៃចំណុច $B$ គឺ៖

ក. $(3,2,2)$ ខ. $(1,-4,6)$ គ. $(-1,4,-6)$ ឃ. $(3,-2,2)$

២៣. បើ $\overrightarrow{AB}=(-3,5,2)$ និង $B(2,1,4)$ នោះកូអរដោនេនៃចំណុច $A$ គឺ៖

ក. $(5,-4,2)$ ខ. $(-1,6,6)$ គ. $(5,4,2)$ ឃ. $(-5,4,-2)$

២៤. វ៉ិចទ័រពីរ $\vec{u}=(2,-4,6)$ និង $\vec{v}=(1,m,3)$ កូលីនេអ៊ែរគ្នាកាលណា $m$ ស្មើនឹង៖

ក. $-2$ ខ. $2$ គ. $-4$ ឃ. $4$

២៥. វ៉ិចទ័រពីរ $\vec{u}=(3,-6,9)$ និង $\vec{v}=(-1,2,k)$ ស្របគ្នាកាលណា $k$ ស្មើនឹង៖

ក. $3$ ខ. $-3$ គ. $9$ ឃ. $-9$

២៦. បើ $\vec{u}=2\vec{i}-3\vec{j}+4\vec{k}$ នោះកូអរដោនេនៃ $\vec{u}$ គឺ៖

ក. $(2,-3,4)$ ខ. $(2,3,4)$ គ. $(-2,3,-4)$ ឃ. $(4,-3,2)$

២៧. បើ $\vec{v}=5\vec{i}-\vec{k}$ នោះកូអរដោនេនៃ $\vec{v}$ គឺ៖

ក. $(5,-1,0)$ ខ. $(5,0,-1)$ គ. $(0,5,-1)$ ឃ. $(5,1,0)$

២៨. បីចំណុច $A(1,2,3),B(2,4,5),C(4,8,9)$ ៖

ក. រត់ត្រង់ជួរគ្នា ព្រោះ $\overrightarrow{AB}\parallel\overrightarrow{AC}$ ខ. មិនរត់ត្រង់ជួរគ្នាទេ

គ. បង្កើតបានជាត្រីកោណកែង ឃ. បង្កើតបានជាត្រីកោណសម័ង្ស

២៩. វ៉ិចទ័រឯកតានៃអ័ក្ស $(Oz)$ គឺ៖

ក. $\vec{i}=(1,0,0)$ ខ. $\vec{j}=(0,1,0)$ គ. $\vec{k}=(0,0,1)$ ឃ. $\vec{0}=(0,0,0)$

៣០. ម៉ូឌុលនៃវ៉ិចទ័រ $\vec{u}=(1,-2,2)$ គឺ៖

ក. $3$ ខ. $9$ គ. $\sqrt{5}$ ឃ. $5$

៣១. ម៉ូឌុលនៃវ៉ិចទ័រ $\vec{v}=(0,-3,4)$ គឺ៖

ក. $5$ ខ. $7$ គ. $25$ ឃ. $\sqrt{7}$

៣២. វ៉ិចទ័រឯកតាស្របនឹង $\vec{u}=(3,0,4)$ គឺ៖

ក. $(\frac{3}{5},0,\frac{4}{5})$ ខ. $(3,0,4)$ គ. $(\frac{3}{7},0,\frac{4}{7})$ ឃ. $(\frac{3}{25},0,\frac{4}{25})$

៣៣. បើ $\alpha,\beta,\gamma$ ជាមុំរវាងវ៉ិចទ័រ $\vec{u}$ ជាមួយអ័ក្ស $Ox,Oy,Oz$ នោះទំនាក់ទំនងត្រឹមត្រូវគឺ៖

ក. $\cos\alpha+\cos\beta+\cos\gamma=1$ ខ. $\cos^2\alpha+\cos^2\beta+\cos^2\gamma=1$

គ. $\sin^2\alpha+\sin^2\beta+\sin^2\gamma=1$ ឃ. $\cos^2\alpha+\cos^2\beta+\cos^2\gamma=0$

៣៤. ទំនាក់ទំនងរវាង $\sin^2\alpha+\sin^2\beta+\sin^2\gamma$ ស្មើនឹង៖

ក. $1$ ខ. $2$ គ. $3$ ឃ. $0$

៣៥. ទិសដៅកូស៊ីនុសនៃវ៉ិចទ័រ $\vec{u}=(1,2,2)$ គឺ៖

ក. $\cos\alpha=\frac{1}{3},\cos\beta=\frac{2}{3},\cos\gamma=\frac{2}{3}$ ខ. $\cos\alpha=1,\cos\beta=2,\cos\gamma=2$

គ. $\cos\alpha=\frac{1}{9},\cos\beta=\frac{2}{9},\cos\gamma=\frac{2}{9}$ ឃ. $\cos\alpha=\frac{1}{\sqrt{5}},\cos\beta=\frac{2}{\sqrt{5}},\cos\gamma=0$

៣៦. ទិសដៅកូស៊ីនុសនៃវ៉ិចទ័រ $\vec{i}=(1,0,0)$ គឺ៖

ក. $\cos\alpha = 1, \cos\beta = 0, \cos\gamma = 0$

ខ. $\cos\alpha = 0, \cos\beta = 1, \cos\gamma = 0$

គ. $\cos\alpha = 0, \cos\beta = 0, \cos\gamma = 1$

ឃ. $\cos\alpha = \frac{1}{\sqrt{3}}, \cos\beta = \frac{1}{\sqrt{3}}, \cos\gamma = \frac{1}{\sqrt{3}}$

៣៧. បើ $\cos\alpha = \frac{1}{2}$ និង $\cos\beta = \frac{1}{2}$ នោះតម្លៃ $\cos^2\gamma$ ស្មើនឹង៖

ក. $\frac{1}{2}$ ខ. $\frac{1}{4}$ គ. $\frac{3}{4}$ ឃ. $0$

៣៨. បើ $\cos\alpha = \frac{\sqrt{2}}{2}$ និង $\cos\beta = \frac{1}{2}$ ហើយ $\gamma$ ជាមុំស្រួច នោះ $\gamma$ ស្មើនឹង៖

ក. $30°$ ខ. $45°$ គ. $60°$ ឃ. $90°$

៣៩. វ៉ិចទ័រ $\vec{u}$ បង្កើតបានមុំស្មើៗគ្នាជាមួយអ័ក្សកូអរដោនេទាំងបី។ តម្លៃ $|\cos\alpha|$ គឺ៖

ក. $\frac{1}{3}$ ខ. $\frac{1}{\sqrt{3}}$ គ. $\frac{\sqrt{3}}{2}$ ឃ. $\frac{1}{2}$

៤០. ទិសដៅកូស៊ីនុសនៃវ៉ិចទ័រ $\vec{v} = (0, 0, -5)$ គឺ៖

ក. $\cos\alpha = 0, \cos\beta = 0, \cos\gamma = -1$

ខ. $\cos\alpha = 0, \cos\beta = 0, \cos\gamma = 1$

គ. $\cos\alpha = 0, \cos\beta = -5, \cos\gamma = 0$

ឃ. $\cos\alpha = 1, \cos\beta = 0, \cos\gamma = -1$

៤១. បើ $\vec{u}$ មានទិសដៅកូស៊ីនុស $(\cos\alpha, \cos\beta, \cos\gamma)$ នោះវ៉ិចទ័រ $\vec{e} = (\cos\alpha, \cos\beta, \cos\gamma)$ ជា៖

ក. វ៉ិចទ័រសូន្យ

ខ. វ៉ិចទ័រឯកតា $(\|\vec{e}\| = 1)$

គ. វ៉ិចទ័រមានម៉ូឌុលស្មើ $3$

ឃ. វ៉ិចទ័រគ្មានទិសដៅ

៤២. រកទិសដៅកូស៊ីនុសនៃ $\overrightarrow{AB}$ ដែល $A(1, 1, 1)$ និង $B(2, 3, 3)$ ៖

ក. $\left(\frac{1}{3}, \frac{2}{3}, \frac{2}{3}\right)$

ខ. $(1, 2, 2)$

គ. $\left(\frac{1}{9}, \frac{2}{9}, \frac{2}{9}\right)$

ឃ. $\left(\frac{1}{\sqrt{3}}, \frac{2}{\sqrt{3}}, \frac{2}{\sqrt{3}}\right)$

៤៣. បើ $\alpha = 60°, \beta = 60°$ នោះមុំ $\gamma$ អាចមានតម្លៃ៖

ក. $45°$ ឬ $135°$ ខ. $30°$ ឬ $150°$ គ. $60°$ ឬ $120°$ ឃ. $90°$

៤៤. វ៉ិចទ័រមួយស្ថិតក្នុងប្លង់ $(Oxy)$។ ទិសដៅកូស៊ីនុស $\cos\gamma$ របស់វាស្មើនឹង៖

ក. $1$ ខ. $0$ គ. $-1$ ឃ. $\frac{1}{2}$

៤៥. វ៉ិចទ័រមួយស្របនឹងអ័ក្ស $(Oy)$ និងមានទិសដៅដូចគ្នា។ មុំ $\alpha, \beta, \gamma$ រៀងគ្នាគឺ៖

ក. $90°, 0°, 90°$

ខ. $0°, 90°, 90°$

គ. $90°, 90°, 0°$

ឃ. $0°, 0°, 0°$

៤៦. និយមន័យផលគុណស្កាលែនៃពីរវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ គឺ៖

ក. $\vec{u}\cdot\vec{v}=\|\vec{u}\|\|\vec{v}\|\sin\theta$  ខ. $\vec{u}\cdot\vec{v}=\|\vec{u}\|\|\vec{v}\|\cos\theta$

គ. $\vec{u}\cdot\vec{v}=\|\vec{u}\|+\|\vec{v}\|$  ឃ. $\vec{u}\cdot\vec{v}=\|\vec{u}\|\|\vec{v}\|\tan\theta$

៤៧. បើ $\|\vec{u}\|=3,\|\vec{v}\|=4$ និងមុំ $\theta=60^\circ$ នោះ $\vec{u}\cdot\vec{v}$ ស្មើនឹង៖

ក. $6$  ខ. $12$  គ. $6\sqrt{3}$  ឃ. $3$

៤៨. បើ $\|\vec{u}\|=5,\|\vec{v}\|=2$ និងមុំ $\theta=90^\circ$ នោះ $\vec{u}\cdot\vec{v}$ ស្មើនឹង៖

ក. $10$  ខ. $0$  គ. $5$  ឃ. $-10$

៤៩. បើ $\|\vec{u}\|=4,\|\vec{v}\|=3$ និងមុំ $\theta=180^\circ$ នោះ $\vec{u}\cdot\vec{v}$ ស្មើនឹង៖

ក. $12$  ខ. $-12$  គ. $0$  ឃ. $7$

៥០. បើ $\|\vec{u}\|=6,\|\vec{v}\|=\sqrt{2}$ និងមុំ $\theta=45^\circ$ នោះ $\vec{u}\cdot\vec{v}$ ស្មើនឹង៖

ក. $6$  ខ. $6\sqrt{2}$  គ. $12$  ឃ. $3$

៥១. ផលគុណស្កាលែ $\vec{u}\cdot\vec{u}$ ស្មើនឹង៖

ក. $\|\vec{u}\|$  ខ. $\|\vec{u}\|^2$  គ. $2\|\vec{u}\|$  ឃ. $0$

៥២. បើ $\vec{u}\cdot\vec{v}>0$ នោះមុំ $\theta$ រវាងវ៉ិចទ័រទាំងពីរជា៖

ក. មុំកែង  ខ. មុំស្រួច $(0^\circ\leq\theta<90^\circ)$  គ. មុំទាល $(90^\circ<\theta\leq 18$  ឃ. មុំរាប

៥៣. បើ $\vec{u}\cdot\vec{v}<0$ នោះមុំ $\theta$ រវាងវ៉ិចទ័រទាំងពីរជា៖

ក. មុំកែង  ខ. មុំស្រួច  គ. មុំទាល $(90^\circ<\theta\leq 18$  ឃ. មុំសូន្យ

៥៤. តម្លៃអតិបរមានៃ $\vec{u}\cdot\vec{v}$ គឺស្មើនឹង៖

ក. $\|\vec{u}\|\|\vec{v}\|$  ខ. $0$  គ. $-\|\vec{u}\|\|\vec{v}\|$  ឃ. $1$

៥៥. តម្លៃអប្បបរមានៃ $\vec{u}\cdot\vec{v}$ គឺស្មើនឹង៖

ក. $0$  ខ. $-\|\vec{u}\|\|\vec{v}\|$  គ. $\|\vec{u}\|\|\vec{v}\|$  ឃ. $-1$

៥៦. សម្រាប់គ្រប់វ៉ិចទ័រ $\vec{u}$ ផលគុណស្កាលែ $\vec{u}\cdot\vec{0}$ ស្មើនឹង៖

ក. $\vec{0}$  ខ. $0$  គ. $1$  ឃ. $\|\vec{u}\|$

៥៧. បើ $\|\vec{u}\|=2,\|\vec{v}\|=5$ និង $\vec{u}\cdot\vec{v}=5$ នោះមុំ $\theta$ ស្មើនឹង៖

ក. $30^\circ$  ខ. $45^\circ$  គ. $60^\circ$  ឃ. $90^\circ$

៥៨. បើ $\|\vec{u}\|=3,\|\vec{v}\|=2$ និង $\vec{u}\cdot\vec{v}=-3\sqrt{3}$ នោះមុំ $\theta$ ស្មើនឹង៖

ក. $120^\circ$  ខ. $135^\circ$  គ. $150^\circ$  ឃ. $180^\circ$

៥៩. លក្ខណៈត្រឡប់នៃផលគុណស្កាលែគឺ៖

ក. $\vec{u}\cdot\vec{v}=\vec{v}\cdot\vec{u}$ ខ. $\vec{u}\cdot\vec{v}=-(\vec{v}\cdot\vec{u})$

គ. $\vec{u}\cdot\vec{v}=\frac{1}{\vec{v}\cdot\vec{u}}$ ឃ. $\vec{u}\cdot\vec{v}=\|\vec{v}\cdot\vec{u}\|$

៦០. លក្ខខណ្ឌចាំបាច់ និងគ្រប់គ្រាន់ដើម្បីឱ្យ $\vec{u}\perp\vec{v}$ $(\vec{u},\vec{v}\neq\vec{0})$ គឺ៖

ក. $\vec{u}\cdot\vec{v}=1$ ខ. $\vec{u}\cdot\vec{v}=0$ គ. $\vec{u}=k\vec{v}$ ឃ. $\|\vec{u}\|=\|\vec{v}\|$

៦១. កន្សោម $(\vec{u}+\vec{v})^2$ ស្មើនឹង៖

ក. $\|\vec{u}\|^2+\|\vec{v}\|^2$ ខ. $\|\vec{u}\|^2+2\vec{u}\cdot\vec{v}+\|\vec{v}\|^2$

គ. $\|\vec{u}\|^2-2\vec{u}\cdot\vec{v}+\|\vec{v}\|^2$ ឃ. $2\|\vec{u}\|+2\|\vec{v}\|$

៦២. កន្សោម $(\vec{u}-\vec{v})^2$ ស្មើនឹង៖

ក. $\|\vec{u}\|^2-\|\vec{v}\|^2$ ខ. $\|\vec{u}\|^2-2\vec{u}\cdot\vec{v}+\|\vec{v}\|^2$

គ. $\|\vec{u}\|^2+2\vec{u}\cdot\vec{v}+\|\vec{v}\|^2$ ឃ. $(\|\vec{u}\|-\|\vec{v}\|)^2$

៦៣. កន្សោម $(\vec{u}+\vec{v})\cdot(\vec{u}-\vec{v})$ ស្មើនឹង៖

ក. $\|\vec{u}\|^2-\|\vec{v}\|^2$ ខ. $0$ គ. $\|\vec{u}\|^2+\|\vec{v}\|^2$ ឃ. $2\vec{u}\cdot\vec{v}$

៦៤. បើ $\|\vec{u}+\vec{v}\|=\|\vec{u}-\vec{v}\|$ នោះគេទាញបាន៖

ក. $\vec{u}\perp\vec{v}$ ខ. $\vec{u}\parallel\vec{v}$ គ. $\|\vec{u}\|=\|\vec{v}\|$ ឃ. $\vec{u}=\vec{v}$

៦៥. បើ $\|\vec{u}\|=3,\|\vec{v}\|=4$ និង $\vec{u}\perp\vec{v}$ នោះ $\|\vec{u}+\vec{v}\|$ ស្មើនឹង៖

ក. 7 ខ. 5 គ. 1 ឃ. 25

៦៦. បើ $\|\vec{u}\|=2,\|\vec{v}\|=3$ និង $\vec{u}\cdot\vec{v}=1$ នោះ $\|\vec{u}+\vec{v}\|^2$ ស្មើនឹង៖

ក. 13 ខ. 15 គ. 14 ឃ. 16

៦៧. បើ $\|\vec{u}\|=1,\|\vec{v}\|=2$ និង $\|\vec{u}+\vec{v}\|=\sqrt{7}$ នោះ $\vec{u}\cdot\vec{v}$ ស្មើនឹង៖

ក. 1 ខ. 2 គ. $\frac{1}{2}$ ឃ. 3

៦៨. ក្នុងគោលអរតូណរម៉ាល់ $(\vec{i},\vec{j},\vec{k})$ ផលគុណ $\vec{i}\cdot\vec{j}$ ស្មើនឹង៖

ក. 1 ខ. 0 គ. $\vec{k}$ ឃ. $-1$

៦៩. ក្នុងគោលអរតូណរម៉ាល់ $(\vec{i},\vec{j},\vec{k})$ ផលគុណ $\vec{k}\cdot\vec{k}$ ស្មើនឹង៖

ក. 0 ខ. 1 គ. $\vec{k}$ ឃ. $-1$

៧០. តម្លៃនៃ $\vec{i}\cdot\vec{i}+\vec{j}\cdot\vec{j}+\vec{k}\cdot\vec{k}$ គឺ៖

ក. 1 ខ. 2 គ. 3 ឃ. 0

៧១. គេឱ្យ $\vec{u}=(x,y,z)$ និង $\vec{v}=(x',y',z')$។ កន្សោមវិភាគនៃ $\vec{u}\cdot\vec{v}$ គឺ៖

ក. $xx'+yy'+zz'$ ខ. $xy'+yz'+zx'$

គ. $(x+x')+(y+y')+(z+z')$ ឃ. $\sqrt{x^2+y^2+z^2}\cdot\sqrt{x'^2+y'^2+z'^2}$

៧២. គេឱ្យ $\vec{u}=(1,2,3)$ និង $\vec{v}=(4,-1,2)$។ ផលគុណស្កាលែ $\vec{u}\cdot\vec{v}$ គឺ៖

ក. 8 ខ. 6 គ. 12 ឃ. 4

៧៣. គេឱ្យ $\vec{u}=(2,-3,1)$ និង $\vec{v}=(3,1,-2)$។ ផលគុណស្កាលែ $\vec{u}\cdot\vec{v}$ គឺ៖

ក. 1 ខ. 0 គ. $-1$ ឃ. 7

៧៤. គេឱ្យ $\vec{u}=(m,2,-1)$ និង $\vec{v}=(3,-1,4)$។ រក $m$ ដើម្បីឱ្យ $\vec{u}\perp\vec{v}$ ៖

ក. $m=2$ ខ. $m=-2$ គ. $m=6$ ឃ. $m=1$

៧៥. គេឱ្យ $\vec{u}=(1,-3,2)$ និង $\vec{v}=(2,k,4)$។ រក $k$ ដើម្បីឱ្យ $\vec{u}\perp\vec{v}$ ៖

ក. $k=\frac{10}{3}$ ខ. $k=-\frac{10}{3}$ គ. $k=3$ ឃ. $k=4$

៧៦. គេឱ្យ $A(1,0,2),B(2,1,3),C(0,2,1)$។ ផលគុណស្កាលែ $\overrightarrow{AB}\cdot\overrightarrow{AC}$ ស្មើនឹង៖

ក. 0 ខ. 1 គ. 2 ឃ. $-1$

៧៧. ពីសំណួរខាងលើ ត្រីកោណ $ABC$ ជាប្រភេទត្រីកោណអ្វី?

ក. ត្រីកោណកែងត្រង់ $A$ ខ. ត្រីកោណសមបាត គ. ត្រីកោណសម័ង្ស ឃ. ត្រីកោណកែងត្រង់ $B$

៧៨. គណនាមុំ $\theta$ រវាងវ៉ិចទ័រ $\vec{u}=(1,1,0)$ និង $\vec{v}=(0,1,1)$ ៖

ក. $30^\circ$ ខ. $45^\circ$ គ. $60^\circ$ ឃ. $90^\circ$

៧៩. គណនាកូស៊ីនុសនៃមុំរវាង $\vec{u}=(1,2,2)$ និង $\vec{v}=(2,1,-2)$ ៖

ក. 0 ខ. $\frac{1}{9}$ គ. $\frac{2}{9}$ ឃ. $-\frac{2}{9}$

៨០. វ៉ិចទ័រពីរ $\vec{u}=(1,2,2)$ និង $\vec{v}=(2,1,-2)$ ៖

ក. កែងគ្នា ខ. ស្របគ្នា គ. មានទិសដៅផ្ទុយគ្នា ឃ. មានប្រវែងស្មើគ្នា និងកែងគ្នា

៨១. ចម្ងាយរវាងពីរចំណុច $A(1,2,3)$ និង $B(3,0,2)$ គឺ៖

ក. 3 ខ. 9 គ. $\sqrt{5}$ ឃ. $\sqrt{7}$

៨២. ចម្ងាយរវាងពីរចំណុច $M(-1,3,2)$ និង $N(2,-1,2)$ គឺ៖

ក. $5$ ខ. $25$ គ. $\sqrt{7}$ ឃ. $\sqrt{41}$

៨៣. ចម្ងាយរវាងពីរចំណុច $P(0,0,0)$ និង $Q(2,-3,6)$ គឺ៖

ក. $7$ ខ. $49$ គ. $5$ ឃ. $\sqrt{13}$

៨៤. រកតម្លៃ $x$ បើចម្ងាយរវាង $A(x,1,2)$ និង $B(1,1,2)$ ស្មើនឹង $3$ ៖

ក. $x=4$ ឬ $x=-2$ ខ. $x=2$ ឬ $x=-4$ គ. $x=3$ ឬ $x=-3$ ឃ. $x=1$

៨៥. គេឱ្យ $\vec{u}=(1,1,1)$ និង $\vec{v}=(1,-1,0)$។ មុំរវាង $\vec{u}$ និង $\vec{v}$ គឺ៖

ក. $0^\circ$ ខ. $45^\circ$ គ. $60^\circ$ ឃ. $90^\circ$

៨៦. គេឱ្យ $\vec{u}=(2,0,0)$ និង $\vec{v}=(1,1,0)$។ មុំរវាង $\vec{u}$ និង $\vec{v}$ គឺ៖

ក. $30^\circ$ ខ. $45^\circ$ គ. $60^\circ$ ឃ. $90^\circ$

៨៧. គេឱ្យ $\vec{u}=(1,0,1)$ និង $\vec{v}=(-1,0,1)$។ ផលគុណស្កាលែ $\vec{u}\cdot\vec{v}$ ស្មើនឹង៖

ក. $0$ ខ. $2$ គ. $-2$ ឃ. $1$

៨៨. បើ $\vec{u}=(2,-1,3)$ នោះ $\|\vec{u}\|^2$ ស្មើនឹង៖

ក. $14$ ខ. $\sqrt{14}$ គ. $4$ ឃ. $12$

៨៩. កូអរដោនេចំណុចកណ្ដាល $I$ នៃអង្កត់ $[AB]$ ដែល $A(1,2,3)$ និង $B(3,4,5)$ គឺ៖

ក. $(2,3,4)$ ខ. $(4,6,8)$ គ. $(1,1,1)$ ឃ. $(2,2,2)$

៩០. កូអរដោនេចំណុចកណ្ដាល $I$ នៃអង្កត់ $[AB]$ ដែល $A(-3,5,2)$ និង $B(1,-1,4)$ គឺ៖

ក. $(-1,2,3)$ ខ. $(-2,4,6)$ គ. $(2,3,1)$ ឃ. $(-1,3,2)$

៩១. បើ $I(2,1,-1)$ ជាចំណុចកណ្ដាលនៃ $[AB]$ ហើយ $A(1,3,0)$ នោះកូអរដោនេនៃ $B$ គឺ៖

ក. $(3,-1,-2)$ ខ. $(3,4,-1)$ គ. $(1.5,2,-0.5)$ ឃ. $(0,-2,-1)$

៩២. បើ $M(0,2,4)$ ជាចំណុចកណ្ដាលនៃ $[AB]$ ហើយ $B(2,-1,3)$ នោះកូអរដោនេនៃ $A$ គឺ៖

ក. $(-2,5,5)$ ខ. $(2,1,7)$ គ. $(-1,3,5)$ ឃ. $(1,0.5,3.5)$

៩៣. ទីប្រជុំទម្ងន់ $G$ នៃត្រីកោណ $ABC$ ដែល $A(1,2,0), B(3,0,4), C(2,4,5)$ គឺ៖

ក. $(2,2,3)$ ខ. $(6,6,9)$ គ. $(3,3,4.5)$ ឃ. $(1,1,1.5)$

៩៤. ទីប្រជុំទម្ងន់ $G$ នៃត្រីកោណ $ABC$ ដែល $A(-1,3,2), B(4,1,-5), C(0,-1,3)$ គឺ៖

ក. $(1,1,0)$ ខ. $(3,3,0)$ គ. $(1,1,1)$ ឃ. $(0,1,1)$

៩៥. ចំណុច $M$ នៅលើអង្កត់ $[AB]$ ដែល $\overrightarrow{AM}=\frac{1}{2}\overrightarrow{MB}$ មានន័យថា៖

ក. $M$ ជាចំណុចកណ្តាលនៃ $[AB]$

ខ. $M$ ចែក $[AB]$ តាមផលធៀប $\frac{AM}{MB}=\frac{1}{2}$

គ. $A$ ជាចំណុចកណ្តាលនៃ $[MB]$

ឃ. $B$ ជាចំណុចកណ្តាលនៃ $[AM]$

៩៦. គេឱ្យ $A(1,2,3)$ និង $B(4,5,6)$។ ចំណុច $M$ ចែក $[AB]$ តាមផលធៀប $\overrightarrow{AM}=2\overrightarrow{MB}$ មានកូអរដោនេ៖

ក. $(3,4,5)$ ខ. $(2,3,4)$ គ. $(5,6,7)$ ឃ. $(2.5,3.5,4.5)$

៩៧. ទីប្រជុំទម្ងន់ $G$ នៃតេត្រាអែត $ABCD$ កំណត់ដោយរូបមន្ត៖

ក. $\vec{OG}=\frac{\vec{OA}+\vec{OB}+\vec{OC}+\vec{OD}}{4}$

ខ. $\vec{OG}=\frac{\vec{OA}+\vec{OB}+\vec{OC}+\vec{OD}}{3}$

គ. $\vec{OG}=\frac{\vec{OA}+\vec{OB}+\vec{OC}}{3}$

ឃ. $\vec{OG}=\vec{OA}+\vec{OB}+\vec{OC}+\vec{OD}$

៩៨. គេឱ្យ $A(1,0,1),B(0,2,1),C(2,1,0),D(1,1,2)$។ ទីប្រជុំទម្ងន់ $G$ នៃតេត្រាអែត $ABCD$ គឺ៖

ក. $(1,1,1)$ ខ. $(4,4,4)$ គ. $(2,2,2)$ ឃ. $(0.5,0.5,0.5)$

៩៩. ចំណុច $M$ ស្ថិតនៅលើប្លង់ $(Oxy)$ ស្មើចម្ងាយពីចំណុច $A(1,2,3)$ និង $B(1,2,-3)$ ៖

ក. គ្រប់ចំណុច $M(x,y,0)$ សុទ្ធតែស្មើចម្ងាយពី $A$ និង $B$

ខ. គ្មានចំណុចណាមួយឡើយ

គ. មានតែចំណុច $(1,2,0)$ មួយគត់

ឃ. មានតែគល់តម្រុយ $O(0,0,0)$ មួយគត់

១០០. ចំណុច $C$ ស្ថិតនៅលើអ័ក្ស $(Oz)$ ដែលស្មើចម្ងាយពី $A(2,-1,0)$ និង $B(0,1,2)$ មានកូអរដោនេ៖

ក. $(0,0,\frac{3}{4})$ ខ. $(0,0,\frac{1}{2})$ គ. $(0,0,1)$ ឃ. $(0,0,2)$

# លំហាត់អនុវត្តន៍

១. គេឲ្យ $\vec{u}=(4,-2,5)$ និង $\vec{v}=(7,9,-8)$។ រកវ៉ិចទ័រ $\vec{x}$ ដែលផ្ទៀងផ្ទាត់ទំនាក់ទំនងខាងក្រោម៖

ក. $2\vec{u}+\vec{x}=3\vec{v}$

ខ. $4\vec{x}-\vec{u}=3\vec{u}-4\vec{v}+2\vec{x}$។

## ដំណោះស្រាយ

២. គេឲ្យ $\vec{u}=(1,1,0), \vec{v}=(1,0,1), \vec{w}=(0,1,1)$ និង $\vec{p}=(5,6,7)$។
បង្ហាញថា $\vec{p}$ ជាទម្រង់ $\vec{p}=l\vec{u}+m\vec{v}+n\vec{w}$។

## ដំណោះស្រាយ

៣. រកទិសដៅកូស៊ីនុសនៃវ៉ិចទ័រខាងក្រោម៖

ក. $\vec{u} = (3, -4, 5)$

ខ. $\vec{v} = (-3, 2, 2\sqrt{3})$។

## ដំណោះស្រាយ

៤. គេឲ្យវ៉ិចទ័រ $\vec{u}=(2,-1,5), \vec{v}=(3x,5,4y-2)$ និង $\vec{w}=(z-1,2,z+1)$។

ក. រកតម្លៃ $x$ និង $y$ ដែល $\vec{u}\parallel\vec{v}$។

ខ. រកតម្លៃ $z$ ដែល $\vec{u}\perp\vec{w}$។

## ដំណោះស្រាយ

៥. រកតម្លៃ $x, y$ និង $z$ ដែលវ៉ិចទ័រ $\vec{u} = (x, 4, 6), \vec{v} = (2, y, 6)$ និង $\vec{w} = (2, 4, z)$ កែងគ្នា។

## ដំណោះស្រាយ

៦. គេឲ្យ $\vec{u}=(1,2,-3), \vec{v}=(2,-1,-2)$ និង $\vec{w}=(1,-3,1)$។ បើវ៉ិចទ័រ $\vec{x}=(x_1,x_2,x_3)$ អរតូកូណាល់នឹងវ៉ិចទ័រ $\vec{u},\vec{v}$ និង $\vec{w}$។ រក $x_1,x_2,x_3$ ដែល $\vec{x}\neq 0$។

## ដំណោះស្រាយ

៧. គេឲ្យ $\vec{u}=(2,-2,1)$ និង $\vec{v}=(2,3,-4)$។ តាង $\vec{v}-k\vec{u}=\vec{w}$ ដែល $k$ ជាចំនួនពិត។ បើ $\vec{w}$ និង $\vec{u}$ កែងគ្នា។ កំណត់តម្លៃ $k$ និង $\vec{w}$។

## ដំណោះស្រាយ

៨. គេឲ្យចំណុច $A(0,3,0), B(0,1,-2)$ និង $C(2,3,-2)$។ តើ $\triangle ABC$ ជាប្រភេទត្រីកោណអ្វី ?

## ដំណោះស្រាយ

៩. $(\vec{i},\vec{j},\vec{k})$ ជាគោលអរតូណរម៉ាល់មួយ។ គណនា $\vec{u}\cdot\vec{v},\vec{v}\cdot\vec{w},\vec{w}\cdot\vec{u}$ ក្នុងករណីនីមួយៗខាងក្រោម៖

ក. $\vec{u}=(1+\sqrt{2})\vec{i}+\sqrt{3}\vec{j},\vec{v}=(1-\sqrt{2})\vec{i}-\vec{k},\vec{w}=\sqrt{3}\vec{j}+\vec{k}$

ខ. $\vec{u}=\frac{2}{3}\vec{i}-\frac{1}{6}\vec{j}+\frac{1}{2}\vec{k},\vec{v}=\frac{1}{2}\vec{i}-2\vec{j}+\frac{2}{5}\vec{k},\vec{w}=\vec{i}+\vec{k}$

## ដំណោះស្រាយ




១០. $SABCD$ ជាពីរ៉ាមីតដែលមានបាតជាការេមានកំពូល $S$ និង ទ្រនុងមានរង្វាស់ $a$ ស្មើគ្នាទាំងអស់។ គណនាផលគុណស្កាលែខាងក្រោមនេះជាអនុគមន៍នៃ $a$ ៖

ក. $\overrightarrow{SA} \cdot \overrightarrow{SB}$

ខ. $\overrightarrow{SA} \cdot \overrightarrow{SC}$

គ. $\overrightarrow{SA} \cdot \overrightarrow{AC}$

## ដំណោះស្រាយ




១១. គេឱ្យរង្វង់ $(C)$ មានអង្កត់ផ្ចិត $[AB]$ នៅក្នុងប្លង់ $(\alpha)$។ បន្ទាត់ $(L)$ កែងប្លង់ $(\alpha)$ ត្រង់ $A$។ យក $P$ ជាចំណុចមួយនៅលើបន្ទាត់ $(L)$។ បង្ហាញថា ចំពោះគ្រប់ចំណុច $M \in (C)$ គេបាន $\overrightarrow{PM} \cdot \overrightarrow{MB} = 0$។

## ដំណោះស្រាយ




## ១ ផលគុណនៃពីរវ៉ិចទ័រក្នុងលំហ

**និយមន័យ ១**

ផលគុណនៃពីរវ៉ិចទ័រ $\vec{u}\,(u_x, u_y, u_z)$ និង $\vec{v}\,(v_x, v_y, v_z)$ គឺកំណត់ដោយ

$$\vec{u} \times \vec{v} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ u_x & u_y & u_z \\ v_x & v_y & v_z \end{vmatrix} = \begin{vmatrix} u_y & u_z \\ v_y & v_z \end{vmatrix} \vec{i} - \begin{vmatrix} u_x & u_z \\ v_x & v_z \end{vmatrix} \vec{j} + \begin{vmatrix} u_x & u_y \\ v_x & v_y \end{vmatrix} \vec{k}$$

$$= (u_y v_z - v_y u_z)\,\vec{i} - (u_x v_z - v_x u_z)\,\vec{j} + (u_x v_y - v_x u_y)\,\vec{k}$$




- $\vec{u} \times \vec{v}$ អរតូកូណាល់(កែង)ទៅនឹង $\vec{u}$ ផង និង $\vec{v}$ ផង
- $|\vec{u} \times \vec{v}| = |\vec{u}| \cdot |\vec{v}| \sin\theta$

- $\vec{u}\times\vec{v}=\vec{0}$ គេបាន $\vec{u}$ និង $\vec{v}$ ជាវ៉ិចទ័រកូលីនេអ៊ែរនឹងគ្នា (ស្របគ្នា)
- $A,B,C$ ជាបីចំណុចក្នុងលំហ៖
  - បើ $\left|\overrightarrow{AB}\times\overrightarrow{AC}\right|=0$ គេបាន ចំណុច $A,B,C$ ស្ថិតនៅលើបន្ទាត់តែមួយ
  - បើ $\left|\overrightarrow{AB}\times\overrightarrow{AC}\right|\neq 0$ គេបាន ចំណុច $A,B,C$ មិនស្ថិតនៅលើបន្ទាត់តែមួយ
- $|\vec{u}\times\vec{v}|=$ ផ្ទៃក្រឡាប្រលេឡូក្រាម
- $\frac{1}{2}|\vec{u}\times\vec{v}|=$ ផ្ទៃក្រឡាត្រីកោណ

## លំហាត់គំរូ ១

គេឱ្យ $\vec{u}=\vec{i}-2\vec{j}+\vec{k}$ និង $\vec{v}=3\vec{i}+\vec{j}-2\vec{k}$ ។ រកវ៉ិចទ័រ

ក. $\vec{u}\times\vec{v}$ ខ. $\vec{v}\times\vec{u}$ គ. $\vec{v}\times\vec{v}$

### ដំណោះស្រាយ

គេមាន $\vec{u}=\vec{i}-2\vec{j}+\vec{k}=(1,-2,1)$ និង $\vec{v}=3\vec{i}+\vec{j}-2\vec{k}=(3,1,-2)$ ៖

ក. រក $\vec{u}\times\vec{v}$ ៖

$$\vec{u}\times\vec{v}=\begin{vmatrix}\vec{i}&\vec{j}&\vec{k}\\1&-2&1\\3&1&-2\end{vmatrix}=\begin{vmatrix}-2&1\\1&-2\end{vmatrix}\vec{i}-\begin{vmatrix}1&1\\3&-2\end{vmatrix}\vec{j}+\begin{vmatrix}1&-2\\3&1\end{vmatrix}\vec{k}$$

$$=(4-1)\vec{i}-(-2-3)\vec{j}+(1-(-6))\vec{k}=3\vec{i}+5\vec{j}+7\vec{k}=(3,5,7)$$

ខ. រក $\vec{v}\times\vec{u}$ ៖

តាមលក្ខណៈត្រឡប់នៃផលគុណវ៉ិចទ័រ យើងបាន៖

$$\vec{v}\times\vec{u}=-(\vec{u}\times\vec{v})=-(3\vec{i}+5\vec{j}+7\vec{k})=-3\vec{i}-5\vec{j}-7\vec{k}=(-3,-5,-7)$$

គ. រក $\vec{v}\times\vec{v}$ ៖

ផលគុណនៃវ៉ិចទ័រមួយជាមួយខ្លួនវាផ្ទាល់ តែងតែស្មើនឹងវ៉ិចទ័រសូន្យ៖

$$\vec{v}\times\vec{v}=\vec{0}=(0,0,0)$$

**លំហាត់គំរូ ២**

គេឱ្យ $\overrightarrow{u}=\sqrt{2}\,\overrightarrow{i}+\sqrt{3}\,\overrightarrow{j}+2\overrightarrow{k}$ និង $\overrightarrow{v}=-\overrightarrow{i}+\overrightarrow{j}$។ គណនា $\overrightarrow{u}\times\overrightarrow{v}$ និង $\overrightarrow{v}\times\overrightarrow{v}$ រួចគណនា $|\overrightarrow{u}\times\overrightarrow{v}|$ និង $|\overrightarrow{v}\times\overrightarrow{v}|$ រួចធ្វើសេចក្ដីសន្និដ្ឋាន។

**ដំណោះស្រាយ**

គេមាន $\overrightarrow{u}=(\sqrt{2},\sqrt{3},2)$ និង $\overrightarrow{v}=(-1,1,0)$ ៖

- គណនា $\overrightarrow{u}\times\overrightarrow{v}$ ៖

$$\overrightarrow{u}\times\overrightarrow{v}=\begin{vmatrix}\overrightarrow{i} & \overrightarrow{j} & \overrightarrow{k}\\ \sqrt{2} & \sqrt{3} & 2\\ -1 & 1 & 0\end{vmatrix}=(0-2)\overrightarrow{i}-(0-(-2))\overrightarrow{j}+(\sqrt{2}-(-\sqrt{3}))\overrightarrow{k}$$

$$=-2\overrightarrow{i}-2\overrightarrow{j}+(\sqrt{2}+\sqrt{3})\overrightarrow{k}=(-2,-2,\sqrt{2}+\sqrt{3})$$

- គណនា $\overrightarrow{v}\times\overrightarrow{v}$ ៖

$$\overrightarrow{v}\times\overrightarrow{v}=\overrightarrow{0}=(0,0,0)$$

- គណនា $|\overrightarrow{u}\times\overrightarrow{v}|$ ៖

$$|\overrightarrow{u}\times\overrightarrow{v}|=\sqrt{(-2)^2+(-2)^2+(\sqrt{2}+\sqrt{3})^2}=\sqrt{4+4+(2+2\sqrt{6}+3)}=\sqrt{13+2\sqrt{6}}$$

- គណនា $|\overrightarrow{v}\times\overrightarrow{v}|$ ៖

$$|\overrightarrow{v}\times\overrightarrow{v}|=|\overrightarrow{0}|=0$$

- **សេចក្ដីសន្និដ្ឋាន៖**
  - ផលគុណនៃវ៉ិចទ័រមួយជាមួយខ្លួនវាផ្ទាល់ តែងតែស្មើនឹងវ៉ិចទ័រសូន្យ $\overrightarrow{v}\times\overrightarrow{v}=\overrightarrow{0}$ និងមានម៉ូឌុលស្មើ 0។
  - វ៉ិចទ័រ $\overrightarrow{u}\times\overrightarrow{v}$ ជាវ៉ិចទ័រមួយដែលកែង (អរតូកូណាល់) ទៅនឹងវ៉ិចទ័រទាំងពីរ $\overrightarrow{u}$ និង $\overrightarrow{v}$។

## ២ លក្ខណៈផលគុណនៃពីរវ៉ិចទ័រ

**ជាទូទៅ ១**

បើ $\vec{u}$; $\vec{v}$; $\vec{w}$ ជាវ៉ិចទ័រក្នុងលំហ ហើយ $c \in \mathbb{R}$ គេបាន៖

- $\vec{u} \times \vec{v} = -(\vec{v} \times \vec{u})$
- $\vec{u} \times (\vec{v} + \vec{w}) = (\vec{u} \times \vec{v}) + (\vec{u} \times \vec{w})$
- $c(\vec{u} \times \vec{v}) = (c\vec{u}) \times \vec{v} = \vec{u} \times (c\vec{v})$
- $\vec{u} \times \vec{0} = \vec{0} \times \vec{u} = \vec{0}$
- $\vec{u} \times \vec{u} = \vec{0}$
- $\vec{u} \cdot (\vec{v} \times \vec{w}) = (\vec{u} \times \vec{v}) \cdot \vec{w}$

## ៣ ផលគុណចម្រុះនៃបីវ៉ិចទ័រ

**ជាទូទៅ ២**

ផលគុណចម្រុះនៃបីវ៉ិចទ័រ $\vec{u}\,(u_x, u_y, u_z)$; $\vec{v}\,(v_x, v_y, v_z)$; $\vec{w}\,(w_x, w_y, w_z)$ គឺជាចំនួនពិតដែលកំណត់ដោយ

$$\vec{u} \cdot (\vec{v} \times \vec{w}) = \begin{vmatrix} u_x & u_y & u_z \\ v_x & v_y & v_z \\ w_x & w_y & w_z \end{vmatrix} = u_x \begin{vmatrix} v_y & v_z \\ w_y & w_z \end{vmatrix} - u_y \begin{vmatrix} v_x & v_z \\ w_x & w_z \end{vmatrix} + u_z \begin{vmatrix} v_x & v_y \\ w_x & w_y \end{vmatrix}$$

- បើ $\vec{u} \cdot (\vec{v} \times \vec{w}) = 0$ គេបាន $\vec{u}, \vec{v}, \vec{w}$ ស្ថិតក្នុងប្លង់តែមួយ
- បើ $\vec{u} \cdot (\vec{v} \times \vec{w}) \neq 0$ គេបាន $\vec{u}, \vec{v}, \vec{w}$ មិនស្ថិតក្នុងប្លង់តែមួយ ហើយទាញបាន៖
  - មាឌប្រលេពីប៉ែតសង់លើវ៉ិចទ័រ $\vec{u}, \vec{v}, \vec{w}$ គឺ $V = |\vec{u} \cdot (\vec{v} \times \vec{w})|$
  - មាឌតេត្រាអែតគឺ $V = \dfrac{|\vec{u} \cdot (\vec{v} \times \vec{w})|}{6}$ (តេត្រាអែត = ចតុមុខ)
- ចំពោះបួនចំណុច $A, B, C, D$ ក្នុងលំហ (មិនស្ថិតក្នុងប្លង់តែមួយ) គេបាន៖
  - មាឌប្រលេពីប៉ែតសង់លើវ៉ិចទ័រ $\overrightarrow{AB}, \overrightarrow{AC}, \overrightarrow{AD}$ គឺ $V = \left|\overrightarrow{AB} \cdot \left(\overrightarrow{AC} \times \overrightarrow{AD}\right)\right|$
  - មាឌតេត្រាអែត $ABCD$ គឺ $V_{ABCD} = \dfrac{\left|\overrightarrow{AB} \cdot \left(\overrightarrow{AC} \times \overrightarrow{AD}\right)\right|}{6}$
  - បើ $B$ ជាកំពូលនៃតេត្រាអែត និងបាតជាត្រីកោណ $ACD$ គេបាន៖

$$V_{ABCD} = \frac{1}{3} \cdot S_{\Delta ACD} \cdot h \implies h = d(B, (ACD)) = \frac{3V_{ABCD}}{S_{\Delta ACD}} = \frac{\left|\overrightarrow{AB} \cdot \left(\overrightarrow{AC} \times \overrightarrow{AD}\right)\right|}{\left\|\overrightarrow{AC} \times \overrightarrow{AD}\right\|}$$

## ៤ សំណួរពហុជ្រើសរើស (Multiple Choice Questions)

ចូរបញ្ជាក់ចម្លើយត្រឹមត្រូវតែមួយគត់ក្នុងចំណោមជម្រើស ក, ខ, គ, និង ឃ ៖

១. ក្នុងគោលអរតូណរម៉ាល់ $(\vec{i},\vec{j},\vec{k})$ ផលគុណ $\vec{i}\times\vec{j}$ ស្មើនឹង៖

ក. $\vec{k}$  ខ. $-\vec{k}$  គ. $\vec{0}$  ឃ. $1$

២. ផលគុណវ៉ិចទ័រ $\vec{j}\times\vec{i}$ ស្មើនឹង៖

ក. $\vec{k}$  ខ. $-\vec{k}$  គ. $\vec{0}$  ឃ. $-1$

៣. ផលគុណវ៉ិចទ័រ $\vec{j}\times\vec{k}$ ស្មើនឹង៖

ក. $-\vec{i}$  ខ. $\vec{i}$  គ. $\vec{0}$  ឃ. $1$

៤. ផលគុណវ៉ិចទ័រ $\vec{k}\times\vec{j}$ ស្មើនឹង៖

ក. $\vec{i}$  ខ. $\vec{0}$  គ. $-\vec{i}$  ឃ. $-1$

៥. ផលគុណវ៉ិចទ័រ $\vec{k}\times\vec{i}$ ស្មើនឹង៖

ក. $-\vec{j}$  ខ. $\vec{0}$  គ. $1$  ឃ. $\vec{j}$

៦. ផលគុណវ៉ិចទ័រ $\vec{i}\times\vec{k}$ ស្មើនឹង៖

ក. $-\vec{j}$  ខ. $\vec{j}$  គ. $\vec{0}$  ឃ. $-1$

៧. ផលគុណនៃវ៉ិចទ័រមួយជាមួយខ្លួនវាផ្ទាល់ $\vec{u}\times\vec{u}$ តែងតែស្មើនឹង៖

ក. $0$  ខ. $\vec{0}$  គ. $\|\vec{u}\|^2$  ឃ. $\vec{u}$

៨. ផលគុណវ៉ិចទ័រ $\vec{i}\times\vec{i}$ ស្មើនឹង៖

ក. $1$  ខ. $\vec{k}$  គ. $\vec{0}$  ឃ. $0$

៩. ផលគុណវ៉ិចទ័រនៃពីរវ៉ិចទ័រ $\vec{u}\times\vec{v}$ ជា៖

ក. ចំនួនពិត (ស្កាលែ)  ខ. ផ្ទៃក្រឡា

គ. មុំមួយ  ឃ. វ៉ិចទ័រមួយ

១០. វ៉ិចទ័រ $\vec{u}\times\vec{v}$ មានទិសដៅ៖

ក. កែងនឹង $\vec{u}$ ផង និងកែងនឹង $\vec{v}$ ផង  ខ. ស្របនឹង $\vec{u}$

គ. ស្របនឹង $\vec{v}$  ឃ. ស្ថិតក្នុងប្លង់កំណត់ដោយ $\vec{u}$ និង $\vec{v}$

១១. គេឱ្យ $\vec{u}=(1,0,0)$ និង $\vec{v}=(0,1,0)$។ វ៉ិចទ័រ $\vec{u}\times\vec{v}$ គឺ៖

ក. $(0,0,-1)$ ខ. $(0,0,1)$ គ. $(1,1,0)$ ឃ. $(0,0,0)$

១២. គេឱ្យ $\vec{u}=(2,0,0)$ និង $\vec{v}=(0,3,0)$។ វ៉ិចទ័រ $\vec{u}\times\vec{v}$ គឺ៖

ក. $(0,0,-6)$ ខ. $(6,0,0)$ គ. $(0,0,6)$ ឃ. $(0,6,0)$

១៣. គេឱ្យ $\vec{u}=(1,2,0)$ និង $\vec{v}=(0,0,1)$។ វ៉ិចទ័រ $\vec{u}\times\vec{v}$ គឺ៖

ក. $(-2,1,0)$ ខ. $(2,1,0)$ គ. $(0,0,2)$ ឃ. $(2,-1,0)$

១៤. គេឱ្យ $\vec{u}=(1,1,1)$ និង $\vec{v}=(1,1,1)$។ វ៉ិចទ័រ $\vec{u}\times\vec{v}$ គឺ៖

ក. $(0,0,0)$ ខ. $(1,1,1)$ គ. $(3,3,3)$ ឃ. $3$

១៥. គេឱ្យ $\vec{u}=(1,-1,2)$ និង $\vec{v}=(2,1,-1)$។ វ៉ិចទ័រ $\vec{u}\times\vec{v}$ គឺ៖

ក. $(1,-5,-3)$ ខ. $(-1,5,3)$ គ. $(-1,3,5)$ ឃ. $(3,5,-1)$

១៦. គេឱ្យ $\vec{u}=(2,-3,1)$ និង $\vec{v}=(1,-2,1)$។ វ៉ិចទ័រ $\vec{u}\times\vec{v}$ គឺ៖

ក. $(1,1,1)$ ខ. $(-1,1,-1)$ គ. $(-1,-1,-1)$ ឃ. $(1,-1,1)$

១៧. គេឱ្យ $\vec{u}=(3,2,-1)$ និង $\vec{v}=(1,0,2)$។ វ៉ិចទ័រ $\vec{u}\times\vec{v}$ គឺ៖

ក. $(4,7,-2)$ ខ. $(-4,7,2)$ គ. $(2,-7,-2)$ ឃ. $(4,-7,-2)$

១៨. គេឱ្យ $\vec{u}=(0,1,2)$ និង $\vec{v}=(3,-1,0)$។ វ៉ិចទ័រ $\vec{u}\times\vec{v}$ គឺ៖

ក. $(2,6,-3)$ ខ. $(-2,-6,3)$ គ. $(2,-6,-3)$ ឃ. $(-2,6,-3)$

១៩. ផលគុណស្កាលែ $(\vec{u}\times\vec{v})\cdot\vec{u}$ ស្មើនឹង៖

ក. $1$ ខ. $0$ គ. $\|\vec{u}\|^2$ ឃ. $\|\vec{u}\times\vec{v}\|$

២០. ផលគុណស្កាលែ $(\vec{u}\times\vec{v})\cdot\vec{v}$ ស្មើនឹង៖

ក. $1$ ខ. $\|\vec{v}\|^2$ គ. $0$ ឃ. $-\|\vec{v}\|^2$

២១. វ៉ិចទ័រមួយដែលកែងនឹង $\vec{u}=(1,0,0)$ និង $\vec{v}=(0,2,0)$ គឺ៖

ក. $(1,2,0)$ ខ. $(2,0,0)$ គ. $(0,1,0)$ ឃ. $(0,0,5)$

២២. វ៉ិចទ័រឯកតាដែលកែងនឹង $\vec{i}$ និង $\vec{j}$ គឺ៖

ក. $\pm\vec{k}$ ខ. $\vec{i}+\vec{j}$ គ. $\vec{0}$ ឃ. $\frac{\vec{i}+\vec{j}}{\sqrt{2}}$

២៣. គេឱ្យ $\vec{u}=(2,1,0)$ និង $\vec{v}=(0,1,2)$។ វ៉ិចទ័រ $\vec{u}\times\vec{v}$ គឺ៖

ក. $(-2,4,-2)$ ខ. $(2,-4,2)$ គ. $(2,4,2)$ ឃ. $(4,-2,2)$

២៤. ម៉ូឌុលនៃ $\vec{u}\times\vec{v}$ ដែល $\vec{u}=(2,0,0)$ និង $\vec{v}=(0,3,0)$ គឺ៖

ក. 5 ខ. 0 គ. 6 ឃ. 13

២៥. គេឱ្យ $\vec{u}=(1,1,0)$ និង $\vec{v}=(1,0,1)$។ វ៉ិចទ័រ $\vec{u}\times\vec{v}$ គឺៈ

ក. $(-1,1,1)$ ខ. $(1,1,-1)$ គ. $(0,1,1)$ ឃ. $(1,-1,-1)$

២៦. ម៉ូឌុលនៃ $\vec{u}\times\vec{v}$ ក្នុងសំណួរខាងលើគឺៈ

ក. $\sqrt{3}$ ខ. 3 គ. 1 ឃ. $\sqrt{2}$

២៧. គេឱ្យ $A(1,0,0), B(0,1,0), C(0,0,1)$។ វ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ គឺៈ

ក. $(-1,-1,-1)$ ខ. $(1,1,1)$ គ. $(1,-1,1)$ ឃ. $(0,0,1)$

២៨. គេឱ្យ $\vec{u}=(2,-1,3)$។ គណនា $\vec{u}\times(2\vec{u})$ ៖

ក. $2\|\vec{u}\|^2$ ខ. $(4,-2,6)$ គ. $\vec{0}$ ឃ. 2

២៩. បើ $\vec{u}\times\vec{v}=(3,-2,6)$ នោះ $\|\vec{u}\times\vec{v}\|$ ស្មើនឹងៈ

ក. 49 ខ. 11 គ. 5 ឃ. 7

៣០. បើ $\vec{u}\times\vec{v}=(0,4,-3)$ នោះ $\|\vec{u}\times\vec{v}\|$ ស្មើនឹងៈ

ក. 5 ខ. 7 គ. 25 ឃ. 1

៣១. បើ $\vec{u}\times\vec{v}=(1,2,2)$ នោះ $\vec{v}\times\vec{u}$ ស្មើនឹងៈ

ក. $(1,2,2)$ ខ. $(-1,-2,-2)$ គ. $(2,2,1)$ ឃ. $(0,0,0)$

៣២. គេឱ្យ $\vec{u}=3\vec{i}$ និង $\vec{v}=2\vec{k}$។ វ៉ិចទ័រ $\vec{u}\times\vec{v}$ គឺៈ

ក. $6\vec{j}$ ខ. $6\vec{i}$ គ. $-6\vec{j}$ ឃ. $5\vec{k}$

៣៣. គេឱ្យ $\vec{u}=-2\vec{j}$ និង $\vec{v}=4\vec{k}$។ វ៉ិចទ័រ $\vec{u}\times\vec{v}$ គឺៈ

ក. $8\vec{i}$ ខ. $-8\vec{j}$ គ. $2\vec{i}$ ឃ. $-8\vec{i}$

៣៤. វ៉ិចទ័រណរម៉ាល់នៃប្លង់កំណត់ដោយ $\vec{u}=(1,2,0)$ និង $\vec{v}=(0,1,1)$ គឺៈ

ក. $(2,-1,1)$ ខ. $(-2,1,-1)$ គ. $(2,1,1)$ ឃ. $(1,1,1)$

៣៥. វ៉ិចទ័រឯកតាណរម៉ាល់នៃប្លង់កំណត់ដោយ $\vec{i}$ និង $\vec{j}+\vec{k}$ គឺៈ

ក. $(0,-1,1)$ ខ. $\left(0,-\frac{1}{\sqrt{2}},\frac{1}{\sqrt{2}}\right)$ គ. $(1,1,1)$ ឃ. $(1,0,0)$

៣៦. លក្ខណៈត្រឹមត្រូវនៃផលគុណវ៉ិចទ័រគឺៈ

ក. $\vec{u}\times\vec{v}=\vec{v}\times\vec{u}$ ខ. $\vec{u}\times\vec{v}=\vec{u}\cdot\vec{v}$

គ. $-(\vec{v}\times\vec{u})=\vec{u}\times\vec{v}$ ឃ. $\vec{u}\times\vec{v}=\frac{\vec{u}}{\vec{v}}$

៣៧. ទំនាក់ទំនងរវាងម៉ូឌុលផលគុណវ៉ិចទ័រ និងមុំ $\theta$ គឺ៖

ក. $\|\vec{u}\times\vec{v}\| = \|\vec{u}\|\|\vec{v}\|\cos\theta$ ខ. $\|\vec{u}\times\vec{v}\| = \|\vec{u}\|\|\vec{v}\|\tan\theta$
គ. $\|\vec{u}\times\vec{v}\| = \frac{\|\vec{u}\|\|\vec{v}\|}{\sin\theta}$ ឃ. $\|\vec{u}\times\vec{v}\| = \|\vec{u}\|\|\vec{v}\|\sin\theta$

៣៨. លក្ខខណ្ឌចាំបាច់ និងគ្រប់គ្រាន់ដើម្បីឱ្យ $\vec{u} \parallel \vec{v}$ $(\vec{u},\vec{v}\neq\vec{0})$ គឺ៖

ក. $\vec{u}\times\vec{v}=\vec{0}$ ខ. $\vec{u}\cdot\vec{v}=0$ គ. $\vec{u}\times\vec{v}=1$ ឃ. $\|\vec{u}\| = \|\vec{v}\|$

៣៩. បើ $\vec{u} \parallel \vec{v}$ នោះ $\|\vec{u}\times\vec{v}\|$ ស្មើនឹង៖

ក. $1$ ខ. $0$ គ. $\|\vec{u}\|\|\vec{v}\|$ ឃ. $-1$

៤០. បើ $\vec{u} \perp \vec{v}$ នោះ $\|\vec{u}\times\vec{v}\|$ ស្មើនឹង៖

ក. $0$ ខ. $\frac{1}{2}\|\vec{u}\|\|\vec{v}\|$ គ. $\|\vec{u}\|\|\vec{v}\|$ ឃ. $1$

៤១. ផ្ទៃក្រឡាប្រលេឡូក្រាមដែលសង់លើពីរវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ កំណត់ដោយ៖

ក. $S=\frac{1}{2}\|\vec{u}\times\vec{v}\|$ ខ. $S=\vec{u}\cdot\vec{v}$
គ. $S=\|\vec{u}\|+\|\vec{v}\|$ ឃ. $S=\|\vec{u}\times\vec{v}\|$

៤២. ផ្ទៃក្រឡាត្រីកោណដែលសង់លើពីរវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ កំណត់ដោយ៖

ក. $S=\frac{1}{2}\|\vec{u}\times\vec{v}\|$ ខ. $S=\|\vec{u}\times\vec{v}\|$
គ. $S=\frac{1}{6}\|\vec{u}\times\vec{v}\|$ ឃ. $S=2\|\vec{u}\times\vec{v}\|$

៤៣. ផ្ទៃក្រឡាត្រីកោណ $ABC$ កំណត់ដោយរូបមន្ត៖

ក. $S=\|\overrightarrow{AB}\times\overrightarrow{AC}\|$ ខ. $S=\frac{1}{2}\|\overrightarrow{AB}\times\overrightarrow{AC}\|$
គ. $S=\frac{1}{6}\|\overrightarrow{AB}\times\overrightarrow{AC}\|$ ឃ. $S=\frac{1}{2}\overrightarrow{AB}\cdot\overrightarrow{AC}$

៤៤. បើ $\|\vec{u}\|=4, \|\vec{v}\|=5$ និងមុំរវាងវ៉ិចទ័រទាំងពីរគឺ $\theta=30^\circ$ នោះផ្ទៃប្រលេឡូក្រាមគឺ៖

ក. $20$ ខ. $10\sqrt{3}$ គ. $10$ ឃ. $5$

៤៥. បើ $\|\vec{u}\|=6, \|\vec{v}\|=8$ និងមុំ $\theta=30^\circ$ នោះផ្ទៃត្រីកោណសង់លើ $\vec{u}$ និង $\vec{v}$ គឺ៖

ក. $24$ ខ. $24\sqrt{3}$ គ. $48$ ឃ. $12$

៤៦. ផ្ទៃក្រឡាប្រលេឡូក្រាមដែលមានវិមាត្រ $\vec{u}=(2,0,0)$ និង $\vec{v}=(0,5,0)$ គឺ៖

ក. $10$ ខ. $5$ គ. $20$ ឃ. $7$

៤៧. ផ្ទៃក្រឡាត្រីកោណ $ABC$ ដែល $\overrightarrow{AB}\times\overrightarrow{AC}=(2,-2,1)$ គឺ៖

ក. $3$ ខ. $\frac{3}{2}$ គ. $9$ ឃ. $\frac{9}{2}$

៤៨. ផ្ទៃក្រឡាត្រីកោណ $ABC$ ដែល $\overrightarrow{AB}\times\overrightarrow{AC}=(0,6,8)$ គឺ៖

ក. 10 ខ. 14 គ. 5 ឃ. 7

៤៩. គេឱ្យ $A(1,1,0),B(3,1,0),C(1,4,0)$។ ផ្ទៃក្រឡាត្រីកោណ $ABC$ គឺ៖

ក. 6 ខ. 1.5 គ. 12 ឃ. 3

៥០. គេឱ្យ $A(0,0,0),B(2,0,0),C(0,3,0)$។ ផ្ទៃក្រឡាត្រីកោណ $ABC$ គឺ៖

ក. 3 ខ. 6 គ. 5 ឃ. 1.5

៥១. បីចំណុច $A,B,C$ រត់ត្រង់ជួរគ្នាកាលណា៖

ក. $\overrightarrow{AB}\cdot\overrightarrow{AC}=0$ ខ. $\overrightarrow{AB}\times\overrightarrow{AC}=\vec{0}$

គ. $\overrightarrow{AB}=\overrightarrow{AC}$ ឃ. $\|\overrightarrow{AB}\|=\|\overrightarrow{AC}\|$

៥២. គេឱ្យ $A(1,2,3),B(2,3,4),C(3,4,5)$។ វ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$ គឺ៖

ក. $(1,1,1)$ ខ. $(-1,2,-1)$ គ. $(0,0,0)$ ឃ. $(2,2,2)$

៥៣. ពីលទ្ធផលសំណួរខាងលើ បញ្ជាក់ថាបីចំណុច $A,B,C$ ៖

ក. បង្កើតបានត្រីកោណសម័ង្ស ខ. បង្កើតបានត្រីកោណកែង

គ. មិនរត់ត្រង់ជួរគ្នាទេ ឃ. រត់ត្រង់ជួរគ្នា

៥៤. កន្សោម $(\vec{u}\times\vec{v})+(\vec{v}\times\vec{u})$ ស្មើនឹង៖

ក. $\vec{0}$ ខ. $2(\vec{u}\times\vec{v})$ គ. 0 ឃ. 2

៥៥. កន្សោម $c(\vec{u}\times\vec{v})$ ស្មើនឹង៖

ក. $(c\vec{u})\times(c\vec{v})$ ខ. $(c\vec{u})\times\vec{v}=\vec{u}\times(c\vec{v})$

គ. $c^2(\vec{u}\times\vec{v})$ ឃ. $c\vec{u}\cdot\vec{v}$

៥៦. សមភាពឡាហ្គ្រង់ (Lagrange's Identity) គឺ៖

ក. $\|\vec{u}\times\vec{v}\|^2=\|\vec{u}\|^2\|\vec{v}\|^2+(\vec{u}\cdot\vec{v})^2$ ខ. $\|\vec{u}\times\vec{v}\|=\|\vec{u}\|\|\vec{v}\|-\vec{u}\cdot\vec{v}$

គ. $\|\vec{u}\times\vec{v}\|^2=\|\vec{u}\|^2\|\vec{v}\|^2-(\vec{u}\cdot\vec{v})^2$ ឃ. $\|\vec{u}\times\vec{v}\|^2=(\vec{u}\cdot\vec{v})^2$

៥៧. បើ $\|\vec{u}\|=3,\|\vec{v}\|=5$ និង $\vec{u}\cdot\vec{v}=9$ នោះ $\|\vec{u}\times\vec{v}\|$ ស្មើនឹង៖

ក. 144 ខ. 6 គ. 15 ឃ. 12

៥៨. បើ $\|\vec{u}\|=2,\|\vec{v}\|=4$ និង $\vec{u}\cdot\vec{v}=0$ នោះ $\|\vec{u}\times\vec{v}\|$ ស្មើនឹង៖

ក. 8 ខ. 0 គ. 6 ឃ. 16

៥៩. បើ $\|\vec{u}\times\vec{v}\|=6$ និង $\vec{u}\cdot\vec{v}=8$ នោះ $\|\vec{u}\|\|\vec{v}\|$ ស្មើនឹង៖

ក. 14 ខ. 10 គ. 100 ឃ. 48

៦០. គេឱ្យ $\vec{u}\times\vec{v}=\vec{w}$។ ផលគុណស្កាលែ $\vec{w}\cdot\vec{u}+\vec{w}\cdot\vec{v}$ ស្មើនឹង៖

ក. 2 ខ. $\|\vec{w}\|^2$ គ. 0 ឃ. 1

៦១. បើ $\vec{u}\times\vec{v}=\vec{0}$ និង $\vec{u}\cdot\vec{v}=0$ ដោយ $\vec{u}\neq\vec{0}$ នោះគេទាញបាន៖

ក. $\vec{u}=\vec{v}$ ខ. $\|\vec{u}\|=\|\vec{v}\|$ គ. $\vec{u}\perp\vec{v}$ ឃ. $\vec{v}=\vec{0}$

៦២. ផ្ទៃក្រឡាប្រលេឡូក្រាម $ABCD$ មានកំពូល $A(0,0,0),B(1,2,0),D(0,1,3)$ គឺ៖

ក. $\sqrt{46}$ ខ. 7 គ. 6 ឃ. $\sqrt{41}$

៦៣. ក្នុងត្រីកោណ $ABC$ កម្ពស់ $h_A$ គូសចេញពីកំពូល $A$ មកជ្រុង $BC$ កំណត់ដោយ៖

ក. $h_A=\frac{2\|\overrightarrow{AB}\times\overrightarrow{AC}\|}{\|\overrightarrow{BC}\|}$ ខ. $h_A=\frac{\|\overrightarrow{AB}\times\overrightarrow{AC}\|}{\|\overrightarrow{BC}\|}$

គ. $h_A=\frac{\|\overrightarrow{AB}\cdot\overrightarrow{AC}\|}{\|\overrightarrow{BC}\|}$ ឃ. $h_A=\frac{\|\overrightarrow{AB}\times\overrightarrow{AC}\|}{2\|\overrightarrow{BC}\|}$

៦៤. បើ $\overrightarrow{AB}\times\overrightarrow{AC}=(4,0,3)$ និង $\|\overrightarrow{BC}\|=5$ នោះកម្ពស់ $h_A$ ស្មើនឹង៖

ក. 5 ខ. 2 គ. 1 ឃ. 0.5

៦៥. ផ្ទៃក្រឡាពហុកោណប៉ោងមួយអាចគណនាបានដោយ៖

ក. យកផលគុណជ្រុងទាំងអស់ ខ. គណនាផលបូកប្រវែងទ្រនុងទាំងអស់

គ. គ្មានរូបមន្តគណនាទេ ឃ. បំបែកពហុកោណជាបណ្តាត្រីកោណ រួចបូកផ្ទៃក្រឡាត្រីកោណទាំងនោះ

៦៦. ផលគុណចម្រុះនៃបីវ៉ិចទ័រ $\vec{u},\vec{v},\vec{w}$ គឺកំណត់ដោយ៖

ក. $\vec{u}\cdot(\vec{v}\times\vec{w})$ ខ. $\vec{u}\times(\vec{v}\cdot\vec{w})$

គ. $(\vec{u}\cdot\vec{v})\times\vec{w}$ ឃ. $(\vec{u}+\vec{v})\times\vec{w}$

៦៧. ផលគុណចម្រុះនៃបីវ៉ិចទ័រផ្តល់លទ្ធផលជា៖

ក. វ៉ិចទ័រ ខ. ចំនួនពិត (ស្កាលែ)

គ. ម៉ាទ្រីស ឃ. មុំ

៦៨. ផលគុណចម្រុះ $\vec{i}\cdot(\vec{j}\times\vec{k})$ ស្មើនឹង៖

ក. 0 ខ. $-1$ គ. 1 ឃ. $\vec{i}$

៦៩. ផលគុណចម្រុះ $\vec{j}\cdot(\vec{i}\times\vec{k})$ ស្មើនឹង៖

ក. 1 ខ. 0 គ. $\vec{j}$ ឃ. $-1$

៧០. ផលគុណចម្រុះ $\vec{u}\cdot(\vec{u}\times\vec{v})$ តែងតែស្មើនឹង៖

ក. 0 ខ. 1 គ. $\|\vec{u}\|^2$ ឃ. $\|\vec{u}\times\vec{v}\|$

៧១. ផលគុណចម្រុះ $\vec{u}\cdot(\vec{v}\times\vec{u})$ ស្មើនឹង៖

ក. $-1$ ខ. 0 គ. 1 ឃ. $\|\vec{u}\|^2$

៧២. លក្ខខណ្ឌចាំបាច់ និងគ្រប់គ្រាន់ដើម្បីឱ្យបីវ៉ិចទ័រ $\vec{u},\vec{v},\vec{w}$ ស្ថិតក្នុងប្លង់តែមួយ (កូប្លាណែ) គឺ៖

ក. $\vec{u}\cdot(\vec{v}\times\vec{w})=1$ ខ. $\vec{u}\times(\vec{v}\times\vec{w})=\vec{0}$

គ. $\vec{u}\cdot(\vec{v}\times\vec{w})=0$ ឃ. $\vec{u}+\vec{v}+\vec{w}=\vec{0}$

៧៣. លក្ខខណ្ឌដើម្បីឱ្យបួនចំណុច $A,B,C,D$ ស្ថិតក្នុងប្លង់តែមួយ (កូប្លាណែ) គឺ៖

ក. $\overrightarrow{AB}\times\overrightarrow{AC}=\overrightarrow{AD}$ ខ. $\overrightarrow{AB}\cdot\overrightarrow{AC}=0$

គ. $\|\overrightarrow{AB}\|+\|\overrightarrow{AC}\|=\|\overrightarrow{AD}\|$ ឃ. $\overrightarrow{AB}\cdot(\overrightarrow{AC}\times\overrightarrow{AD})=0$

៧៤. គេឱ្យ $\vec{u}=(1,0,0),\vec{v}=(0,2,0),\vec{w}=(0,0,3)$។ ផលគុណចម្រុះ $\vec{u}\cdot(\vec{v}\times\vec{w})$ គឺ៖

ក. 6 ខ. 5 គ. 0 ឃ. $-6$

៧៥. មាឌប្រលេពីប៉ែតដែលសង់លើបីវ៉ិចទ័រ $\vec{u},\vec{v},\vec{w}$ គឺ៖

ក. $V=\frac{1}{6}|\vec{u}\cdot(\vec{v}\times\vec{w})|$ ខ. $V=|\vec{u}\cdot(\vec{v}\times\vec{w})|$

គ. $V=\frac{1}{3}|\vec{u}\cdot(\vec{v}\times\vec{w})|$ ឃ. $V=\vec{u}\cdot(\vec{v}\times\vec{w})$

៧៦. មាឌតេត្រាអែត (ចតុមុខ) ដែលសង់លើបីវ៉ិចទ័រ $\vec{u},\vec{v},\vec{w}$ គឺ៖

ក. $V=|\vec{u}\cdot(\vec{v}\times\vec{w})|$ ខ. $V=\frac{1}{3}|\vec{u}\cdot(\vec{v}\times\vec{w})|$

គ. $V=\frac{1}{6}|\vec{u}\cdot(\vec{v}\times\vec{w})|$ ឃ. $V=\frac{1}{2}|\vec{u}\cdot(\vec{v}\times\vec{w})|$

៧៧. មាឌតេត្រាអែត $ABCD$ កំណត់ដោយរូបមន្ត៖

ក. $V=|\overrightarrow{AB}\cdot(\overrightarrow{AC}\times\overrightarrow{AD})|$ ខ. $V=\frac{1}{3}|\overrightarrow{AB}\cdot(\overrightarrow{AC}\times\overrightarrow{AD})|$

គ. $V=\frac{1}{4}|\overrightarrow{AB}\cdot(\overrightarrow{AC}\times\overrightarrow{AD})|$ ឃ. $V=\frac{1}{6}|\overrightarrow{AB}\cdot(\overrightarrow{AC}\times\overrightarrow{AD})|$

៧៨. ផលធៀបរវាងមាឌតេត្រាអែត និងមាឌប្រលេពីប៉ែតដែលសង់លើវ៉ិចទ័រដូចគ្នា គឺស្មើនឹង៖

ក. $\frac{1}{6}$ ខ. $\frac{1}{3}$ គ. $\frac{1}{2}$ ឃ. 6

៧៩. គណនាមាឌប្រលេពីប៉ែតសង់លើ $\vec{u}=(1,1,0),\vec{v}=(0,1,1),\vec{w}=(1,0,1)$ ៖

ក. 1 ខ. 2 គ. 4 ឃ. 6

៨០. គណនាមាឌតេត្រាអែតសង់លើ $\vec{u}=(1,1,0), \vec{v}=(0,1,1), \vec{w}=(1,0,1)$ ៖

ក. $\frac{1}{6}$ ខ. $1$ គ. $\frac{1}{3}$ ឃ. $2$

៨១. គេឱ្យ $\vec{u}=(2,0,0), \vec{v}=(0,3,0), \vec{w}=(0,0,4)$។ មាឌតេត្រាអែតគឺ៖

ក. $24$ ខ. $8$ គ. $12$ ឃ. $4$

៨២. គេឱ្យ $A(0,0,0), B(1,0,0), C(0,2,0), D(0,0,3)$។ មាឌតេត្រាអែត $ABCD$ គឺ៖

ក. $1$ ខ. $6$ គ. $2$ ឃ. $3$

៨៣. គេឱ្យ $\vec{u}=(1,2,3), \vec{v}=(2,4,6), \vec{w}=(1,0,1)$។ ផលគុណចម្រុះ $\vec{u}\cdot(\vec{v}\times\vec{w})$ គឺ៖

ក. $6$ ខ. $0$ (ព្រោះ $\vec{v}=2\vec{u}$) គ. $12$ ឃ. $-6$

៨៤. គេឱ្យ $\vec{u}=(1,-1,1), \vec{v}=(2,0,1), \vec{w}=(3,-1,2)$។ ផលគុណចម្រុះ $\vec{u}\cdot(\vec{v}\times\vec{w})$ គឺ៖

ក. $1$ ខ. $2$ គ. $0$ (ព្រោះ $\vec{w}=\vec{u}+\vec{v}$) ឃ. $-1$

៨៥. គេឱ្យ $\vec{u}=(1,1,m), \vec{v}=(0,2,1), \vec{w}=(3,1,0)$។ រក $m$ ដើម្បីឱ្យវ៉ិចទ័រទាំងបីកូប្លាណែ៖

ក. $m=1$ ខ. $m=-\frac{1}{3}$ គ. $m=3$ ឃ. $m=\frac{1}{3}$

៨៦. គេឱ្យ $A(1,0,1), B(2,1,0), C(0,1,2), D(k,1,1)$។ រក $k$ ដើម្បីឱ្យ $A,B,C,D$ ស្ថិតក្នុងប្លង់តែមួយ៖

ក. $k=1$ ខ. $k=2$ គ. $k=0$ ឃ. $k=-1$

៨៧. ទំនាក់ទំនងវដ្តនៃផលគុណចម្រុះគឺ៖

ក. $\vec{u}\cdot(\vec{v}\times\vec{w})=-\vec{v}\cdot(\vec{w}\times\vec{u})$

ខ. $\vec{u}\cdot(\vec{v}\times\vec{w})=\vec{v}\cdot(\vec{w}\times\vec{u})=\vec{w}\cdot(\vec{u}\times\vec{v})$

គ. $\vec{u}\cdot(\vec{v}\times\vec{w})=\vec{u}\cdot(\vec{w}\times\vec{v})$

ឃ. $\vec{u}\cdot(\vec{v}\times\vec{w})=0$

៨៨. ប្តូរទីតាំងវ៉ិចទ័រពីរជាប់គ្នា $(\vec{u}\cdot(\vec{w}\times\vec{v}))$ នាំឱ្យលទ្ធផល៖

ក. ស្មើគ្នានឹង $\vec{u}\cdot(\vec{v}\times\vec{w})$

ខ. ស្មើនឹង $0$

គ. ផ្ទុយសញ្ញានឹង $\vec{u}\cdot(\vec{v}\times\vec{w})$

ឃ. មិនអាចកំណត់បាន

៨៩. កម្ពស់ $h$ នៃតេត្រាអែត $ABCD$ ចេញពីកំពូល $A$ មកបាត $BCD$ កំណត់ដោយ៖

ក. $h=\frac{V_{ABCD}}{S_{\triangle BCD}}$

ខ. $h=\frac{6V_{ABCD}}{S_{\triangle BCD}}$

គ. $h=\frac{3V_{ABCD}}{\|\overrightarrow{AB}\|}$

ឃ. $h=\frac{3V_{ABCD}}{S_{\triangle BCD}}=\frac{|\overrightarrow{AB}\cdot(\overrightarrow{AC}\times\overrightarrow{AD})|}{\|\overrightarrow{BC}\times\overrightarrow{BD}\|}$

៩០. បើ $V_{ABCD}=6$ និង $S_{\triangle BCD}=3$ នោះកម្ពស់ $h$ ចេញពីកំពូល $A$ ស្មើនឹង៖

ក. $6$ ខ. $2$ គ. $18$ ឃ. $3$

៩១. បើ $V_{ABCD}=10$ និង $h=5$ នោះផ្ទៃក្រឡាបាត $S$ ស្មើនឹង៖

ក. 2 ខ. 6 គ. 50 ឃ. 15

៩២. មាឌតេត្រាអែត $OABC$ ដែល $A(a,0,0), B(0,b,0), C(0,0,c)$ គឺ៖

ក. $V=\frac{1}{3}|abc|$ ខ. $V=|abc|$ គ. $V=\frac{1}{6}|abc|$ ឃ. $V=\frac{1}{2}|abc|$

៩៣. ពីសំណួរខាងលើ បើ $a=3, b=4, c=5$ នោះមាឌតេត្រាអែត $OABC$ ស្មើនឹង៖

ក. 60 ខ. 20 គ. 30 ឃ. 10

៩៤. បើប្រលេពីប៉ែតមួយមានមាឌស្មើនឹង 48 នោះតេត្រាអែតសង់លើវិមាត្រទាំងបីដូចគ្នានឹងមានមាឌស្មើ៖

ក. 8 ខ. 16 គ. 24 ឃ. 4

៩៥. ចំណុច $A, B, C, D$ មិនស្ថិតក្នុងប្លង់តែមួយកាលណា៖

ក. $\overrightarrow{AB}\cdot(\overrightarrow{AC}\times\overrightarrow{AD})=0$ ខ. $\overrightarrow{AB}\cdot(\overrightarrow{AC}\times\overrightarrow{AD})\neq 0$

គ. $\overrightarrow{AB}\times\overrightarrow{AC}=\vec{0}$ ឃ. $\overrightarrow{AB}\cdot\overrightarrow{AC}=0$

៩៦. ក្នុងប្រលេពីប៉ែត $ABCD.A'B'C'D'$ ដែលមានបាត $ABCD$ និងកំពូល $A'$ មាឌរបស់វាគឺ៖

ក. $V=\frac{1}{6}|\overrightarrow{AA'}\cdot(\overrightarrow{AB}\times\overrightarrow{AD})|$ ខ. $V=\frac{1}{3}|\overrightarrow{AA'}\cdot(\overrightarrow{AB}\times\overrightarrow{AD})|$

គ. $V=|\overrightarrow{AA'}\cdot(\overrightarrow{AB}\times\overrightarrow{AD})|$ ឃ. $V=\|\overrightarrow{AB}\times\overrightarrow{AD}\|$

៩៧. ដេទែមីណង់លំដាប់ ៣ នៃផលគុណចម្រុះ $\begin{vmatrix}1&2&3\\0&1&4\\0&0&2\end{vmatrix}$ ស្មើនឹង៖

ក. 0 ខ. 6 គ. 24 ឃ. 2

៩៨. បើ $\vec{u},\vec{v},\vec{w}$ បង្កើតបានជាគោលអរតូណរម៉ាល់វិជ្ជមាន នោះ $\vec{u}\cdot(\vec{v}\times\vec{w})$ ស្មើនឹង៖

ក. 1 ខ. $-1$ គ. 0 ឃ. 3

៩៩. បើ $\vec{u},\vec{v},\vec{w}$ បង្កើតបានជាគោលអរតូណរម៉ាល់អវិជ្ជមាន នោះ $\vec{u}\cdot(\vec{v}\times\vec{w})$ ស្មើនឹង៖

ក. 1 ខ. $-1$ គ. 0 ឃ. $-3$

១០០. ផលគុណចម្រុះ $\vec{u}\cdot(\vec{v}\times\vec{w})=0$ មានន័យធរណីមាត្រថា៖

ក. បីវ៉ិចទ័រនោះមានប្រវែងស្មើគ្នា ខ. បីវ៉ិចទ័រនោះកែងគ្នាពីរៗ

គ. បីវ៉ិចទ័រនោះកូប្លាណែ (ស្ថិតក្នុងប្លង់តែមួយ) ឃ. បីវ៉ិចទ័រនោះជាគោលអរតូណរម៉ាល់

# លំហាត់អនុវត្តន៍

១. រកផលគុណនៃវ៉ិចទ័រ រួចគូសរូបតាង

ក. $\vec{j}\times\vec{i}$ ខ. $\vec{i}\times\vec{j}$ គ. $\vec{j}\times\vec{k}$ ឃ. $\vec{k}\times\vec{j}$ ង. $\vec{i}\times\vec{k}$ ច. $\vec{k}\times\vec{i}$

## ដំណោះស្រាយ

២. រក $\vec{u}\times\vec{v}$ ហើយបង្ហាញថា $\vec{u}\times\vec{v}$ អរត្តូកូណាល់ទៅនឹង $\vec{u}$ ផង និង $\vec{v}$ ផង ក្នុងករណីនីមួយៗខាងក្រោម៖

ក. $\vec{u}=(2,-3,1),\vec{v}=(1,-2,1)$

ខ. $\vec{u}=(-1,1,2),\vec{v}=(0,1,0)$

គ. $\vec{u}=(12,-3,0),\vec{v}=(-2,5,0)$

ឃ. $\vec{u}=(-10,0,6),\vec{v}=(7,0,0)$

ង. $\vec{u}=(1,1,1),\vec{v}=(2,1,-1)$

ច. $\vec{u}=(0,1,6),\vec{v}=(1,-2,1)$

## ដំណោះស្រាយ

៣. រក $\vec{u}\times\vec{v}$ ហើយបង្ហាញថា $\vec{u}\times\vec{v}$ អរត្តូកូណាល់ទៅនឹង $\vec{u}$ ផង និង $\vec{v}$ ផង ក្នុងករណីនីមួយៗខាងក្រោម៖

ក. $\vec{u}=(4,-3.5,7),\vec{v}=(-1,8,4)$

ខ. $\vec{u}=(-8,-6,4),\vec{v}=(10,-12,-2)$

គ. $\vec{u}=-3\vec{i}+2\vec{j}-5\vec{k},\vec{v}=\frac{1}{2}\vec{i}-\frac{3}{4}\vec{j}+\frac{1}{10}\vec{k}$

ឃ. $\vec{u}=\frac{2}{3}\vec{k},\vec{v}=\frac{1}{2}\vec{i}+6\vec{j}$

## ដំណោះស្រាយ

៤. រកផ្ទៃប្រលេឡូក្រាមដែលមានវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ជាជ្រុងជាប់ក្នុងករណីនីមួយៗខាងក្រោម៖

ក. $\vec{u}=\vec{j}, \vec{v}=\vec{j}+\vec{k}$

ខ. $\vec{u}=\vec{i}+\vec{j}+\vec{k}, \vec{v}=\vec{j}+\vec{k}$

គ. $\vec{u}=(3,2,-1), \vec{v}=(1,2,3)$

ឃ. $\vec{u}=(2,-1,0), \vec{v}=(-1,2,0)$

## ដំណោះស្រាយ

៥. ផ្ទៀងផ្ទាត់ចំណុចខាងក្រោម ជាកំពូលរបស់ប្រលេឡូក្រាមរួចរកផ្ទៃក្រឡា៖

ក. $(1,1,1),(2,3,4),(6,5,2),(7,7,5)$ ខ. $(2,-1,1),(5,1,4),(0,1,1),(3,3,4)$

## ដំណោះស្រាយ

៦. រកផ្ទៃក្រឡាត្រីកោណ ដែលមានកំពូលដូចខាងក្រោម៖

ក. $(0,0,0),(1,2,3),(-3,0,0)$

គ. $(1,3,5),(3,3,0),(-2,0,5)$

ខ. $(2,-3,4),(0,1,2),(-1,2,0)$

ឃ. $(1,2,0),(-2,1,0),(0,0,0)$

## ដំណោះស្រាយ

៧. រក $\vec{u}\cdot(\vec{v}\times\vec{w})$ ក្នុងករណីនីមួយៗខាងក្រោម៖

ក. $\vec{u}=\vec{i},\vec{v}=\vec{j},\vec{w}=\vec{k}$

គ. $\vec{u}=(2,0,1),\vec{v}=(0,3,0),\vec{w}=(0,0,1)$

ខ. $\vec{u}=(1,1,1),\vec{v}=(2,1,0),\vec{w}=(0,0,1)$

ឃ. $\vec{u}=(2,0,0),\vec{v}=(1,1,1),\vec{w}=(0,2,2)$

## ដំណោះស្រាយ

៨. ដោយប្រើផលគុណចម្រុះនៃបីវ៉ិចទ័រក្នុងលំហ ចូរគណនាមាឌប្រលេពីប៉ែតដែលមានវ៉ិចទ័រ $\vec{u},\vec{v}$ និង $\vec{w}$ ជាជ្រុងជាប់ដូចខាងក្រោម៖

ក. $\vec{u}=\vec{i}+\vec{j},\vec{v}=\vec{j}+\vec{k},\vec{w}=\vec{i}+\vec{k}$

ខ. $\vec{u}=(1,3,1),\vec{v}=(0,5,5),\vec{w}=(4,0,4)$

## ដំណោះស្រាយ

៩. រកមាឌប្រលេពីប៉ែតដែលមានកំពូលដូចខាងក្រោម៖

ក. $(0,0,0),(3,0,0),(0,5,1),(3,5,1),(2,0,5),(5,0,5),(2,5,6),(5,5,6)$

ខ. $(0,0,0),(1,1,0),(1,0,2),(0,1,1),(2,1,2),(1,1,3),(1,2,1),(2,2,3)$

## ដំណោះស្រាយ




# មេរៀនទី៣ អនុវត្តន៍នៃផលគុណវិចទ័រ

## ១ ចម្ងាយរវាងពីរចំណុច

**ជាទូទៅ ១**

គេមានចំណុច $A(x_1,y_1,z_1)$; $B(x_2,y_2,z_2)$ គេបានចម្ងាយ ពី $A$ ទៅ $B$ គឺកំណត់ដោយ

$$d(A,B)=AB=\left|\overrightarrow{AB}\right|=\sqrt{(x_2-x_1)^2+(y_2-y_1)^2+(z_2-z_1)^2}$$




## ២ សមីការបន្ទាត់ក្នុងលំហ

# ៣ សមីការបន្ទាត់កាត់តាមមួយចំណុច និងស្គាល់វ៉ិចទ័រប្រាប់ទិស

## និយមន័យ ១

- សមីការបន្ទាត់ $L$ ដែលកាត់តាមចំណុច $A(x_o,y_o,z_o)$ ហើយស្របទៅនឹងវ៉ិចទ័រប្រាប់ទិស $\vec{u}=(a,b,c)$ គឺកំណត់ដោយ

$$(L):\begin{cases} x-x_o=at \\ y-y_o=bt \\ z-z_o=ct \end{cases} \quad ;t\in\mathbb{R}$$




សមីការខាងលើនេះ គេហៅថា **សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់** $(L)$

- បើ $a\neq 0;\ b\neq 0;\ c\neq 0$ គេអាចសរសេរសមីការបន្ទាត់ $(L)$ ជា

$$(L):\ \frac{x-x_o}{a}=\frac{y-y_o}{b}=\frac{z-z_o}{c}$$

គេហៅទម្រង់នេះថាជា **សមីការឆ្លុះនៃបន្ទាត់** $(L)$

## លំហាត់គំរូ ១

រកសមីការបន្ទាត់ដែលកាត់តាមចំណុច $A(1,-2,3)$ និងមានវ៉ិចទ័រប្រាប់ទិស $\vec{u}=(-1,2,-3)$

### ដំណោះស្រាយ

បន្ទាត់កាត់តាមចំណុច $A(x_0,y_0,z_0)=(1,-2,3)$ និងមានវ៉ិចទ័រប្រាប់ទិស $\vec{u}=(a,b,c)=(-1,2,-3)$ ៖

- **សមីការឆ្លុះ៖**

$$\frac{x-x_0}{a}=\frac{y-y_0}{b}=\frac{z-z_0}{c}\iff\frac{x-1}{-1}=\frac{y+2}{2}=\frac{z-3}{-3}$$

- សមីការប៉ារ៉ាម៉ែត្រ៖

$$\begin{cases} x = 1 - t \\ y = -2 + 2t \\ z = 3 - 3t \end{cases} \qquad (t \in \mathbb{R})$$

## ៤ សមីការបន្ទាត់កាត់តាមពីរចំណុចក្នុងលំហ

**ជាទូទៅ ២**

សមីការបន្ទាត់ដែលកាត់តាមចំណុច $A(x_o, y_o, z_o)$ និង $B(x_1, y_1, z_1)$ កំណត់ដោយ

$$(AB): \quad \frac{x - x_o}{x_1 - x_o} = \frac{y - y_o}{y_1 - y_o} = \frac{z - z_o}{z_1 - z_o}$$




**លំហាត់គំរូ ២**

រកសមីការបន្ទាត់ $(AB)$ កាត់តាមចំណុច $A(-2, 1, -3)$ និង $B(3, -2, -1)$ ។

**ដំណោះស្រាយ**

បន្ទាត់ $(AB)$ កាត់តាម $A(-2, 1, -3)$ និង $B(3, -2, -1)$ ៖

- វ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(AB)$ គឺ៖

$$\vec{u} = \overrightarrow{AB} = (3 - (-2), -2 - 1, -1 - (-3)) = (5, -3, 2)$$

- សមីការឆ្លុះនៃបន្ទាត់ $(AB)$៖

$$(AB):\frac{x-(-2)}{5}=\frac{y-1}{-3}=\frac{z-(-3)}{2}\iff\frac{x+2}{5}=\frac{y-1}{-3}=\frac{z+3}{2}$$

- សមីការប៉ារ៉ាម៉ែត្រ៖

$$\begin{cases}x=-2+5t\\ y=1-3t\\ z=-3+2t\end{cases}\qquad(t\in\mathbb{R})$$

## ៥ សមីការបន្ទាត់ដែលកំណត់ដោយប្លង់ពីរប្រសព្វគ្នា

គេឱ្យ សមីការប្លង់ $(P_1):a_1x+b_1y+c_1z+d_1=0$ និងសមីការប្លង់ $(P_2):a_2x+b_2y+c_2z+d_2=0$ ដែលមានវ៉ិចទ័រណរម៉ាល់រៀងគ្នា $\vec{n_1}=(a_1,b_1,c_1)$ និង $\vec{n_2}=(a_2,b_2,c_2)$ ។ បើវ៉ិចទ័រ $\vec{n_1}=(a_1,b_1,c_1)$ និង $\vec{n_2}=(a_2,b_2,c_2)$ មិនកូលីនេអ៊ែរគ្នា( មិនស្របគ្នា ) នោះប្លង់ $(P_1)$ និង $(P_2)$ ប្រសព្វគ្នាបានបន្ទាត់ $(L)$ មួយ។
ដើម្បីរកសមីការបន្ទាត់ $(L)$ គេត្រូវ៖

- យក $z=t$ (ឬយក $x,y$ ) ជំនួសក្នុងសមីការ $(P_1)$ និង $(P_2)$
- ដោះស្រាយប្រព័ន្ធសមីការ $\begin{cases}a_1x+b_1y+c_1z+d_1=0\\ a_2x+b_2y+c_2z+d_2=0\end{cases}$
- រកទំនាក់ទំនងគ្មាន $t$ រវាង $x,y,z$ នោះគេទទួលបាន សមីការឆ្លុះរបស់បន្ទាត់ $(L)$
- វ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(L)$ គឺ $\vec{u}=\vec{n_1}\times\vec{n_2}$

**លំហាត់គំរូ ៣**

គេឱ្យប្លង់ពីរ $(P):x+2y+5z-2=0$ និង $(Q):2x-2y+z-1=0$ ។ ចូររកសមីការបន្ទាត់ $(L)$ កំណត់ដោយប្លង់ទាំងពីរខាងលើប្រសព្វគ្នា។

**ដំណោះស្រាយ**

- វ៉ិចទ័រណរម៉ាល់នៃប្លង់ទាំងពីរគឺ $\vec{n_1}=(1,2,5)$ និង $\vec{n_2}=(2,-2,1)$។

- វ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ប្រសព្វ $(L)$ គឺ៖

$$\vec{u}=\vec{n_1}\times\vec{n_2}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & 2 & 5\\ 2 & -2 & 1\end{vmatrix}=(2-(-10))\vec{i}-(1-10)\vec{j}+(-2-4)\vec{k}$$

$$=12\vec{i}+9\vec{j}-6\vec{k}=3(4,3,-2)$$

យក $\vec{u}=(4,3,-2)$ ជាវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(L)$។

- រកចំណុចមួយដែលស្ថិតនៅលើបន្ទាត់ $(L)$៖
តាង $z=0$ ជំនួសក្នុងសមីការប្លង់ទាំងពីរ៖

$$\begin{cases}x+2y-2=0\\ 2x-2y-1=0\end{cases}\implies 3x-3=0\implies x=1\implies y=\frac{1}{2}$$

ដូចនេះ ចំណុច $M\left(1,\frac{1}{2},0\right)\in(L)$។

- គេបានសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(L)$ គឺ៖

$$(L):\begin{cases}x=1+4t\\ y=\frac{1}{2}+3t\\ z=-2t\end{cases}\quad(t\in\mathbb{R})$$

សមីការឆ្លុះ៖ $(L):\frac{x-1}{4}=\frac{2y-1}{6}=\frac{z}{-2}$។

## ៦ សមីការបន្ទាត់កាត់តាមចំណុចមួយហើយកែងទៅនឹងប្លង់មួយ

**ជាទូទៅ ៣**

ឧបមាថាគេមានប្លង់ $(P):ax+by+cz+d=0$ និងចំណុច $A(x_A,y_A,z_A)$ ដែលមិនស្ថិតនៅក្នុងប្លង់ $(P)$ ។ រកសមីការបន្ទាត់ $(L)$ កាត់តាមចំណុច $A(x_A,y_A,z_A)$ ហើយកែងនឹងប្លង់ $P$

- ដោយបន្ទាត់ $(L)\perp(P)$ នោះ វ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$ គឺជាវ៉ិចទ័រប្រាប់ទិស របស់បន្ទាត់ $(L)$ ។

- បើ $\vec{u}$ ជាវ៉ិចទ័រប្រាប់ទិសរបស់បន្ទាត់ $(L)$ នោះគេបាន $\vec{u}=(a,b,c)$
- បន្ទាប់មកប្រើរូបមន្ត : $(L):\frac{x-x_A}{a}=\frac{y-y_A}{b}=\frac{z-z_A}{c}$

**លំហាត់គំរូ ៤**

គេឱ្យប្លង់មួយមានសមីការ $(P): 2x+2y-z+1=0$ និងចំណុច $A(4,1,2)$ ។ ចូរសរសេរសមីការបន្ទាត់ $(L)$ កាត់តាមចំណុច $A$ ហើយកែងនឹងប្លង់ $(P)$ ។

**ដំណោះស្រាយ**

- ប្លង់ $(P): 2x+2y-z+1=0$ មានវ៉ិចទ័រណរម៉ាល់ $\vec{n}=(2,2,-1)$។
- ដោយបន្ទាត់ $(L)\perp(P)$ នោះវ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$ ជាវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(L)$៖

$$\vec{u}_L=\vec{n}=(2,2,-1)$$

- បន្ទាត់ $(L)$ កាត់តាមចំណុច $A(4,1,2)$ ដូចនេះគេបាន៖
  - **សមីការឆ្លុះ៖**

$$(L):\frac{x-4}{2}=\frac{y-1}{2}=\frac{z-2}{-1}$$

  - **សមីការប៉ារ៉ាម៉ែត្រ៖**

$$\begin{cases} x=4+2t \\ y=1+2t \\ z=2-t \end{cases} \quad (t\in\mathbb{R})$$

## ៧ សមីការប្លង់

### ៧.១ សមីការប្លង់កាត់តាមមួយចំណុច និងស្គាល់វ៉ិចទ័រណរម៉ាល់

**និយមន័យ ២**

សមីការ ប្លង់ $P$ កាត់តាម ចំណុច $A(x_o,y_o,z_o)$ ហើយ មាន វ៉ិចទ័រ ណ រម៉ាល់ $\vec{n}(a,b,c)$ កំណត់ ដោយ $(P):\ a(x-x_o)+b(y-y_o)+c(z-z_o)=0$ មានទម្រង់ទូទៅ $ax+by+cz+d=0$




**លំហាត់គំរូ ៥**

ចូរកំណត់សមីការប្លង់ $(P)$ កាត់តាមចំណុច $A(1,2,3)$ ហើយមានវ៉ិចទ័រណរម៉ាល់ $\vec{n}=(2,-3,6)$

**ដំណោះស្រាយ**

សមីការប្លង់ $(P)$ កាត់តាមចំណុច $A(x_0,y_0,z_0)=(1,2,3)$ ហើយមានវ៉ិចទ័រណរម៉ាល់ $\vec{n}=(a,b,c)=(2,-3,6)$ កំណត់ដោយ៖

$$a(x-x_0)+b(y-y_0)+c(z-z_0)=0$$

$$\iff 2(x-1)-3(y-2)+6(z-3)=0$$

$$\iff 2x-2-3y+6+6z-18=0$$

$$\iff (P):2x-3y+6z-14=0$$

## ៧.២ សមីការប្លង់កាត់តាមបន្ទាត់មួយ ហើយស្របទៅនឹងបន្ទាត់មួយទៀត

**ជាទូទៅ ៤**

គេមានបន្ទាត់ពីរ $(L_1): \frac{x-x_1}{a_1}=\frac{y-y_1}{b_1}=\frac{z-z_1}{c_1}$ និង $(L_2): \frac{x-x_2}{a_2}=\frac{y-y_2}{b_2}=\frac{z-z_2}{c_2}$

$(L_1)$ និង $(L_2)$ មានវ៉ិចទ័រប្រាប់ទិសរៀងគ្នាគឺ $\vec{u_1}=(a_1,b_1,c_1)$ និង $\vec{u_2}=(a_2,b_2,c_2)$

តាង $\vec{n}$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$ កាត់តាម $(L_1)$ ហើយស្របនឹងបន្ទាត់ $(L_2)$

គេបាន $\vec{n}=\vec{u_1}\times\vec{u_2}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ a_1 & b_1 & c_1\\ a_2 & b_2 & c_2\end{vmatrix}=(a,b,c)$ ; យក $A\in(L_1)$ នោះ $A(x_1,y_1,z_1)$ គេបាន $A\in(P)$ នោះ

សមីការប្លង់ $(P): a(x-x-1)+b(y-y_1)+c(z-z_1)=0$

**លំហាត់គំរូ ៦**

គេឱ្យបន្ទាត់ពីរមានសមីការ $(L_1): \frac{x-3}{2}=\frac{y+1}{-3}=\frac{z-2}{-2}$ និង $(L_2): \frac{x+2}{4}=y-2=\frac{z+3}{-3}$ ។ ចូរកំណត់សមីការប្លង់ $(P)$ ដែលកាត់តាមបន្ទាត់ $(L_1)$ ហើយស្របនឹងបន្ទាត់ $(L_2)$ ។

**ដំណោះស្រាយ**

- វ៉ិចទ័រប្រាប់ទិសនៃ $(L_1)$ គឺ $\vec{u_1}=(2,-3,-2)$ និងចំណុច $A(3,-1,2)\in(L_1)$។
- វ៉ិចទ័រប្រាប់ទិសនៃ $(L_2)$ គឺ $\vec{u_2}=(4,1,-3)$។
- ដោយប្លង់ $(P)$ កាត់តាម $(L_1)$ ហើយស្របនឹង $(L_2)$ នាំឱ្យវ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$ គឺ៖

$$\vec{n}=\vec{u_1}\times\vec{u_2}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 2 & -3 & -2\\ 4 & 1 & -3\end{vmatrix}=(9-(-2))\vec{i}-(-6-(-8))\vec{j}+(2-(-12))\vec{k}$$

$$=11\vec{i}-2\vec{j}+14\vec{k}=(11,-2,14)$$

- ដោយ $A(3,-1,2)\in(L_1)\implies A\in(P)$ នាំឱ្យសមីការប្លង់ $(P)$ គឺ៖

$$11(x-3)-2(y-(-1))+14(z-2)=0$$

$$\iff 11(x-3)-2(y+1)+14(z-2)=0$$

$$\iff 11x-33-2y-2+14z-28=0$$

$$\iff (P): 11x-2y+14z-63=0$$

## លំហាត់គំរូ ៧

គេឱ្យបន្ទាត់ពីរដែលមានសមីការ $(L_1): \frac{x-1}{-1}=\frac{y-2}{3}=\frac{z+1}{5}$ និង $(L_2): \frac{x+6}{-2}=\frac{y-4}{6}=-z+3$ ។

ក. រកចំណុចប្រសព្វ $A$ រវាងបន្ទាត់ទាំងពីរ

ខ. រកសមីការប្លង់ $(P)$ ដែលកំណត់ដោយបន្ទាត់ $(L_1)$ និង $(L_2)$ ។

### ដំណោះស្រាយ

ក. **រកចំណុចប្រសព្វ $A$ រវាងបន្ទាត់ទាំងពីរ៖**

សរសេរសមីការបន្ទាត់ទាំងពីរជាទម្រង់ប៉ារ៉ាម៉ែត្រ៖

$$(L_1): \begin{cases} x=1-t \\ y=2+3t \\ z=-1+5t \end{cases} \quad \text{និង} \quad (L_2): \begin{cases} x=-6-2s \\ y=4+6s \\ z=3-s \end{cases}$$

ដើម្បីរកចំណុចប្រសព្វ យើងផ្ទឹមផ្ទងកូអរដោនេ៖

$$\begin{cases} 1-t=-6-2s \implies 2s-t=-7 \quad (1) \\ 2+3t=4+6s \implies 3t-6s=2 \quad (2) \\ -1+5t=3-s \implies s+5t=4 \quad (3) \end{cases}$$

ពី (1) យើងបាន $t=2s+7$។ ជំនួសចូល (2)៖

$$3(2s+7)-6s=2 \iff 6s+21-6s=2 \iff 21=2 \quad (\text{មិនពិត})$$

ដោយប្រព័ន្ធសមីការគ្មានចម្លើយ នាំឱ្យបន្ទាត់ $(L_1)$ និង $(L_2)$ គ្មានចំណុចប្រសព្វឡើយ (ជាបន្ទាត់ទ្វេរ)។

ខ. **សមីការប្លង់ $(P)$៖**

ដោយសារបន្ទាត់ទាំងពីរ $(L_1)$ និង $(L_2)$ មិនកាត់គ្នា និងមិនស្របគ្នា (បន្ទាត់ទ្វេរ) នោះបន្ទាត់ទាំងពីរមិនអាចកំណត់ប្លង់តែមួយបានឡើយ។

(ករណីប្លង់កាត់តាម $(L_1)$ ហើយស្រប $(L_2)$៖ មានវ៉ិចទ័រណរម៉ាល់ $\vec{n}=\vec{u_1}\times\vec{u_2}=(-1,3,5)\times(-2,6,-1)=(-33,-11,0)=-11(3,1,0)$ ដែលកាត់តាម $M(1,2,-1)\in(L_1)$ គឺ $(P): 3x+y-5=0$)។

## ៧.៣ សមីការប្លង់កាត់តាមចំណុចមួយ ហើយកែងនឹងបន្ទាត់មួយ

**ជាទូទៅ ៥**

គេមានបន្ទាត់ $(L): \frac{x-x_0}{a} = \frac{y-y_0}{b} = \frac{z-z_0}{c}$ និងចំណុច $A(x_A, y_A, z_A)$
ដោយ $(P) \perp (L)$ នោះវ៉ិចទ័រប្រាប់ទិសរបស់ $(L)$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$ គេបាន ៖ $\overrightarrow{n_p} = \overrightarrow{n_l} = (a, b, c)$
នោះសមីការប្លង់ $(P)$ កាត់តាម $A$ ហើយកែងនឹងបន្ទាត់ $(L)$ កំណត់ដោយ៖ $(P): a(x-x_A)+b(y-y_A)+c(z-z_A) = 0$

**លំហាត់គំរូ ៨**

គេឱ្យបន្ទាត់ $(L): \frac{x+3}{-4} = \frac{y-2}{3} = \frac{z-5}{7}$ ។ ចូរកំណត់សមីការប្លង់ $(P)$ កាត់តាម $A(-3, 1, 0)$ ហើយកែងបន្ទាត់ $(L)$។

**ដំណោះស្រាយ**

- ដោយប្លង់ $(P) \perp (L)$ នាំឱ្យវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(L)$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$៖

$$\vec{n} = \vec{u}_L = (-4, 3, 7)$$

- ប្លង់ $(P)$ កាត់តាមចំណុច $A(-3, 1, 0)$ ដូចនេះសមីការប្លង់ $(P)$ គឺ៖

$$-4(x-(-3))+3(y-1)+7(z-0) = 0$$

$$\iff -4(x+3)+3(y-1)+7z = 0$$

$$\iff -4x-12+3y-3+7z = 0$$

$$\iff (P): -4x+3y+7z-15 = 0 \quad (\text{ឬ } 4x-3y-7z+15 = 0)$$

## ៧.៤ សមីការប្លង់ដែលកំណត់ដោយបន្ទាត់ពីរស្របគ្នាក្នុងប្លង់តែមួយ

**ជាទូទៅ ៦**

គេមានបន្ទាត់ពីរស្របគ្នា $(L_1): \frac{x-x_1}{a}=\frac{y-y_1}{b}=\frac{z-z_1}{c}$ និង $(L_2): \frac{x-x_2}{a}=\frac{y-y_2}{b}=\frac{z-z_2}{c}$ ។ វ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ទាំងពីរគឺ $\vec{u}=(a,b,c)$

យក $A(x_1,y_1,z_1)\in(L_1)$ និង $B(x_2,y_2,z_2)\in(L_2)$ $\Rightarrow \overrightarrow{AB}=(x_2-x_1,y_2-y_1,z_2-z_1)$

តាង $\vec{n}$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$ នោះគេបាន $\vec{n}=\vec{u}\times\overrightarrow{AB}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ a & b & c\\ x_2-x_1 & y_2-y_1 & z_2-z_1\end{vmatrix}$

ឧបមាថា $\vec{n}=(\alpha,\beta,\gamma)$

ដោយ $A\in(P)$ នោះសមីការប្លង់ $(P)$ កំណត់សរសេរដោយ ៖ $(P): \alpha(x-x_1)+\beta(y-y_1)+c(z-z_1)=0$

**លំហាត់គំរូ ៩**

គេឱ្យបន្ទាត់ពីរស្របគ្នា $(L_1): \frac{x+1}{2}=\frac{y-1}{3}=\frac{z-2}{6}$ និង $(L_2): \frac{x-2}{2}=\frac{y+5}{3}=\frac{z-4}{6}$ ។ ចូរកំណត់សមីការប្លង់ $(P)$ កំណត់ដោយបន្ទាត់ ស្របគ្នា $(L_1)$ និង $(L_2)$។

**ដំណោះស្រាយ**

- វ៉ិចទ័រប្រាប់ទិសរួមនៃបន្ទាត់ទាំងពីរគឺ $\vec{u}=(2,3,6)$។
- យកចំណុច $A(-1,1,2)\in(L_1)$ និងចំណុច $B(2,-5,4)\in(L_2)$។
- គណនាវ៉ិចទ័រ $\overrightarrow{AB}$ ៖

$$\overrightarrow{AB}=(2-(-1),-5-1,4-2)=(3,-6,2)$$

- វ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$ គឺ៖

$$\vec{n}=\vec{u}\times\overrightarrow{AB}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 2 & 3 & 6\\ 3 & -6 & 2\end{vmatrix}=(6-(-36))\vec{i}-(4-18)\vec{j}+(-12-9)\vec{k}$$

$$=42\vec{i}+14\vec{j}-21\vec{k}=7(6,2,-3)$$

យក $\vec{n}=(6,2,-3)$។

- សមីការប្លង់ $(P)$ កាត់តាមចំណុច $A(-1,1,2)$ គឺ៖

$$6(x-(-1))+2(y-1)-3(z-2)=0$$

$$\iff 6(x+1)+2(y-1)-3(z-2)=0$$

$$\iff 6x+6+2y-2-3z+6=0$$

$$\iff (P): 6x+2y-3z+10=0$$

## ៧.៥ សមីការប្លង់ដែលជាប្លង់មេដ្យាទ័រនៃអង្កត់មួយ $[AB]$

**ជាទូទៅ ៧**

ដើម្បីរកសមីការប្លង់មេដ្យាទ័រនៃអង្កត់ $[AB]$ គេត្រូវ៖

- រកកូអរដោនេចំណុចកណ្ដាលអង្កត់ $[AB]$ គឺ $I\left(\frac{x_A+x_B}{2},\frac{y_A+y_B}{2},\frac{z_A+z_B}{2}\right)$
- រកវ៉ិចទ័រណរម៉ាល់ប្លង់ $\vec{n}=\overrightarrow{AB}=(x_B-x_A,y_B-y_A,z_B-z_A)=(a,b,c)$
- គេបានសមីការប្លង់ $(P): a(x-x_I)+b(y-y_I)+c(z-z_I)=0$

**លំហាត់គំរូ ១០**

គេឱ្យចំណុច $A(1,2,3)$ និង $B(-3,4,1)$ ។ ចូរកំណត់សមីការប្លង់មេដ្យាទ័ររបស់អង្កត់ $[AB]$ ។

**ដំណោះស្រាយ**

- រកកូអរដោនេចំណុចកណ្ដាល $I$ នៃអង្កត់ $[AB]$ ៖

$$I\left(\frac{1+(-3)}{2},\frac{2+4}{2},\frac{3+1}{2}\right) \implies I(-1,3,2)$$

- វ៉ិចទ័រណរម៉ាល់នៃប្លង់មេដ្យាទ័រគឺ $\vec{n}=\overrightarrow{AB}$ ៖

$$\overrightarrow{AB}=(-3-1,4-2,1-3)=(-4,2,-2)=-2(2,-1,1)$$

យក $\vec{n} = (2,-1,1)$។

- សមីការប្លង់មេដ្យាទ័រកាត់តាមចំណុច $I(-1,3,2)$ គឺ៖

$$2(x-(-1))-1(y-3)+1(z-2)=0$$

$$\iff 2(x+1)-(y-3)+(z-2)=0$$

$$\iff 2x+2-y+3+z-2=0$$

$$\iff (P): 2x-y+z+3=0$$

## ៧.៦ សមីការប្លង់កាត់តាមបីចំណុចផ្សេងគ្នា

**ជាទូទៅ ៨**

គេមានបីចំណុច $A(x_A,y_A,z_A), B(x_B,y_B,z_B)$ និង $C(x_C,y_C,z_C)$ ។ ឧបមាថាបីចំណុច $A,B,C$ មិនរត់ត្រង់ជួរ ដែលបង្កើតបានប្លង់ $(ABC)$ បើប្លង់កាត់តាម $A$ នោះមានវ៉ិចទ័រណរម៉ាល់ $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}=(a,b,c)$ គេបានសមីការប្លង់ $(ABC): a(x-x_A)+b(y-y_A)+c(z-z_A)=0$

**លំហាត់គំរូ ១១**

គេឱ្យបីចំណុច $A(1,2,1), B(-1,3,2)$ និង $C(5,2,2)$ ។ ចូររកសមីការប្លង់ $(ABC)$។

**ដំណោះស្រាយ**

- គណនាវ៉ិចទ័រ $\overrightarrow{AB}$ និង $\overrightarrow{AC}$ ៖

$$\overrightarrow{AB}=(-1-1,3-2,2-1)=(-2,1,1)$$

$$\overrightarrow{AC}=(5-1,2-2,2-1)=(4,0,1)$$

- វ៉ិចទ័រណរម៉ាល់នៃប្លង់ $(ABC)$ គឺ៖

$$\overrightarrow{n}=\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\overrightarrow{i} & \overrightarrow{j} & \overrightarrow{k}\\ -2 & 1 & 1\\ 4 & 0 & 1\end{vmatrix}=(1-0)\overrightarrow{i}-(-2-4)\overrightarrow{j}+(0-4)\overrightarrow{k}$$

$$=\overrightarrow{i}+6\overrightarrow{j}-4\overrightarrow{k}=(1,6,-4)$$

- សមីការប្លង់ $(ABC)$ កាត់តាមចំណុច $A(1,2,1)$ គឺ៖

$$1(x-1)+6(y-2)-4(z-1)=0$$

$$\iff x-1+6y-12-4z+4=0$$

$$\iff (ABC): x+6y-4z-9=0$$

## ៧.៧ សមីការប្លង់ប៉ះស្វ៊ែត្រង់ចំណុចមួយ

គេឱ្យស្វ៊ែ $(S):(x-a)^2+(y-b)^2+(z-c)^2=R^2$ និងចំណុច $A\in(S)$ ដែល $A(x_A,y_A,z_A)$ ។ កំណត់សមីការប្លង់ $(P)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ចំណុច $A$។ ស្វ៊ែ $(S)$ មានផ្ចិត $I(a,b,c)$ ដោយប្លង់ $(P)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ចំណុច $A$ នោះវ៉ិចទ័រ ដែលភ្ជាប់ពីផ្ចិត $I$ ទៅចំណុចប៉ះ $A$ គឺជាវ៉ិចទ័រដែលភ្ជាប់ពីផ្ចិត $I$ ទៅចំណុច ប៉ះ $A$ គឺជាវ៉ិចទ័រណរម៉ាល់របស់ប្លង់ $(P)$ គឺ $\overrightarrow{n_p}=\overrightarrow{IA}=(x_A-a,y_A-b,z_A-c)=(a',b',c')$ ។ ដោយ $A\in(P)$ ដូចនេះសមីការប្លង់ $(P)$ អាចសរសេរ ៖ $(P): a'(x-x_A)+b'(y-y_A)+c'(z-z_A)=0$។

**លំហាត់គំរូ ១២**

គេឱ្យស្វ៊ែ $(S):(x-2)^2+(y+1)^2+(z-1)^2=9$ ។ បង្ហាញថាចំណុច $A(1,-3,3)\in(S)$ រួចសរសេរសមីការប្លង់ $(P)$ ប៉ះនឹងស្វ៊ែ $(S)$ ត្រង់ចំណុច $A$។

**ដំណោះស្រាយ**

- បង្ហាញថា $A(1,-3,3)\in(S)$ ៖
  ជំនួសកូអរដោនេនៃចំណុច $A$ ចូលក្នុងសមីការស្វ៊ែ $(S)$៖

$$(1-2)^2+(-3+1)^2+(3-1)^2=(-1)^2+(-2)^2+2^2=1+4+4=9$$

សមីការផ្ទៀងផ្ទាត់ ដូចនេះចំណុច $A(1,-3,3) \in (S)$ ពិតប្រាកដមែន។

- **សរសេរសមីការប្លង់ $(P)$ ប៉ះស្វ៊ែ $(S)$ ត្រង់ $A$ ៖**

  ផ្ចិតនៃស្វ៊ែ $(S)$ គឺ $I(2,-1,1)$។
  
  វ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$ ប៉ះត្រង់ $A$ គឺ $\vec{n} = \overrightarrow{IA}$៖

$$\overrightarrow{IA} = (1-2, -3-(-1), 3-1) = (-1,-2,2)$$

សមីការប្លង់ $(P)$ កាត់តាម $A(1,-3,3)$ គឺ៖

$$-1(x-1) - 2(y-(-3)) + 2(z-3) = 0$$

$$\iff -(x-1) - 2(y+3) + 2(z-3) = 0$$

$$\iff -x+1-2y-6+2z-6 = 0$$

$$\iff (P): -x-2y+2z-11 = 0 \quad (\text{ឬ } x+2y-2z+11 = 0)$$

## ៧.៨ សមីការប្លង់កំណត់ដោយបន្ទាត់ពីរប្រសព្វគ្នា

**លំហាត់គំរូ ១៣**

គេឱ្យបន្ទាត់ $(L_1): \frac{x-5}{-2} = \frac{y+4}{3} = \frac{z+5}{4}$ និង $(L_2): \frac{x+1}{2} = \frac{y-5}{-3} = \frac{z-4}{-1}$។

ក. រកកូអរដោនេចំណុចប្រសព្វ $A$ រវាង $(L_1)$ និង $(L_2)$

ខ. សរសេរសមីការប្លង់ $(P)$ កំណត់ដោយ $(L_1)$ និង $(L_2)$ ប្រសព្វគ្នា

**ដំណោះស្រាយ**

ក. **រកកូអរដោនេចំណុចប្រសព្វ $A$ រវាង $(L_1)$ និង $(L_2)$ ៖**

សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ទាំងពីរ៖

$$(L_1):\begin{cases}x=5-2t\\ y=-4+3t\\ z=-5+4t\end{cases} \quad \text{និង} \quad (L_2):\begin{cases}x=-1+2s\\ y=5-3s\\ z=4-s\end{cases}$$

ផ្ទឹមផ្ទងកូអរដោនេនៃបន្ទាត់ទាំងពីរ៖

$$\begin{cases}5-2t=-1+2s \implies 2t+2s=6 \implies t+s=3 \quad (1)\\ -4+3t=5-3s \implies 3t+3s=9 \implies t+s=3 \quad (2)\\ -5+4t=4-s \implies 4t+s=9 \quad (3)\end{cases}$$

យក $(3)$ ដក $(1)$ យើងបាន៖ $3t=6 \implies t=2$។
ជំនួស $t=2$ ចូល $(1)$ យើងបាន $s=3-2=1$។
ជំនួស $t=2$ ចូលសមីការនៃ $(L_1)$ ៖

$$\begin{cases}x=5-2(2)=1\\ y=-4+3(2)=2\\ z=-5+4(2)=3\end{cases} \implies A(1,2,3)$$

ដូចនេះ ចំណុចប្រសព្វរវាងបន្ទាត់ទាំងពីរគឺ $A(1,2,3)$។

**២. សរសេរសមីការប្លង់ $(P)$ កំណត់ដោយ $(L_1)$ និង $(L_2)$ ប្រសព្វគ្នា៖**
វ៉ិចទ័រប្រាប់ទិសនៃ $(L_1)$ និង $(L_2)$ គឺ $\vec{u_1}=(-2,3,4)$ និង $\vec{u_2}=(2,-3,-1)$។
វ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$ គឺ៖

$$\vec{n}=\vec{u_1}\times\vec{u_2}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ -2 & 3 & 4\\ 2 & -3 & -1\end{vmatrix}=(-3-(-12))\vec{i}-(2-8)\vec{j}+(6-6)\vec{k}$$

$$=9\vec{i}+6\vec{j}+0\vec{k}=(9,6,0)=3(3,2,0)$$

យក $\vec{n}=(3,2,0)$។

ដោយប្លង់ $(P)$ កាត់តាមចំណុចប្រសព្វ $A(1,2,3)$ នាំឱ្យសមីការប្លង់ $(P)$ គឺ៖

$$3(x-1)+2(y-2)+0(z-3)=0 \iff 3x-3+2y-4=0$$

$$\iff (P): 3x+2y-7=0$$

# ៨ មុំរវាងប្លង់ពីរ

**ជាទូទៅ ៩**

គេមានប្លង់ពីរផ្សេងគ្នា គឺ

- ប្លង់ $(P)$ មានវ៉ិចទ័រណរម៉ាល់ $\vec{n_1}$
- និង ប្លង់ $(Q)$ មានវ៉ិចទ័រណរម៉ាល់ $\vec{n_2}$
  នោះគេបាន ប្លង់ទាំងពីរ៖
- ប្រសព្វគ្នា $(P)\cap(Q)$ ដែលមុំរវាងប្លង់ទាំងពីរគឺ

$$\cos\theta = \frac{|\vec{n_1}\cdot\vec{n_2}|}{|\vec{n_1}||\vec{n_2}|}$$

(ដែល $\theta$ ជាមុំដែលកើតឡើងដោយ $\vec{n_1}$ និង $\vec{n_2}$)

- កែងគ្នា $(P)\perp(Q)$ បើ $\vec{n_1}\cdot\vec{n_2}=0$
- ស្របគ្នា $(P)//(Q)$ បើ $\vec{n_1}=k\vec{n_2}$ ; $k\in\mathbb{R}$; $k\neq 0$




**លំហាត់គំរូ ១៩**

ក. រកមុំរវាងប្លង់ $\alpha_1: x-2y+z=0$ និងប្លង់ $\alpha_2: 2x+3y-2z=0$ ។ (គេយក $\cos 53.55^\circ = 0.5941$)

ខ. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $L$ ដែលជាប្រសព្វរវាងប្លង់ $\alpha_1$ និង $\alpha_2$ ។

**ដំណោះស្រាយ**

ក. **រកមុំ $\theta$ រវាងប្លង់ $\alpha_1$ និង $\alpha_2$ ៖**

វ៉ិចទ័រណរម៉ាល់នៃប្លង់ទាំងពីរគឺ $\overrightarrow{n_1}=(1,-2,1)$ និង $\overrightarrow{n_2}=(2,3,-2)$ ៖

$$|\overrightarrow{n_1}|=\sqrt{1^2+(-2)^2+1^2}=\sqrt{6}$$

$$|\overrightarrow{n_2}|=\sqrt{2^2+3^2+(-2)^2}=\sqrt{4+9+4}=\sqrt{17}$$

$$\overrightarrow{n_1}\cdot\overrightarrow{n_2}=(1)(2)+(-2)(3)+(1)(-2)=2-6-2=-6$$

មុំរវាងប្លង់ទាំងពីរ $(0^\circ\leq\theta\leq 90^\circ)$ កំណត់ដោយ៖

$$\cos\theta=\frac{|\overrightarrow{n_1}\cdot\overrightarrow{n_2}|}{|\overrightarrow{n_1}|\cdot|\overrightarrow{n_2}|}=\frac{|-6|}{\sqrt{6}\cdot\sqrt{17}}=\frac{6}{\sqrt{102}}\approx 0.5941$$

ដោយ $\cos 53.55^\circ\approx 0.5941$ ដូចនេះមុំរវាងប្លង់ទាំងពីរគឺ $\theta\approx 53.55^\circ$។

❷. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $L=\alpha_1\cap\alpha_2$ ៖

- វ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $L$ គឺ៖

$$\overrightarrow{u}=\overrightarrow{n_1}\times\overrightarrow{n_2}=\begin{vmatrix}\overrightarrow{i} & \overrightarrow{j} & \overrightarrow{k}\\ 1 & -2 & 1\\ 2 & 3 & -2\end{vmatrix}=(4-3)\overrightarrow{i}-(-2-2)\overrightarrow{j}+(3-(-4))\overrightarrow{k}=(1,4,7)$$

- ដោយសមីការប្លង់ទាំងពីរគ្មានតួថេរ $(d=0)$ នោះគល់កូអរដោនេ $O(0,0,0)$ ផ្ទៀងផ្ទាត់សមីការទាំងពីរ នាំឱ្យ $O(0,0,0)\in L$។
- ដូចនេះ សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $L$ គឺ៖

$$(L):\begin{cases}x=t\\ y=4t\\ z=7t\end{cases}\qquad(t\in\mathbb{R})$$

# ៩ ចម្ងាយពីចំណុចមួយទៅប្លង់មួយ

**ជាទូទៅ ១០**

ចម្ងាយពីចំណុច $A(x_o,y_o,z_o)$ ទៅប្លង់ $(\alpha)$ : $ax+by+cz+d=0$ កំណត់ដោយ

$d(A_o,\alpha) = \frac{|ax_o+by_o+cz_o+d|}{\sqrt{a^2+b^2+c^2}}$




**លំហាត់គំរូ ១៥**

គណនាចម្ងាយពីចំណុច $P_0$ ទៅប្លង់ $(P)$ ក្នុងករណីនីមួយៗខាងក្រោម៖

ក. $P_0(-1,3,5)$ និង $(P): x-2y+2z+3=0$

ខ. $P_0(2,\sqrt{2},1)$ និង $(P): x-\sqrt{2}y+z+3=0$

**ដំណោះស្រាយ**

រូបមន្តចម្ងាយពីចំណុច $P_0(x_0,y_0,z_0)$ ទៅប្លង់ $(P): ax+by+cz+d=0$ គឺ៖

$$d(P_0,P)=\frac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}}$$

ក. ចំពោះ $P_0(-1,3,5)$ និង $(P): x-2y+2z+3=0$ ៖

$$d(P_0,P)=\frac{|1(-1)-2(3)+2(5)+3|}{\sqrt{1^2+(-2)^2+2^2}}=\frac{|-1-6+10+3|}{\sqrt{1+4+4}}=\frac{|6|}{\sqrt{9}}=\frac{6}{3}=2$$

ខ. ចំពោះ $P_0(2,\sqrt{2},1)$ និង $(P): x-\sqrt{2}y+z+3=0$ ៖

$$d(P_0,P)=\frac{|1(2)-\sqrt{2}(\sqrt{2})+1(1)+3|}{\sqrt{1^2+(-\sqrt{2})^2+1^2}}=\frac{|2-2+1+3|}{\sqrt{1+2+1}}=\frac{|4|}{\sqrt{4}}=\frac{4}{2}=2$$

# ១០ ចម្ងាយពីចំណុចមួយទៅបន្ទាត់មួយក្នុងលំហ

**ជាទូទៅ ១១**

គេមានចំណុច$A$ និង បន្ទាត់$(L)$ ក្នុងលំហ ដែល $\vec{u}$ ជាវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់$(L)$ ហើយចំណុច$P$ ជាចំណោលកែងនៃចំណុច$A$ លើបន្ទាត់$(L)$ គេបាន ចម្ងាយពីចំណុច$A$ ទៅបន្ទាត់$(L)$ គឺ

$$D(A,L)=\frac{\left|\overrightarrow{PA}\times\vec{u}\right|}{|\vec{u}|}$$




# ១១ សមីការស្វ៊ែ

**និយមន័យ ៣**

សមីការនៃស្វ៊ែដែលមានផ្ចិតត្រង់ចំណុច $C(a,b,c)$ និង កាំស្មើ $r$ កំណត់ដោយ

- សមីការស្តង់ដារ $(x-a)^2+(y-b)^2+(z-c)^2=r^2$
- សមីការទូទៅ $x^2+y^2+z^2+Ax+By+Cz+D=0$ ដែល $A,B,C,D$ ជាចំនួនពិត។




**លំហាត់គំរូ ១៦**

កំណត់សមីការស្វ៊ែ ផ្ចិត និងកាំនៃស្វ៊ែ

១. រកសមីការស្វ៊ែ $(S)$ ដែល៖

ក. មានផ្ចិតត្រង់ចំណុច $C(2,-3,1)$ និងកាំ $r=4$

ខ. មានអង្កត់ផ្ចិត $AB$ ដែល $A(1,2,3)$ និង $B(3,0,1)$

គ. មានផ្ចិតនៅត្រង់ចំណុច $C(1,-2,-1)$ ហើយប៉ះនឹងប្លង់ $(xz)$

២. កំណត់ផ្ចិត និងកាំនៃស្វ៊ែដែលមានសមីការដូចខាងក្រោម៖

ក. $(x-2)^2+(y+3)^2+z^2=5$

ខ. $x^2+y^2+z^2-2x+4y-6z+10=0$

**ដំណោះស្រាយ**

១. រកសមីការស្វ៊ែ $(S)$ ៖

ក. ផ្ចិត $C(2,-3,1)$ និងកាំ $r=4$ ៖

$$(S):(x-2)^2+(y-(-3))^2+(z-1)^2=4^2 \iff (x-2)^2+(y+3)^2+(z-1)^2=16$$

ខ. អង្កត់ផ្ចិត $[AB]$ ដែល $A(1,2,3)$ និង $B(3,0,1)$ ៖

- ផ្ចិត $I$ ជាចំណុចកណ្ដាលនៃ $[AB]$៖

$$I\left(\frac{1+3}{2},\frac{2+0}{2},\frac{3+1}{2}\right) \Longrightarrow I(2,1,2)$$

- កាំ $r=\frac{AB}{2}=\frac{\sqrt{(3-1)^2+(0-2)^2+(1-3)^2}}{2}=\frac{\sqrt{4+4+4}}{2}=\frac{\sqrt{12}}{2}=\sqrt{3}$
- សមីការស្វ៊ែ $(S)$៖

$$(S):(x-2)^2+(y-1)^2+(z-2)^2=(\sqrt{3})^2=3$$

គ. ផ្ចិត $C(1,-2,-1)$ ហើយប៉ះនឹងប្លង់ $(xz)$ (សមីការប្លង់ $(xz)$ គឺ $y=0$)៖

- កាំ $r$ ស្មើនឹងចម្ងាយពីផ្ចិត $C$ ទៅប្លង់ $(xz)$៖ $r=|y_C|=|-2|=2$
- សមីការស្វ៊ែ $(S)$៖

$$(S):(x-1)^2+(y-(-2))^2+(z-(-1))^2=2^2 \iff (x-1)^2+(y+2)^2+(z+1)^2=4$$

២. កំណត់ផ្ចិត និងកាំនៃស្វ៊ែ៖

ក. $(x-2)^2+(y+3)^2+z^2=5$ ៖
សរសេរជាទម្រង់ស្តង់ដា៖ $(x-2)^2+(y-(-3))^2+(z-0)^2=(\sqrt{5})^2$
ដូចនេះ ស្វ៊ែមានផ្ចិត $I(2,-3,0)$ និងកាំ $r=\sqrt{5}$។

ខ. $x^2+y^2+z^2-2x+4y-6z+10=0$ ៖

បំប្លែងជាផលបូកការេពេញលេញ៖

$$(x^2-2x+1)+(y^2+4y+4)+(z^2-6z+9)=-10+1+4+9$$

$$\iff (x-1)^2+(y+2)^2+(z-3)^2=4=2^2$$

ដូចនេះ ស្វ៊ែមានផ្ចិត $I(1,-2,3)$ និងកាំ $r=2$។

## ប្រតិបត្តិ ១

១. រកសមីការស្វ៊ែ $(S)$ ដែល៖

ក. មានផ្ចិតត្រង់គល់ $O$ និងកាំ $r=\sqrt{10}$

ខ. មានអង្កត់ផ្ចិត $AB$ ដែល $A(3,-1,2)$ និង $B(0,3,2)$

គ. មានផ្ចិតនៅត្រង់ចំណុច $C(2,-1,5)$ ហើយប៉ះនឹងប្លង់ $(xy)$

ឃ. កាត់តាមចំណុច $D(-5,1,4)$ ហើយប៉ះនឹងប្លង់កូអរដោនេទាំងបី។

២. កំណត់ផ្ចិត និងកាំនៃស្វ៊ែដែលមានសមីការដូចខាងក្រោម៖

ក. $x+2)^2+(y-1)^2+(z+3)^2-16=0$

ខ. $x^2+y^2+z^2-10x+6y+4z+13=0$

## ដំណោះស្រាយ

# ១២ វិសមីការតំបន់ផ្នែកខាងក្នុង

**ជាទូទៅ ១២**

**វិសមីការតំបន់ផ្នែកខាងក្នុង** នៃស្វ៊ែដែលមានផ្ចិតត្រង់ $(a,b,c)$ និងមានកាំ $r$ គឺកំណត់ដោយ

$\{(x,y,z)/(x-a)^2+(y-b)^2+(z-c)^2<r^2\}$




# ១៣ វិសមីការតំបន់ផ្នែកខាងក្រៅ

**ជាទូទៅ ១៣**

**វិសមីការតំបន់ផ្នែកខាងក្រៅ** នៃស្វ៊ែដែលមានផ្ចិតត្រង់ $(a,b,c)$ និងមានកាំ $r$ គឺកំណត់ដោយ

$\{(x,y,z)/(x-a)^2+(y-b)^2+(z-c)^2>r^2\}$




**លំហាត់គំរូ ១៧**

ចូរសរសេរសមីការផ្នែកខាងក្នុង និងក្រៅនៃស្វ៊ែដែលមានផ្ចិត $C(-1,-2,1)$ និងកាំ $r=\sqrt{13}$។

**ដំណោះស្រាយ**

- សមីការស្វ៊ែដែលមានផ្ចិត $C(-1,-2,1)$ និងកាំ $r=\sqrt{13}$ គឺ៖

$$(x-(-1))^2+(y-(-2))^2+(z-1)^2=(\sqrt{13})^2 \iff (x+1)^2+(y+2)^2+(z-1)^2=13$$

- **វិសមីការតំបន់ផ្នែកខាងក្នុងនៃស្វ៊ែ៖**

$$\{(x,y,z) \in \mathbb{R}^3 \mid (x+1)^2 + (y+2)^2 + (z-1)^2 < 13\}$$

- **វិសមីការតំបន់ផ្នែកខាងក្រៅនៃស្វ៊ែ៖**

$$\{(x,y,z) \in \mathbb{R}^3 \mid (x+1)^2 + (y+2)^2 + (z-1)^2 > 13\}$$

**ប្រតិបត្តិ ២**

សរសេរសមីការនៃចំណុចស្ថិតនៅចន្លោះស្វ៊ែពីរមានផ្ចិតនៅត្រង់គល់ $O$ ហើយមានកាំរៀងគ្នា $r = 2$ និង $R = 5$ ។

## ដំណោះស្រាយ

# ១៤ ទីតាំងរវាងស្វ៊ែ $(S)$ និងប្លង់ $(P)$

**ជាទូទៅ ១៤**

ឧបមាថា $d$ ជាចម្ងាយពីផ្ចិត $I(a,b,c)$ នៃស្វ៊ែ $(S)$ ដែលមានកាំ $r$ ទៅប្លង់ $(P)$ គេបាន៖

- បើ $d>r$ នោះប្លង់ $(P)$ មិនកាត់ស្វ៊ែ $(S)$ ទេ។
- បើ $d=r$ នោះប្លង់ $(P)$ ប៉ះស្វ៊ែ $(S)$ ត្រង់ចំណុច $H$ មួយ (ប្លង់ប៉ះ)។
- បើ $d<r$ នោះប្លង់ $(P)$ កាត់ស្វ៊ែ $(S)$ បានរង្វង់មួយ (ផ្ចិត $H$ និងកាំ $r'=\sqrt{r^2-d^2}$)។




$d>r$ (មិនកាត់ស្វ៊ែ)  $d=r$ (ប៉ះត្រង់ $H$)  $d<r$ ($r'=\sqrt{r^2-d^2}$)

# ១៥ ទីតាំងរវាងស្វ៊ែពីរមានកាំ $r$ និង $r'$

**ជាទូទៅ ១៥**

យើងសន្មតថា $d$ ជាចម្ងាយរវាងផ្ចិតនៃស្វ៊ែ $(S)$ និង $(S')$ ដែលមានកាំ $r$ និង $r'$ រៀងគ្នាគេបាន៖

- បើ $d>r+r'$ នោះស្វ៊ែ $(S)$ និង $(S')$ នៅក្រៅគ្នា
- បើ $d=r+r'$ នោះស្វ៊ែ $(S)$ និង $(S')$ ប៉ះគ្នាខាងក្រៅ
- បើ $|r-r'|<d<r+r'$ នោះស្វ៊ែ $(S)$ និង $(S')$ កាត់គ្នាបានរង្វង់មួយ
- បើ $d=|r-r'|$ នោះស្វ៊ែ $(S)$ និង $(S')$ ប៉ះគ្នាខាងក្នុង
- បើ $d<|r-r'|$ នោះស្វ៊ែ $(S)$ និង $(S')$ នៅក្នុងគ្នា




$d>r+r'$ (នៅក្រៅគ្នា)  $d=r+r'$ (ប៉ះក្រៅ)  $|r-r'|<d<r+r'$ (កាត់គ្នាបានរង្វង់)  $d=|r-r'|$ (ប៉ះក្នុង)  $d<|r-r'|$ (នៅក្នុងគ្នា)

# ១៦ សំណួរពហុជ្រើសរើស (Multiple Choice Questions)

ចូរបញ្ជាក់ចម្លើយត្រឹមត្រូវតែមួយគត់ក្នុងចំណោមជម្រើស ក, ខ, គ, និង ឃ ៖

១. ចម្ងាយរវាងពីរចំណុច $A(1,2,3)$ និង $B(4,6,3)$ គឺ៖

ក. $5$ ខ. $25$ គ. $7$ ឃ. $\sqrt{5}$

២. ចម្ងាយរវាងពីរចំណុច $A(0,0,0)$ និង $B(2,-3,6)$ គឺ៖

ក. $49$ ខ. $7$ គ. $\sqrt{13}$ ឃ. $5$

៣. ចម្ងាយរវាងពីរចំណុច $M(1,-1,2)$ និង $N(3,1,1)$ គឺ៖

ក. $3$ ខ. $\sqrt{11}$ គ. $9$ ឃ. $\sqrt{5}$

៤. បើចម្ងាយរវាង $A(x,0,0)$ និង $B(0,3,4)$ ស្មើនឹង $5\sqrt{2}$ នោះ $x$ ស្មើនឹង៖

ក. $\pm 3$ ខ. $\pm 4$ គ. $\pm 5$ ឃ. $\pm 25$

៥. កូអរដោនេនៃចំណុចកណ្ដាល $I$ នៃអង្កត់ $[AB]$ ដែល $A(2,4,-6)$ និង $B(4,-2,2)$ គឺ៖

ក. $(6,2,-4)$ ខ. $(2,-6,8)$ គ. $(1,-3,4)$ ឃ. $(3,1,-2)$

៦. វ៉ិចទ័រប្រាប់ទិសនៃបន្ទាត់កាត់តាម $A(1,2,3)$ និង $B(3,5,7)$ គឺ៖

ក. $(2,3,4)$ ខ. $(4,7,10)$ គ. $(2,2,2)$ ឃ. $(-2,-3,-4)$

៧. ត្រីកោណ $ABC$ ដែល $A(1,0,0), B(0,1,0), C(0,0,1)$ ជាត្រីកោណ៖

ក. សមបាត ខ. សម័ង្ស គ. កែង ឃ. កែងសមបាត

៨. ប្រវែងជ្រុងនៃត្រីកោណសម័ង្ស $ABC$ ក្នុងសំណួរខាងលើគឺ៖

ក. $1$ ខ. $2$ គ. $\sqrt{2}$ ឃ. $\sqrt{3}$

៩. ផ្ទៃក្រឡាត្រីកោណ $ABC$ ខាងលើគឺ៖

ក. $\frac{\sqrt{3}}{4}$ ខ. $\frac{1}{2}$ គ. $\sqrt{3}$ ឃ. $\frac{\sqrt{3}}{2}$

១០. ចំណុច $M(x,y,z)$ ស្មើចម្ងាយពី $A(1,0,0)$ និង $B(-1,0,0)$ លុះត្រាតែ៖

ក. $x=0$ ខ. $y=0$ គ. $z=0$ ឃ. $x+y+z=0$

១១. សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់កាត់តាម $M_0(x_0,y_0,z_0)$ និងមានវ៉ិចទ័រប្រាប់ទិស $\vec{u}=(a,b,c)$ គឺ៖

ក. $x=x_0+at,\ y=y_0+bt,\ z=z_0+ct$ ខ. $x=x_0-at,\ y=y_0+bt,\ z=z_0-ct$

គ. $ax+by+cz+d=0$ ឃ. $\frac{x-x_0}{a}+\frac{y-y_0}{b}+\frac{z-z_0}{c}=0$

១២. សមីការឆ្លុះនៃបន្ទាត់កាត់តាម $M_0(x_0,y_0,z_0)$ មានវ៉ិចទ័រប្រាប់ទិស $\vec{u}=(a,b,c)$ $(abc\neq 0)$ គឺ៖

ក. $\frac{x+x_0}{a}=\frac{y+y_0}{b}=\frac{z+z_0}{c}$ ខ. $\frac{x-x_0}{a}=\frac{y-y_0}{b}=\frac{z-z_0}{c}$

គ. $a(x-x_0)+b(y-y_0)+c(z-z_0)=0$ ឃ. $\frac{a}{x-x_0}=\frac{b}{y-y_0}=\frac{c}{z-z_0}$

១៣. បន្ទាត់ $(L):\begin{cases}x=1+2t\\y=-3+4t\\z=5-t\end{cases}$ មានវ៉ិចទ័រប្រាប់ទិសគឺ៖

ក. $(1,-3,5)$ ខ. $(-1,3,-5)$ គ. $(2,4,-1)$ ឃ. $(2,4,1)$

១៤. បន្ទាត់ $(L)$ ក្នុងសំណួរខាងលើកាត់តាមចំណុចណា?៖

ក. $(2,4,-1)$ ខ. $(-1,3,-5)$ គ. $(0,0,0)$ ឃ. $(1,-3,5)$

១៥. សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់កាត់តាម $A(2,-1,3)$ មានវ៉ិចទ័រប្រាប់ទិស $\vec{u}=(3,0,-2)$ គឺ៖

ក. $\begin{cases}x=2+3t\\y=-1\\z=3-2t\end{cases}$ ខ. $\begin{cases}x=3+2t\\y=-t\\z=-2+3t\end{cases}$

គ. $\begin{cases}x=2+3t\\y=-1+t\\z=3-2t\end{cases}$ ឃ. $\begin{cases}x=2-3t\\y=-1\\z=3+2t\end{cases}$

១៦. សមីការឆ្លុះនៃបន្ទាត់កាត់តាម $A(1,-2,4)$ និង $B(2,1,3)$ គឺ៖

ក. $\frac{x-1}{1}=\frac{y+2}{3}=\frac{z-4}{1}$ ខ. $\frac{x-1}{1}=\frac{y+2}{3}=\frac{z-4}{-1}$

គ. $\frac{x-2}{1}=\frac{y-1}{3}=\frac{z-3}{1}$ ឃ. $\frac{x+1}{1}=\frac{y-2}{3}=\frac{z+4}{-1}$

១៧. ចំណុចណាដែលស្ថិតនៅលើបន្ទាត់ $(L):\frac{x-1}{2}=\frac{y+1}{3}=\frac{z-2}{-1}$?៖

ក. $(1,1,2)$ ខ. $(2,3,-1)$ គ. $(3,2,1)$ ឃ. $(0,0,0)$

១៨. បើចំណុច $M(5,y_0,0)$ ស្ថិតនៅលើបន្ទាត់ខាងលើ នោះ $y_0$ ស្មើនឹង៖

ក. $2$ ខ. $-1$ គ. $3$ ឃ. $5$

១៩. បន្ទាត់ពីរ $(L_1):\frac{x-1}{2}=\frac{y}{3}=\frac{z+1}{1}$ និង $(L_2):\frac{x+2}{4}=\frac{y-1}{6}=\frac{z}{2}$ ជាបន្ទាត់៖

ក. ស្របគ្នា ខ. កែងគ្នា គ. កាត់គ្នា ឃ. ទ្រួតគ្នា

២០. បន្ទាត់ពីរ $(L_1):\begin{cases}x=1+t\\y=2-t\\z=3t\end{cases}$ និង $(L_2):\begin{cases}x=2s\\y=1+s\\z=-1-s\end{cases}$ កែងគ្នាកាលណាផលគុណស្កាលែនៃវិចទ័រប្រាប់ទិសស្មើនឹង៖

ក. 1 ខ. 0 គ. $-1$ ឃ. 2

២១. ពីសំណួរខាងលើ បន្ទាត់ $(L_1)$ និង $(L_2)$ ៖

ក. ស្របគ្នា ខ. កាត់គ្នា គ. កែងគ្នា ឃ. មិនកែងគ្នាទេ

២២. បន្ទាត់ស្របនឹងអ័ក្ស $(Oz)$ មានវិចទ័រប្រាប់ទិសគឺ៖

ក. $(1,0,0)$ ខ. $(0,1,0)$ គ. $(1,1,0)$ ឃ. $(0,0,1)$

២៣. សមីការបន្ទាត់តំណាងអ័ក្ស $(Ox)$ គឺ៖

ក. $\begin{cases}x=t\\y=0\\z=0\end{cases}$ ខ. $\begin{cases}x=0\\y=t\\z=0\end{cases}$

គ. $\begin{cases}x=0\\y=0\\z=t\end{cases}$ ឃ. $\begin{cases}x=t\\y=t\\z=0\end{cases}$

២៤. បន្ទាត់ពីរស្របគ្នាកាលណា វិចទ័រប្រាប់ទិសរបស់វាទាំងពីរ៖

ក. កែងគ្នា ខ. កូលីនេអ៊ែរគ្នា គ. ស្មើគ្នានឹងសូន្យ ឃ. គ្មានទំនាក់ទំនង

២៥. បន្ទាត់ពីរ $(L_1)$ និង $(L_2)$ កាត់គ្នាកាលណា៖

ក. វិចទ័រប្រាប់ទិសកូលីនេអ៊ែរគ្នា ខ. គ្មានចំណុចរួម គ. មានចំណុចរួមតែមួយគត់ ឃ. ស្ថិតក្នុងប្លង់ពីរផ្សេងគ្នា

២៦. បន្ទាត់កាត់តាម $A(1,0,-1)$ និងកែងនឹងប្លង់ $(P): 2x-y+3z-5=0$ មានវិចទ័រប្រាប់ទិសគឺ៖

ក. $(1,0,-1)$ ខ. $(-2,1,-3)$ គ. $(2,1,3)$ ឃ. $(2,-1,3)$

២៧. សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ក្នុងសំណួរខាងលើគឺ៖

ក. $\begin{cases}x=1+2t\\y=-t\\z=-1+3t\end{cases}$ ខ. $\begin{cases}x=2+t\\y=-1\\z=3-t\end{cases}$

គ. $\begin{cases} x = 1-2t \\ y = t \\ z = -1-3t \end{cases}$ ឃ. $\begin{cases} x = 1+2t \\ y = t \\ z = -1+3t \end{cases}$

២៨. បន្ទាត់ $(L)$ កាត់តាម $A(0,0,0)$ និង $B(1,1,1)$ មានសមីការឆ្លុះគឺ៖

ក. $x = y-1 = z$ ខ. $x = y = z$ គ. $x+y+z = 0$ ឃ. $x-y = z$

២៩. បន្ទាត់ $(L)$ កាត់តាម $A(2,3,4)$ និងស្របនឹងអ័ក្ស $(Oy)$ មានសមីការប៉ារ៉ាម៉ែត្រគឺ៖

ក. $\begin{cases} x = 2+t \\ y = 3 \\ z = 4 \end{cases}$ ខ. $\begin{cases} x = 2 \\ y = 3 \\ z = 4+t \end{cases}$

គ. $\begin{cases} x = 2 \\ y = 3+t \\ z = 4 \end{cases}$ ឃ. $\begin{cases} x = 2t \\ y = 3t \\ z = 4t \end{cases}$

៣០. បន្ទាត់ប្រសព្វនៃប្លង់ $(Oxy)$ និង $(Oxz)$ គឺ៖

ក. អ័ក្ស $(Oy)$ ខ. អ័ក្ស $(Oz)$ គ. បន្ទាត់ $x = y = z$ ឃ. អ័ក្ស $(Ox)$

៣១. សមីការទូទៅនៃប្លង់ក្នុងលំហមានទម្រង់៖

ក. $Ax+By+Cz+D = 0$ ខ. $y = ax+b$

គ. $\frac{x}{a}+\frac{y}{b} = 1$ ឃ. $(x-a)^2+(y-b)^2 = r^2$

៣២. វ៉ិចទ័រណរម៉ាល់នៃប្លង់ $(P): 3x-2y+5z-7 = 0$ គឺ៖

ក. $(3,2,5)$ ខ. $(3,-2,5)$ គ. $(-3,2,5)$ ឃ. $(3,-2,-7)$

៣៣. ប្លង់ $(P)$ កាត់តាម $A(1,2,3)$ មានវ៉ិចទ័រណរម៉ាល់ $\vec{n} = (2,-1,4)$ មានសមីការគឺ៖

ក. $2x-y+4z-14 = 0$ ខ. $2x-y+4z+12 = 0$

គ. $2x-y+4z-12 = 0$ ឃ. $x+2y+3z-12 = 0$

៣៤. ប្លង់កាត់តាមគល់តម្រុយ $O(0,0,0)$ និងមានវ៉ិចទ័រណរម៉ាល់ $\vec{n} = (1,2,3)$ មានសមីការគឺ៖

ក. $x+2y+3z = 6$ ខ. $x+2y+3z = 1$ គ. $x+2y-3z = 0$ ឃ. $x+2y+3z = 0$

៣៥. សមីការប្លង់កូអរដោនេ $(Oxy)$ គឺ៖

ក. $z = 0$ ខ. $x = 0$ គ. $y = 0$ ឃ. $x+y = 0$

៣៦. សមីការប្លង់កូអរដោនេ $(Oyz)$ គឺៈ

ក. $z=0$ ខ. $x=0$ គ. $y=0$ ឃ. $y+z=0$

៣៧. សមីការប្លង់កូអរដោនេ $(Oxz)$ គឺៈ

ក. $z=0$ ខ. $x=0$ គ. $y=0$ ឃ. $x+z=0$

៣៨. ប្លង់ស្របនឹងប្លង់ $(Oxy)$ និងកាត់តាម $A(1,2,5)$ មានសមីការគឺៈ

ក. $x=1$ ខ. $y=2$ គ. $x+y=3$ ឃ. $z=5$

៣៩. ប្លង់ស្របនឹងប្លង់ $(P): 2x-3y+z-1=0$ ត្រូវតែមានវ៉ិចទ័រណរម៉ាល់កូលីនេអ៊ែរនឹងៈ

ក. $(2,-3,1)$ ខ. $(2,3,1)$ គ. $(1,-3,2)$ ឃ. $(-2,-3,1)$

៤០. ប្លង់កាត់តាម $A(1,1,1)$ និងស្របនឹងប្លង់ $(P): x+2y-3z+4=0$ មានសមីការគឺៈ

ក. $x+2y-3z=4$ ខ. $x+2y-3z=0$ គ. $x+2y-3z+1=0$ ឃ. $x+2y-3z-2=0$

៤១. ប្លង់ $(P)$ កាត់អ័ក្សទាំងបីត្រង់ $A(a,0,0), B(0,b,0), C(0,0,c)$ $(abc\neq 0)$ មានសមីការតាមកង់គឺៈ

ក. $\frac{x}{a}+\frac{y}{b}+\frac{z}{c}=0$ ខ. $ax+by+cz=1$

គ. $\frac{x}{a}+\frac{y}{b}+\frac{z}{c}=1$ ឃ. $\frac{a}{x}+\frac{b}{y}+\frac{c}{z}=1$

៤២. ប្លង់កាត់តាម $A(2,0,0), B(0,3,0), C(0,0,6)$ មានសមីការគឺៈ

ក. $3x+2y+z-1=0$ ខ. $6x+3y+2z-6=0$ គ. $3x+2y+z+6=0$ ឃ. $3x+2y+z-6=0$

៤៣. ប្លង់មេដ្យាទ័រនៃអង្កត់ $[AB]$ ជាប្លង់ដែលៈ

ក. កែងនឹង $[AB]$ ត្រង់ចំណុចកណ្ដាលនៃ $[AB]$ ខ. កាត់តាមចំណុច $A$ និងកែងនឹង $[AB]$

គ. កាត់តាមចំណុច $B$ និងកែងនឹង $[AB]$ ឃ. ស្របនឹង $[AB]$

៤៤. គេឱ្យ $A(1,2,3)$ និង $B(3,4,1)$។ ចំណុចកណ្ដាល $I$ នៃ $[AB]$ គឺៈ

ក. $(1,1,-1)$ ខ. $(2,3,2)$ គ. $(4,6,4)$ ឃ. $(2,2,2)$

៤៥. ពីសំណួរខាងលើ សមីការប្លង់មេដ្យាទ័រនៃអង្កត់ $[AB]$ គឺៈ

ក. $x+y+z-7=0$ ខ. $x-y+z-1=0$ គ. $x+y-z-3=0$ ឃ. $2x+2y-2z-5=0$

៤៦. ប្លង់កាត់តាមបីចំណុច $A(1,0,0), B(0,1,0), C(0,0,1)$ មានវ៉ិចទ័រណរម៉ាល់គឺៈ

ក. $(1,0,1)$ ខ. $(0,1,1)$ គ. $(-1,1,0)$ ឃ. $(1,1,1)$

៤៧. សមីការប្លង់កាត់តាមបីចំណុចក្នុងសំណួរខាងលើគឺៈ

ក. $x+y+z-1=0$ ខ. $x+y+z+1=0$ គ. $x+y-z-1=0$ ឃ. $x-y+z-1=0$

៤៨. ប្លង់ពីរ $(P_1): A_1x+B_1y+C_1z+D_1=0$ និង $(P_2): A_2x+B_2y+C_2z+D_2=0$ កែងគ្នាកាលណា៖

ក. $A_1A_2+B_1B_2+C_1C_2=1$ ខ. $A_1A_2+B_1B_2+C_1C_2=0$

គ. $\frac{A_1}{A_2}=\frac{B_1}{B_2}=\frac{C_1}{C_2}$ ឃ. $D_1=D_2$

៤៩. ប្លង់ $(P): 2x-y+3z-4=0$ និង $(Q): x+2y+mz+1=0$ កែងគ្នាកាលណា $m$ ស្មើនឹង៖

ក. $m=1$ ខ. $m=-1$ គ. $m=0$ ឃ. $m=2$

៥០. ប្លង់ពីរ $(P): 3x-6y+9z-2=0$ និង $(Q): x-2y+3z+5=0$ ជាប្លង់៖

ក. កាត់គ្នា ខ. កែងគ្នា គ. ត្រួតគ្នា ឃ. ស្របគ្នាដាច់ខាត

៥១. កូស៊ីនុសនៃមុំរវាងប្លង់ពីរដែលមានវ៉ិចទ័រណរម៉ាល់ $\vec{n}_1$ និង $\vec{n}_2$ កំណត់ដោយ៖

ក. $\cos\theta=\frac{|\vec{n}_1\cdot\vec{n}_2|}{\|\vec{n}_1\|\|\vec{n}_2\|}$ ខ. $\cos\theta=\frac{\vec{n}_1\cdot\vec{n}_2}{\|\vec{n}_1\|\|\vec{n}_2\|}$

គ. $\cos\theta=\frac{\|\vec{n}_1\times\vec{n}_2\|}{\|\vec{n}_1\|\|\vec{n}_2\|}$ ឃ. $\cos\theta=|\vec{n}_1\cdot\vec{n}_2|$

៥២. មុំរវាងប្លង់ $(P): x+y-2=0$ និង $(Q): y+z-3=0$ គឺ៖

ក. $30^\circ$ ខ. $60^\circ$ គ. $45^\circ$ ឃ. $90^\circ$

៥៣. មុំរវាងប្លង់ $(P): x=0$ និង $(Q): y=0$ គឺ៖

ក. $0^\circ$ ខ. $45^\circ$ គ. $90^\circ$ ឃ. $180^\circ$

៥៤. ប្លង់ $(P)$ កាត់តាម $A(1,2,-1)$ និងកែងនឹងបន្ទាត់ $(L): \frac{x-1}{3}=\frac{y}{2}=\frac{z+3}{-4}$ មានសមីការគឺ៖

ក. $3x+2y-4z-10=0$ ខ. $3x+2y-4z+11=0$ គ. $3x-2y+4z-11=0$ ឃ. $3x+2y-4z-11=0$

៥៥. បន្ទាត់ $(L)$ កែងនឹងប្លង់ $(P)$ កាលណា៖

ក. វ៉ិចទ័រប្រាប់ទិសនៃ $(L)$ កូលីនេអ៊ែរនឹងវ៉ិចទ័រណរម៉ាល់នៃ $(P)$ ខ. វ៉ិចទ័រប្រាប់ទិសនៃ $(L)$ កែងនឹងវ៉ិចទ័រណរម៉ាល់នៃ $(P)$

គ. បន្ទាត់ $(L)$ ស្ថិតក្នុងប្លង់ $(P)$ ឃ. គ្មានចំណុចរួម

៥៦. បន្ទាត់ $(L)$ ស្របនឹងប្លង់ $(P)$ កាលណា៖

ក. វ៉ិចទ័រប្រាប់ទិសនៃ $(L)$ កូលីនេអ៊ែរនឹងវ៉ិចទ័រណរម៉ាល់នៃ $(P)$ ខ. វ៉ិចទ័រប្រាប់ទិសនៃ $(L)$ កែងនឹងវ៉ិចទ័រណរម៉ាល់នៃ $(P)$

គ. បន្ទាត់ $(L)$ កាត់ប្លង់ $(P)$ ត្រង់មួយចំណុច ឃ. វ៉ិចទ័រទាំងពីរបូកចូលគ្នាស្មើ $\vec{0}$

៥៧. បន្ទាត់ $(L): \frac{x-1}{1}=\frac{y}{2}=\frac{z+1}{-1}$ និងប្លង់ $(P): 2x-y-3=0$ ៖

ក. កាត់គ្នាត្រង់មួយចំណុច ខ. កែងគ្នា គ. ស្របគ្នា ឃ. ត្រួតគ្នា

៥៨. ប្រព័ន្ធសមីការតំណាងបន្ទាត់ប្រសព្វនៃប្លង់ពីរ $(P): x+y+z-1=0$ និង $(Q): 2x-y+z-2=0$ គឺ៖

ក. $\begin{cases} x+y+z-1=0 \\ 2x-y+z-2=0 \end{cases}$ ខ. $x+y+z=2x-y+z$

គ. $(x+y+z-1)(2x-y+z-2)=0$ ឃ. $\frac{x+y+z-1}{2x-y+z-2}=1$

៥៩. វ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ប្រសព្វរវាងប្លង់ $(P)$ និង $(Q)$ ខាងលើកំណត់ដោយៈ

ក. $\vec{n}_P+\vec{n}_Q$ ខ. $\vec{n}_P\times\vec{n}_Q$ គ. $\vec{n}_P\cdot\vec{n}_Q$ ឃ. $\vec{n}_P-\vec{n}_Q$

៦០. វ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ប្រសព្វរវាងប្លង់ $(Oxy)$ និងប្លង់ $(Oyz)$ គឺៈ

ក. $(1,0,0)$ ខ. $(0,1,0)$ គ. $(0,0,1)$ ឃ. $(1,1,0)$

៦១. ប្លង់ដែលកាត់តាមចំណុច $M(1,-2,3)$ និងស្របនឹងអ័ក្ស $(Ox)$ និង $(Oy)$ មានសមីការគឺៈ

ក. $x=1$ ខ. $y=-2$ គ. $x+y=-1$ ឃ. $z=3$

៦២. ប្លង់កាត់តាម $A(1,0,0)$ និងផ្ទុកអ័ក្ស $(Oy)$ មានសមីការគឺៈ

ក. $z=0$ ខ. $y=0$ គ. $x=0$ ឃ. $x+z=1$

៦៣. ប្លង់កាត់តាម $A(0,0,2)$ និងផ្ទុកអ័ក្ស $(Ox)$ មានសមីការគឺៈ

ក. $x=0$ ខ. $y=0$ គ. $z=2$ ឃ. $x+y=2$

៦៤. ចំណុចប្រសព្វរវាងបន្ទាត់ $(L):\begin{cases} x=1+t \\ y=2t \\ z=-1+t \end{cases}$ និងប្លង់ $(P):x+y+z-8=0$ គឺៈ

ក. $(2,2,0)$ ខ. $(3,3,2)$ គ. $(3,4,1)$ ឃ. $(4,2,2)$

៦៥. តាង $t$ ជាប៉ារ៉ាម៉ែត្រ ចំណុចប្រសព្វក្នុងសំណួរខាងលើត្រូវនឹងតម្លៃ $t$ ស្មើនឹងៈ

ក. $t=0$ ខ. $t=1$ គ. $t=3$ ឃ. $t=2$

៦៦. ចម្ងាយពីចំណុច $M_0(x_0,y_0,z_0)$ ទៅប្លង់ $(P):Ax+By+Cz+D=0$ គឺៈ

ក. $d=\frac{|Ax_0+By_0+Cz_0+D|}{\sqrt{A^2+B^2+C^2}}$ ខ. $d=\frac{Ax_0+By_0+Cz_0+D}{\sqrt{A^2+B^2+C^2}}$

គ. $d=\frac{|Ax_0+By_0+Cz_0+D|}{A^2+B^2+C^2}$ ឃ. $d=\frac{\sqrt{A^2+B^2+C^2}}{|Ax_0+By_0+Cz_0+D|}$

៦៧. ចម្ងាយពីគល់តម្រុយ $O(0,0,0)$ ទៅប្លង់ $(P):2x-2y+z-6=0$ គឺៈ

ក. 3 ខ. 2 គ. 6 ឃ. 1

៦៨. ចម្ងាយពីចំណុច $A(1,2,3)$ ទៅប្លង់ $(P):2x+y-2z+8=0$ គឺៈ

ក. 1 ខ. 3 គ. 2 ឃ. 6

៦៩. ចម្ងាយពីចំណុច $M(2,-1,1)$ ទៅប្លង់ $(Oxy)$ គឺ៖

ក. 2 ខ. 1 គ. 3 ឃ. 1

៧០. ចម្ងាយពីចំណុច $M(2,-3,4)$ ទៅប្លង់ $(Oxz)$ គឺ៖

ក. 3 ខ. 2 គ. 4 ឃ. 5

៧១. ចម្ងាយរវាងប្លង់ស្របគ្នាពីរ $(P): 2x-y+2z-1=0$ និង $(Q): 2x-y+2z+8=0$ គឺ៖

ក. 9 ខ. 3 គ. 6 ឃ. 1

៧២. ចម្ងាយពីចំណុច $M$ ទៅបន្ទាត់ $(L)$ កាត់តាម $A$ មានវ៉ិចទ័រប្រាប់ទិស $\vec{u}$ គឺ៖

ក. $d=\frac{|\overrightarrow{AM}\cdot\vec{u}|}{\|\vec{u}\|}$ ខ. $d=\frac{\|\overrightarrow{AM}\times\vec{u}\|}{\|\vec{u}\|^2}$

គ. $d=\frac{\|\overrightarrow{AM}\times\vec{u}\|}{\|\vec{u}\|}$ ឃ. $d=\|\overrightarrow{AM}\times\vec{u}\|$

៧៣. ចម្ងាយពីគល់តម្រុយ $O(0,0,0)$ ទៅបន្ទាត់ $(L):\begin{cases}x=t\\y=0\\z=0\end{cases}$ (អ័ក្ស $Ox$) គឺ៖

ក. 1 ខ. $\sqrt{2}$ គ. $\infty$ ឃ. 0

៧៤. ចម្ងាយពីចំណុច $M(1,2,0)$ ទៅអ័ក្ស $(Oz)$ គឺ៖

ក. $\sqrt{5}$ ខ. 1 គ. 2 ឃ. 5

៧៥. ចម្ងាយពីចំណុច $M(3,0,4)$ ទៅអ័ក្ស $(Oy)$ គឺ៖

ក. 7 ខ. 5 គ. 3 ឃ. 4

៧៦. ចម្ងាយពី $M(0,1,0)$ ទៅបន្ទាត់ $(L): \frac{x}{1}=\frac{y}{0}=\frac{z}{0}$ គឺ៖

ក. 0 ខ. 2 គ. 1 ឃ. $\sqrt{2}$

៧៧. ចម្ងាយពីចំណុច $M(1,1,1)$ ទៅប្លង់ $(P): x+y+z-3=0$ គឺ៖

ក. 3 ខ. $\sqrt{3}$ គ. 1 ឃ. 0

៧៨. ពីសំណួរខាងលើ បញ្ជាក់ថាចំណុច $M(1,1,1)$ ៖

ក. ស្ថិតនៅលើប្លង់ $(P)$ ខ. នៅក្រៅប្លង់ $(P)$

គ. ជាចំណោលកែងលើប្លង់ $(P)$ ឃ. គ្មានន័យ

៧៩. រកតម្លៃ $m$ បើចម្ងាយពី $A(1,0,1)$ ទៅប្លង់ $(P): 2x-y+2z+m=0$ ស្មើនឹង 2 ៖

ក. $m=2$ ឬ $m=-10$ ខ. $m=2$ ឬ $m=-6$
គ. $m=0$ ឃ. $m=6$ ឬ $m=-6$

៨០. ប្លង់ $(P)$ មួយប៉ះស្វ៊ែ $(S)$ កាលណាចម្ងាយពីផ្ចិត $I$ ទៅប្លង់ $(P)$ ៖
ក. ធំជាងកាំ $r$ ខ. ស្មើនឹងកាំ $r$ គ. តូចជាងកាំ $r$ ឃ. ស្មើនឹងសូន្យ

៨១. សមីការស្តង់ដារនៃស្វ៊ែដែលមានផ្ចិត $I(a,b,c)$ និងកាំ $r$ គឺ៖
ក. $(x-a)^2+(y-b)^2+(z-c)^2=r$ ខ. $(x+a)^2+(y+b)^2+(z+c)^2=r^2$
គ. $(x-a)^2+(y-b)^2+(z-c)^2=r^2$ ឃ. $x^2+y^2+z^2=r^2$

៨២. ផ្ចិត និងកាំនៃស្វ៊ែ $(S):(x-1)^2+(y+2)^2+(z-3)^2=16$ គឺ៖
ក. $I(-1,2,-3),\ r=16$ ខ. $I(1,-2,3),\ r=16$
គ. $I(-1,2,-3),\ r=4$ ឃ. $I(1,-2,3),\ r=4$

៨៣. ស្វ៊ែដែលមានផ្ចិត $O(0,0,0)$ និងកាំ $r=5$ មានសមីការគឺ៖
ក. $x^2+y^2+z^2=25$ ខ. $x^2+y^2+z^2=5$ គ. $(x-5)^2+(y-5)^2+(z-5)^2=0$ ឃ. $x+y+z=25$

៨៤. សមីការទូទៅ $x^2+y^2+z^2-2x+4y-6z+5=0$ មានផ្ចិតគឺ៖
ក. $(-1,2,-3)$ ខ. $(1,-2,3)$ គ. $(2,-4,6)$ ឃ. $(-2,4,-6)$

៨៥. កាំនៃស្វ៊ែក្នុងសំណួរខាងលើគឺ៖
ក. $r=14$ ខ. $r=4$ គ. $r=3$ ឃ. $r=9$

៨៦. លក្ខខណ្ឌដើម្បីឱ្យសមីការ $x^2+y^2+z^2+Ax+By+Cz+D=0$ ជាសមីការស្វ៊ែគឺ៖
ក. $A^2+B^2+C^2-D>0$ ខ. $A^2+B^2+C^2-4D=0$
គ. $A^2+B^2+C^2+4D>0$ ឃ. $A^2+B^2+C^2-4D>0$

៨៧. វិសមីការតំបន់ផ្នែកខាងក្នុងនៃស្វ៊ែផ្ចិត $I(a,b,c)$ កាំ $r$ គឺ៖
ក. $(x-a)^2+(y-b)^2+(z-c)^2<r^2$ ខ. $(x-a)^2+(y-b)^2+(z-c)^2>r^2$
គ. $(x-a)^2+(y-b)^2+(z-c)^2\le r$ ឃ. $x^2+y^2+z^2<r^2$

៨៨. វិសមីការតំបន់ផ្នែកខាងក្រៅនៃស្វ៊ែផ្ចិត $I(a,b,c)$ កាំ $r$ គឺ៖
ក. $(x-a)^2+(y-b)^2+(z-c)^2<r^2$ ខ. $(x-a)^2+(y-b)^2+(z-c)^2>r^2$
គ. $(x-a)^2+(y-b)^2+(z-c)^2=r^2$ ឃ. $(x-a)^2+(y-b)^2+(z-c)^2\ge r$

៨៩. ចំណុច $M(1,1,1)$ ធៀបនឹងស្វ៊ែ $(S): x^2+y^2+z^2=9$ ស្ថិតនៅ៖

ក. លើស្វ៊ែ ខ. ក្រៅស្វ៊ែ គ. ក្នុងស្វ៊ែ ឃ. ត្រង់ផ្ចិតស្វ៊ែ

៩០. ចំណុច $P(2,2,2)$ ធៀបនឹងស្វ៊ែ $(S): x^2+y^2+z^2=9$ ស្ថិតនៅ៖

ក. ក្នុងស្វ៊ែ ខ. លើស្វ៊ែ គ. ត្រង់ផ្ចិត ឃ. ក្រៅស្វ៊ែ

៩១. បើចម្ងាយពីផ្ចិតស្វ៊ែទៅប្លង់គឺ $d>r$ នោះប្លង់ និងស្វ៊ែ៖

ក. មិនកាត់គ្នា ខ. ប៉ះគ្នាត្រង់មួយចំណុច គ. កាត់គ្នាបានរង្វង់មួយ ឃ. កាត់គ្នាបានបន្ទាត់មួយ

៩២. បើចម្ងាយពីផ្ចិតស្វ៊ែទៅប្លង់គឺ $d=r$ នោះប្លង់ និងស្វ៊ែ៖

ក. មិនកាត់គ្នា ខ. ប៉ះគ្នាត្រង់មួយចំណុច គ. កាត់គ្នាបានរង្វង់មួយ ឃ. មានចំណុចរួមច្រើនរាប់មិនអស់

៩៣. បើចម្ងាយពីផ្ចិតស្វ៊ែទៅប្លង់គឺ $d<r$ នោះប្លង់កាត់ស្វ៊ែបាន៖

ក. ចំណុចមួយ ខ. បន្ទាត់មួយ គ. រង្វង់មួយ ឃ. ពងក្រពើមួយ

៩៤. កាំ $r'$ នៃរង្វង់ប្រសព្វរវាងស្វ៊ែកាំ $r$ និងប្លង់ដែលមានចម្ងាយ $d$ $(d<r)$ គឺ៖

ក. $r'=r-d$ ខ. $r'=\sqrt{r^2+d^2}$ គ. $r'=r^2-d^2$ ឃ. $r'=\sqrt{r^2-d^2}$

៩៥. ស្វ៊ែកាំ $r=5$ ត្រូវបានកាត់ដោយប្លង់មួយនៅចម្ងាយ $d=3$ ពីផ្ចិត។ កាំរង្វង់ប្រសព្វគឺ៖

ក. $r'=4$ ខ. $r'=2$ គ. $r'=16$ ឃ. $r'=\sqrt{34}$

៩៦. ស្វ៊ែកាំ $r=10$ ត្រូវបានកាត់ដោយប្លង់មួយនៅចម្ងាយ $d=6$ ពីផ្ចិត។ ផ្ទៃក្រឡារង្វង់ប្រសព្វគឺ៖

ក. $64\pi$ ខ. $8\pi$ គ. $16\pi$ ឃ. $100\pi$

៩៧. បើចម្ងាយរវាងផ្ចិតនៃស្វ៊ែពីរគឺ $d>r+r'$ នោះស្វ៊ែទាំងពីរ៖

ក. ប៉ះគ្នាខាងក្រៅ ខ. នៅក្រៅគ្នា គ. កាត់គ្នាបានរង្វង់មួយ ឃ. នៅក្នុងគ្នា

៩៨. បើចម្ងាយរវាងផ្ចិតនៃស្វ៊ែពីរគឺ $d=r+r'$ នោះស្វ៊ែទាំងពីរ៖

ក. នៅក្រៅគ្នា ខ. កាត់គ្នា គ. ប៉ះគ្នាខាងក្រៅ ឃ. ប៉ះគ្នាខាងក្នុង

៩៩. បើ $|r-r'|<d<r+r'$ នោះស្វ៊ែទាំងពីរ៖

ក. នៅក្រៅគ្នា ខ. ប៉ះគ្នាខាងក្រៅ គ. នៅក្នុងគ្នា ឃ. កាត់គ្នាបានរង្វង់មួយ

១០០. បើ $d=|r-r'|$ $(r\neq r')$ នោះស្វ៊ែទាំងពីរ៖

ក. ប៉ះគ្នាខាងក្នុង ខ. ប៉ះគ្នាខាងក្រៅ គ. កាត់គ្នា ឃ. មានផ្ចិតរួមគ្នា

# លំហាត់អនុវត្តន៍

១. $ABCD$ ជាចតុមុខមួយដែលមានទ្រនុងទាំង 6 ប៉ុនៗគ្នា។ $A'$ ជាចំណោលកែងនៃ $A$ លើប្លង់ $(BCD)$ ។ $O$ ជាចំណុចមួយនៃ $[AA']$ ដែល $OA = OB = 3 \cdot OA' = x(cm)$ ។

ក. ចូរគណនា $\overrightarrow{OA} \cdot \overrightarrow{OB}$ ជាអនុគមន៍នៃ $x$ ។

ខ. ចូរគណនា $\cos AOB$ រួចទាញរក $AB$ ជាអនុគមន៍នៃ $x$ ។

## ដំណោះស្រាយ

❷. នៅក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេឱ្យចំណុច $A(2,2,2), B(2,0,1)$ និង $C(0,-1,3)$ ។

ក. ចូរសង់រូប។

ខ. គណនាកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB}$ និង $\overrightarrow{BC}$។

គ. គណនាផលគុណស្កាលែ $\overrightarrow{AB}\cdot\overrightarrow{BC}$ រួចទាញថា $ABC$ ជាត្រីកោណកែង។

## ដំណោះស្រាយ

៣. នៅក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ ដែលមានទិសដៅវិជ្ជមាន គេឱ្យចំណុច $A(1,-3,2)$ និង វ៉ិចទ័រ $\vec{w}=(2,1,3)$។(បេក្ខជនមិនបាច់គូសរូប)

ក. សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(D)$ ដែលកាត់តាម $A$ និងមានវ៉ិចទ័រប្រាប់ទិស $\vec{w}$ ។

ខ. រកកូអរដោនេនៃចំណុចប្រសព្វរវាងបន្ទាត់ $(D)$ និងប្លង់ $(Q)$ ដែលមានសមីការ $2x-y+5z+3=0$ ។

## ដំណោះស្រាយ

៤. រកចំនួនពិត$x$ដើម្បីឱ្យវ៉ិចទ័រ$\vec{u}=3\vec{i}+\vec{j}-4\vec{k}$ កែងនឹងវ៉ិចទ័រ $\vec{c}=x\vec{i}+\vec{j}-5\vec{k}$។

## ដំណោះស្រាយ

៥. រកចំនួនពិត$y$ដើម្បីឱ្យវ៉ិចទ័រ$\vec{a}(-2,1,7)$ កែងទៅនឹងវ៉ិចទ័រ$\vec{e}(1,y,4)$។

## ដំណោះស្រាយ

៦. បង្ហាញថាចំណុច$P(1,7,2)$;$Q(0,7,-2)$ និង $R(-1,6,1)$ ជាកំពូលត្រីកោណកែង។

## ដំណោះស្រាយ

**៧**. រកប្រវែង និង ទិសដៅស៊ីនុសនៃវ៉ិចទ័រនីមួយៗខាងក្រោម៖

ក. $\vec{u}(-1,1,1)$

ខ. $\vec{u}(3,0,0)$

គ. $\vec{u}=\vec{i}+\vec{j}+\vec{k}$

ឃ. $\vec{u}=4\vec{i}-\vec{j}$

ង. $\vec{u}=-\vec{i}-\vec{j}-\vec{k}$

ច. $\vec{u}=-3\vec{i}-3\vec{j}+8\vec{k}$

ឆ. $\vec{u}=3\vec{i}-\vec{j}-4\vec{k}$

ជ. $\vec{u}=-2\vec{i}-3\vec{j}-4\vec{k}$

## ដំណោះស្រាយ

៨. រកមុំផ្គុំដោយវ៉ិចទ័រនីមួយៗខាងក្រោម៖

ក. $\vec{u}(4,2,4)$ និង $\vec{v}(2\sqrt{2},2\sqrt{2},0)$

ខ. $\vec{u}(2,1,-2)$ និង $\vec{v}(0,-\sqrt{2},\sqrt{2})$

គ. $\vec{u}=\vec{i}-2\vec{j}+2\vec{k}$ និង $\vec{v}=-2\vec{i}+\vec{j}+2\vec{k}$

ឃ. $\vec{u}=-2\vec{i}+\vec{j}+2\vec{k}$ និង $\vec{v}=\sqrt{2}\vec{i}-\sqrt{2}\vec{j}$

## ដំណោះស្រាយ

៩. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(0,1,-4),B(-2,1,-1)$ និង $C(1,1,1)$។

ក. រកកូអរដោនេនៃវ៉ិចទ័រ$\overrightarrow{AB}$ និង $\overrightarrow{BC}$។

ខ. រកប្រវែងអង្កត់$AB$ និង $BC$។

គ. គណនាផលគុណស្កាលែ $\overrightarrow{AB}\cdot\overrightarrow{BC}$។

ឃ. រកមុំ $\angle ABC$រួចទាញបញ្ជាក់ប្រភេទនៃត្រីកោណ$\triangle ABC$។

## ដំណោះស្រាយ

១០. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(2,2,6),B(2+2\sqrt{2},0,4)$ និង $C(2+2\sqrt{2},4,4)$។

ក. រកកូអរដោនេនៃវ៉ិចទ័រ$\overrightarrow{AB}$ និង $\overrightarrow{AC}$។

ខ. រកប្រវែងអង្កត់$AB$ និង $AC$។

គ. គណនាផលគុណស្កាលែ $\overrightarrow{AB}\cdot\overrightarrow{AC}$។

ឃ. រកមុំ $\angle BAC$រួចទាញបញ្ជាក់ប្រភេទនៃត្រីកោណ$\triangle ABC$។

## ដំណោះស្រាយ

មេរៀនទី ៣ មេរៀនទី៣ អនុវត្តន៍នៃផលគុណវ៉ិចទ័រ

១១. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(4,2,3), B(-2,1,-1), C(3,8,7)$ និង $D(-6,2,z)$។

ក. រកកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB}, \overrightarrow{AC}$ និង $\overrightarrow{BC}$។

ខ. រកប្រវែងអង្កត់ $AB, AC$ និង $BC$។

គ. បង្ហាញថា $\triangle ABC$ ជាត្រីកោណសមបាត។

ឃ. កំណត់ចំនួនពិត $z$ ដើម្បី $ABD$ ជាត្រីកោណសមបាតកំពូល $B$។

ង. រកកូអរដោនេទីប្រជុំទំងន់នៃត្រីកោណ $\triangle ABC$។

## ដំណោះស្រាយ

១២. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(0,6,2)$, $B(3,4,1)$ និង $C(1,3,4)$។

ក. រកកូអរដោនេនៃវិចទ័រ$\overrightarrow{AB}$, $\overrightarrow{AC}$ និង $\overrightarrow{BC}$។

ខ. រកប្រវែងអង្កត់$AB$, $AC$ និង $BC$។

គ. តើ$\triangle ABC$ ជាត្រីកោណ សមបាត ត្រីកោណសម័ង្ស ឬជាត្រីកោណកែង ?

## ដំណោះស្រាយ

១៣. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(2,1,0), B(0,2,1)$ និង $C(0,-1,4)$។

ក. រកកូអរដោនេនៃវ៉ិចទ័រ $\overrightarrow{AB}$ និង $\overrightarrow{AC}$។

ខ. រកប្រវែងអង្កត់ $AB$ និង $AC$។

គ. គណនាផលគុណស្កាលែ $\overrightarrow{AB}\cdot\overrightarrow{AC}$។

ឃ. គណនាមុំ $\theta$ ដែលផ្គុំឡើងរវាងវ៉ិចទ័រ $\overrightarrow{AB}$ និង $\overrightarrow{AC}$។

## ដំណោះស្រាយ

១៤. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$M(3,1,5),N(3,5,1)$ និង $P(-1,5,5)$។

ក. គណនាផលគុណស្កាលែ $\overrightarrow{MN}\cdot\overrightarrow{MP}$។

ខ. គណនាមុំ $\theta$ដែលផ្គុំឡើងរវាងវ៉ិចទ័រ $\overrightarrow{MN}$ និង $\overrightarrow{MP}$។

គ. កំណត់ប្រភេទនៃត្រីកោណ$\triangle MNP$។

## ដំណោះស្រាយ

១៥. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(1,0,1),B(2,1,0)$ និង វ៉ិចទ័រ $\overrightarrow{AC}(-1,2,1)$។

ក. គណនាផលគុណស្កាលែ $\overrightarrow{AB}\cdot\overrightarrow{AC}$។

ខ. រកកូអរដោនេចំណុច$C$។

គ. គេគូសមេដ្យាន$BM$នៃត្រីកោណ$ABC$។រកកូអរដោនេចំណុច$M$។

ឃ. រកទីប្រជុំទំងន់នៃត្រីកោណ$ABC$។

## ដំណោះស្រាយ

១៦. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌខាងក្រោម៖

ក. កាត់តាមចំណុច$A(-1,-1,4)$ ហើយស្របនឹងវ៉ិចទ័រ $\vec{u}=\vec{i}+\vec{j}-2\vec{k}$។

ខ. កាត់តាមចំណុច$B(1,3,-2)$ ហើយកែងនឹងប្លង់ $x-y+2z=5$។

គ. កាត់តាមចំណុច$C(1,-1,2)$ ហើយកែងនឹងប្លង់ $5x-y+3z=7$។

ឃ. កាត់តាមចំណុច$D(1,5,10)$ ហើយស្របនឹងអ័ក្សកូដ។

ង. កាត់តាម$E(2,-1,0)$ ហើយស្របនឹងបន្ទាត់$(d): x=3+2t, y=5-2t, z=-7+5t, t\in\mathbb{R}$។

ច. កាត់តាមចំណុច$F(0,4,-2)$ ហើយស្របនឹងបន្ទាត់$(d): \dfrac{x-3}{5}=\dfrac{y-2}{-2}=\dfrac{z+1}{2}$។

## ដំណោះស្រាយ

១៧. ក. រកសមីការប៉ារ៉ាម៉ែតនៃបន្ទាត់$(L)$កាត់តាមចំណុច$P(2,-3,7)$ហើយស្របនឹងវ៉ិចទ័រ $\vec{v}(1,1,-4)$។

ខ. រកវ៉ិចទ័រប្រាប់ទិសនៃបន្ទាត់ $(d): 2x-6=4-y=z-5$។

គ. រកមុំផ្គុំរវាងបន្ទាត់$(L)$ និង $(d)$។

## ដំណោះស្រាយ

១៨. រកសមីការប្លង់ $\alpha$ ក្នុងករណីនីមួយៗខាងក្រោម៖

ក. ប្លង់ $\alpha$ កាត់តាមចំណុច $A(2,1,3)$ ហើយស្របនឹងប្លង់ $(P): 2x+2y+z-6=0$។

ខ. ប្លង់ $\alpha$ កាត់តាមចំណុច $A(-1,3,5)$ ហើយស្របនឹងប្លង់ $(P): 6x-3y-2z+9=0$។

គ. ប្លង់ $\alpha$ កាត់តាមចំណុច $O(0,0,0)$ ហើយស្របនឹងប្លង់ $(P): 3x-7y+z=4$។

ឃ. ប្លង់ $\alpha$ កាត់តាមចំណុច $A(4,-2,1)$ ហើយកែងនឹងបន្ទាត់ដែលកាត់តាមចំណុច $P(2,-1,2)$ និង $Q(3,2,-1)$។

ង. ប្លង់ $\alpha$ កាត់តាមចំណុច $A(-1,3,2)$ ហើយស្របនឹងប្លង់ $(yoz)$។

ច. ប្លង់ $\alpha$ កាត់តាមចំណុច $A(-7,8,9)$ ហើយស្របនឹងប្លង់ $(xoz)$។

ឆ. ប្លង់ $\alpha$ កាត់តាមគល់តម្រុយហើយស្របនឹងប្លង់ $(xoy)$។

## ដំណោះស្រាយ

១៩. គេមានប្លង់ $\alpha$ កាត់តាមចំណុច$P(1,2,-3)$ហើយមានវ៉ិចទ័រណរម៉ាល់$\vec{n}(3,-2,5)$។

ក. ចូរសរសេរសមីការទូទៅនៃប្លង់$\alpha$។

ខ. តើ$\vec{a}(4,1,-2)$ជាវ៉ិចទ័រស្របឬកែងទៅនឹងប្លង់$\alpha$?

គ. តើ$\vec{a}(15,-10,25)$ជាវ៉ិចទ័រស្របឬកែងទៅនឹងប្លង់$\alpha$?

ឃ. រកវ៉ិចទ័រមួយផ្សេងទៀតដែលកែងទៅនឹងប្លង់$\alpha$។

## ដំណោះស្រាយ

២០. គេមានប្លង់ $(\alpha): x+2y-z-8=0$។

ក. តើ$A(1,3,-1), B(3,5,1)$ និង $C(1,6,5)$ជាចំណុចនៅលើប្លង់$(\alpha)$ឬទេ?

ខ. រកចំណុចប្រសព្វរវាងប្លង់នឹងអ័ក្សទាំងបី។

គ. រកពីរវ៉ិចទ័រដែលស្របទៅនឹងប្លង់$(\alpha)$។

## ដំណោះស្រាយ

២១. គណនាចម្ងាយពីចំណុចទៅប្លង់ខាងក្រោម៖

ក. ពីចំណុច$A(3,2,-1)$ ទៅប្លង់$(\alpha): 7x-6y+6z=8$។

ខ. ពីចំណុច$O(0,0,0)$ ទៅប្លង់$(\alpha): 2x+y-2z+7=0$។

គ. ពីចំណុច$Q(-2,8,-3)$ ទៅប្លង់$(\alpha): 9x-y-4z=0$។

ឃ. ពីចំណុច$R(-1,2,-1)$ ទៅប្លង់$(\alpha): x+y=6$។

ង. ពីចំណុច$R(0,-3,0)$ ទៅប្លង់$(\alpha): 2x-7y+z-1=0$។

ច. ពីចំណុច$R(4,-4,1)$ ទៅប្លង់$(\alpha): 2x+y-z=3$។

## ដំណោះស្រាយ

២២. គណនាចម្ងាយរវាងប្លង់ពីរស្របគ្នា៖

ក. $(\alpha): 8x+y-4z+6=0$ និង $(\beta): 8x+y-4z=24$ ។

ខ. $(\alpha): 2x+y-z=12$ និង $(\beta): 2x+y-z=7$ ។

## ដំណោះស្រាយ

២៣. រកមុំរវាងប្លង់ខាងក្រោម៖

ក. $(\alpha): x-2y+3z-4=0$ និង $(\beta): -2x+2y-z=3$។

ខ. $(\alpha): 3x-z=7$ និង $(\beta): 2y+4z=5$។

គ. $(\alpha): 4x-4y+7z=31$ និង $(\beta): 3x-2y-6z=11$។

ឃ. $(\alpha): 2x+3y+5z=17$ និង $(\beta): x=4$។

## ដំណោះស្រាយ

២៤. រកសមីការស្វ៊ែក្នុងករណីនីមួយៗខាងក្រោម៖

ក. ស្វ៊ែ$S$មានផ្ចិត $I(0,1,2)$និង កាំ$r=\sqrt{3}$។

ខ. ស្វ៊ែ$S$មានផ្ចិត $I(0,-1,3)$ ហើយកាត់តាមចំណុច$M(2,1,1)$។

គ. ស្វ៊ែ$S$មានអង្កត់ផ្ចិត$AB$ដែលចំណុច$A(4,0,5)$ និង $B(0,4,5)$។

ឃ. ស្វ៊ែ$S$មានផ្ចិត $I(3,-1,4)$ ហើយកាំជាចម្ងាយពី$Q(0,2,1)$ទៅប្លង់$(\alpha): x-2y+3z-1=0$។

ង. ស្វ៊ែ$S$មានផ្ចិត $I(2,2,-1)$ ហើយប៉ះនិងប្លង់$(P): 2x+y-z-3=0$។

ច. ស្វ៊ែ$S$មានផ្ចិត $I(-5,1,1)$ ហើយប៉ះស្វ៊ែ $S': x^2+y^2+z^2-2x+4y-6z+5=0$។

ឆ. ស្វ៊ែ$S$មានផ្ចិត $I(1,0,-1)$ ហើយប៉ះស្វ៊ែ$S': x^2+y^2+z^2-6x-2y+4z+5=0$។

## ដំណោះស្រាយ

២៥. រកកូអរដោនេផ្ចិត និង កាំនៃស្វ៊ែនីមួយៗខាងក្រោម៖

ក. $x^2+y^2+z^2-2x+4z-4=0$

ខ. $x^2+y^2+z^2+2x+14y-10z+74=0$

គ. $2x^2+2y^2+2z^2+4x-4y-14=0$

ឃ. $x^2+y^2+z^2-6x+2y-4z-19=0$

ង. $x^2+y^2+z^2-8x+4y+10z+9=0$

ច. $x^2+y^2+z^2-4=0$

## ដំណោះស្រាយ

២៦. កំណត់ទីតាំងរវាងស្វ៊ែ$S'$ និង $S$៖

ក. $S: x^2+y^2+z^2-2x+4z-4=0$ និង $S': x^2+y^2+z^2-6x+2y-4z-19=0$

ខ. $S: x^2+y^2+z^2-8x+4y-2z+4=0$ និង $S': x^2+y^2+z^2+4x-2y-4z+5=0$

គ. $S: 2x^2+2y^2+2z^2+4x-4y-14=0$ និង $S': x^2+y^2+z^2-2x+4z-4=0$

## ដំណោះស្រាយ

២៧. កំណត់ទីតាំងរវាងស្វ៊ែ $S'$ និង ប្លង់ $P$៖

ក. $S: x^2+y^2+z^2+2x-8y-4z+12=0$ និង $(P): 2x-2y+z-1=0$

ខ. $S: x^2+y^2+z^2-2x+6y+4z-22=0$ និង $(P): x+2y-2z-5=0$

គ. $S: x^2+y^2+z^2+2x-4y-2z+2=0$ និង $(P): x+y-2z-11=0$

## ដំណោះស្រាយ

២៨. ក្នុងសំណេរខាងក្រោមមួយណាជាបញ្ញាក់វិសមភាព៖

ក. $\vec{j}\times\vec{i}$ ខ. $\vec{i}\times\vec{j}$ គ. $\vec{j}\times\vec{k}$ ឃ. $\vec{k}\times\vec{j}$ ង. $\vec{i}\times\vec{k}$ ច. $\vec{k}\times\vec{i}$

## ដំណោះស្រាយ

២៩. រក $\vec{u}\times\vec{v}$ ហើយបង្ហាញថា $\vec{u}\times\vec{v}$ កែងនឹង $\vec{u}$ ផង ហើយកែងនឹង $\vec{v}$ ផងក្នុងករណីនីមួយៗខាងក្រោម៖

ក. $\vec{u}=(2,-3,1);\vec{v}=(1,-2,1)$

ខ. $\vec{u}=(12,-3,0);\vec{v}=(-2,5,0)$

គ. $\vec{u}=(1,1,1);\vec{v}=(2,1,-1)$

ឃ. $\vec{u}=(-1,1,2);\vec{v}=(0,1,0)$

ង. $\vec{u}=(2,-3,1);\vec{v}=(1,-2,1)$

ច. $\vec{u}=(0,1,6);\vec{v}=(1,-2,1)$

## ដំណោះស្រាយ

៣០. រក $\vec{u}(4,-2,,5)$ និង $\vec{v}(7,9,-8)$។ រកវ៉ិចទ័រ $\vec{x}$ ដែលផ្ទៀងផ្ទាត់ទំនាក់ទំនងខាងក្រោម៖

ក. $2\vec{u}+\vec{x}=3\vec{v}$

ខ. $4\vec{x}-\vec{u}=3\vec{u}-4\vec{v}+2\vec{x}$

## ដំណោះស្រាយ

៣១. គេឱ្យ $\vec{u}(2,-1,5);\vec{v}(3x,5,4y-2)$ និង $\vec{w}(z-1,2,z+1)$។

ក. រកតម្លៃ $x$ និង $y$ ដែល $\vec{u}\parallel\vec{v}$។

ខ. រកតម្លៃ $z$ ដែល $\vec{u}\perp\vec{v}$។

## ដំណោះស្រាយ

៣២. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេឱ្យចំណុច $A(1,-1,-4);B(3,-4,2)$ នឹង $C(4,5,-2)$។

ក. គណនា $\overrightarrow{AB},\overrightarrow{AC}$ នឹង $\overrightarrow{BC}$។

ខ. គណនាផលគុណស្កាលែ $\overrightarrow{AB}.\overrightarrow{AC}$ រួចប្រាប់ឈ្មោះរបស់ត្រីកោណ $ABC$។

## ដំណោះស្រាយ

៣៣. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេឱ្យចំណុច $A(x,2,-1);B(0,y,1)$ នឹង $C(3,4,-2)$។ កំណត់ $x$ និង $y$ដើម្បីឱ្យ $ABC$ ជាត្រីកោណកែងបាតកំពូល $A$។

## ដំណោះស្រាយ

៣៤. គេឱ្យ $\vec{a}=(1,-2,1);\vec{b}=(-1,1,3)$ នឹង $\vec{c}=(2,3,-1)$។

ក. កំណត់កូអរដោនេនៃវ៉ិចទ័រ $\vec{u}=\vec{a}+\vec{b}+\vec{c},\vec{v}=2\vec{a}-\vec{b}+3\vec{c}$ និង $\vec{w}=2\vec{u}+3\vec{v}$។

ខ. គេមានវ៉ិចទ័រ $\vec{S}=(1,3,6)$។ កំណត់ចំនួនពិត $\alpha,\beta,\gamma$ ដោយដឹងថា $\vec{S}=\alpha\vec{a}+\beta\vec{b}+\gamma\vec{c}$។

## ដំណោះស្រាយ

៣៥. រក $\vec{u}\times\vec{v}$ រួចបង្ហាញថា $\vec{u}\times\vec{v}$ អរតូកូណាល់ទៅនឹងវ៉ិចទ័រ $\vec{u}$ ផង នឹង$\vec{v}$ ផងក្នុងករណីនីមួយៗខាងក្រោម៖

ក. $\vec{u}=(4,3,5);\vec{v}=(-1,8,4)$

ខ. $\vec{u}=(-3,2,-5);\vec{v}=(11,2,5)$

គ. $\vec{u}=(-8,-6,4);\vec{v}=(10,-12,-2)$

ឃ. $\vec{u}=(-1,3,1);\vec{v}=(0,3,7)$

## ដំណោះស្រាយ

៣៦. គេឱ្យបីចំណុច $A(1,-1,2);B(2,1,4)$ នឹង $C(4,-2,-2)$។

ក. កំណត់កូអរដោនេវ៉ិចទ័រនៃវ៉ិចទ័រ $\overrightarrow{AB},\overrightarrow{BC}$ និង $\overrightarrow{AC}$។

ខ. គណនារង្វាស់ជ្រុងទាំងបីនៃត្រីកោណ $ABC$។

គ. កំណត់កូអរដោនេនៃចំណុច$D$ ដោយដឹងថា$ABCD$ជាប្រលេឡូក្រាម។

## ដំណោះស្រាយ

៣៧. គេឱ្យបីចំណុច $\vec{a}=(1,-2,2);\vec{b}=(-1,4,8)$ នឹង $\vec{c}(x,y,4)$។

ក. គណនាផលគុណស្កាលែ $\vec{a}.\vec{b}$។

ខ. គណនា $|\vec{a}|,|\vec{b}|$ នឹងកូស៊ីនុសនៃមុំរវាងពីរវ៉ិចទ័រ $\vec{a}$ នឹង $\vec{b}$។

គ. កំណត់ $x$ នឹង $y$ ដើម្បីឱ្យ $\vec{a}.\vec{c}=\vec{b}.\vec{c}$ នឹង $(\vec{a}+\vec{b}).\vec{c}=52$។

## ដំណោះស្រាយ

៣៨. ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន$(O,\vec{i},\vec{j},\vec{k})$ គេមានបីចំណុច $A(-1,2,3);B(0,-1,1)$ នឹង $C(2,3,5)$។

ក. ចូរកំណត់សមីការប្លង់ $(P)$ កាត់តាមចំណុច $A$ ហើយកែងនឹងវ៉ិចទ័រ $\overrightarrow{BC}$ នឹង សមីការប៉ារ៉ាម៉ែត្របន្ទាត់ $(L)$ដែលកាត់តាមចំណុច $B$ នឹង $C$។

ខ. គណនាកូអរដោនេនៃចំណុចប្រសព្វ $H$ រវាងបន្ទាត់ $(L)$ ជាមួយប្លង់ $(P)$។

គ. រកប្រភេទនៃត្រីកោណ $\triangle ABC$។

## ដំណោះស្រាយ

៣៩. ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន$(O,\vec{i},\vec{j},\vec{k})$ គេមានបួនចំណុច $A(4,0,0);B(0,-2,0),C(0,0,2)$ នឹង $D(4,2,2)$។

ក. បង្ហាញថាចតុកោណ $ABCD$ ជាប្រលេឡូក្រាម។

ខ. ចូរកំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(BC)$ នឹង សមីការនៃប្លង់ដែលកាត់តាមបីចំណុច $A,B$នឹង $C$។

គ. យក $H$ ជាចំណោលកែងនៃ $A$ លើបន្ទាត់ $(BC)$ ។ រកកូអរដោនេនៃចំណុច $H$ រួចគណនា $AH$ នឹងផ្ទៃក្រឡាប្រលេឡូក្រាម $ABCD$។

ឃ. គេមានចំណុច $S(1,6,-6)$។ បង្ហាញថាបន្ទាត់ $(SA)$កែងនឹងប្លង់ $(ABCD)$ រួចគណនាមាឌនៃពីរ៉ាមីត $SABCD$។

## ដំណោះស្រាយ

៤០. ក្នុងតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន$(O,\vec{i},\vec{j},\vec{k})$ គេមានបីចំណុច $A(1,2,3)$ នឹង $(\alpha): x+2y-2z-8=0$។

ក. កំណត់សមីការប៉ារ៉ាម៉ែត្រនៃ$(\Delta)$ គូសចេញពីចំណុច $A$ហើយកែងនឹងប្លង់ $(\beta)$ត្រង់ចំណុច $H$។

ខ. គណនាកូអរដោនេនៃចំណុច $H$នឹងចំណុច $A'$ ឆ្លុះគ្នានឹង $A$ ធៀបនឹងប្លង់ $(\alpha)$។

គ. កំណត់សមីការប្លង់ $(\beta)$កាត់តាមចំណុច $A'$ ហើយស្របនឹងប្លង់ $(\alpha)$ ខាងលើ។

## ដំណោះស្រាយ

៤១. គេឱ្យ $(\alpha): 2x+2y+z-9=0$ នឹង $(\Delta): \begin{cases} x=2-t \\ y=6-4t \\ z=2+t, t\in IR \end{cases}$

ក. រកកូអរដោនេចំណុចប្រសព្វ $A$ រវាងបន្ទាត់ $(\Delta)$ នឹងប្លង់ $(\alpha)$។

ខ. កំណត់មុំស្រួចរវាងបន្ទាត់ $(\Delta)$ នឹងប្លង់ $(\alpha)$។

គ. កំណត់សមីការប្លង់ $(\beta)$ កែងនឹងបន្ទាត់ $(\Delta)$ ត្រង់ចំណុច $A$។

ឃ. កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ប្រសព្វរវាងប្លង់ $(\Delta)$ នឹងប្លង់ $(\alpha)$។

## ដំណោះស្រាយ

៤២. គេឱ្យប្លង់ $(\Delta) : 2x - 2y + z - 1 = 0$ នឹងស្វ៊ែ $(S) : x^2 + y^2 + z^2 + 2x - 8y - 4z + 12 = 0$។

ក. បង្ហាញថាប្លង់ $(\alpha)$ ប៉ះនឹងស្វ៊ែ $(S)$ត្រង់ចំណុច $A$មួយ។

ខ. កំណត់កូអរដោនេចំណុចប៉ះ $A$។

គ. កំណត់សមីការបន្ទាត់ $(\Delta)$ កែងនឹងប្លង់ $(\alpha)$ត្រង់ចំណុច $A$។

ឃ. ក្រៅពីចំណុច $A$ បន្ទាត់ $(\Delta)$ ប្រសព្វស្វ៊ែ $(S)$ ត្រង់ចំណុច $B$មួយទៀត។ ចូរកំណត់កូអរដោនេចំណុច $B$រួចកំណត់សមីការនៃប្លង់$(\beta)$ ដែលប៉ះស្វ៊ែ $(S)$ ត្រង់ $B$។

## ដំណោះស្រាយ

៤៣. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(4,-2,0),B(1,2,2),C(2,-1,0)$ និង $D(2,-2,-1)$។

ក. កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(d)$ដែលកាត់តាមចំណុច$A$ហើយស្របនឹងវ៉ិចទ័រ$\overrightarrow{CD}$។

ខ. កំណត់សមីការប្លង់$(P)$ដែលកាត់តាមចំណុច$B$ហើយកែងនឹងបន្ទាត់$CD$។

គ. កំណត់កូអរដោនេចំណុចប្រសព្វរវាងបន្ទាត់$(d)$ និង $(P)$។

## ដំណោះស្រាយ

៤៤. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(3,0,1),B(2,4,0)$ និង $C(0,3,3)$។

ក. គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$។ ទាញថាចំណុច$A,B$ និង $C$ ជាកំពូលនៃត្រីកោណមួយ រួចគណនាផ្ទៃក្រឡានៃត្រីកោណនេះ។

ខ. កំណត់សមីការប្លង់$(ABC)$។

គ. កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(d)$ដែលកាត់តាមចំណុច$O$ហើយស្របនឹងវ៉ិចទ័រ$\vec{u}(1,1,1)$។

ឃ. កំណត់កូអរដោនេចំណុចប្រសព្វរវាងបន្ទាត់$(d)$ និង $(ABC)$។

## ដំណោះស្រាយ

៤៥. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានពីរចំណុច$A(1,1,1),B(0,-2,1)$។

ក. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(AB)$។

ខ. គណនា $\overrightarrow{OA}\times\overrightarrow{OB}$។ គណនាផ្ទៃក្រឡាត្រីកោណ$OAB$។ រកសមីការប្លង់$(OBA)$។

គ. រកសមីការស្វ៊ែដែលមានអង្កត់ផ្ចិត$AB$។

## ដំណោះស្រាយ

៤៦. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(2,0,2),B(1,2,0)$ និង $C(0,2,3)$។

ក. ចូរសង់ត្រីកោណ$ABC$។

ខ. គណនា $AB$ និង $AC$ រួចរកផ្ទៃក្រឡានៃត្រីកោណ$ABC$។

គ. គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$។ ទាញថាចំណុច$A,B$ និង $C$ មិនស្ថិតនៅលើបន្ទាត់តែមួយ រួចគណនាផ្ទៃក្រឡានៃត្រីកោណនេះ។

ឃ. កំណត់សមីការប្លង់$(ABC)$។

ង. រកមាឌតេត្រា$OABC$។ ទាញរកចម្ងាយពី$O$ទៅប្លង់$(ABC)$។

## ដំណោះស្រាយ

៤៧. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(3,2,0)$ និង $K(0,-1,3)$។

ក. រកសមីការប្លង់$(P)$ដែលកាត់តាមចំណុច$A$ហើយកែងនឹងបន្ទាត់$(AK)$។

ខ. គេមាន $B(5,0,0),C(0,5,0)$ និង $D(0,0,-5)$។ ផ្ទៀងផ្ទាត់ថា$B,C$ និង $D$ នៅលើប្លង់$P$។

គ. គណនាផ្ទៃក្រឡានៃត្រីកោណ$BCD$។

ឃ. គណនា$AK$រួចរកមាឌនៃត្រាអ៊ែត$KBCD$។

## ដំណោះស្រាយ

៤៨. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(0,2,2)$ និងបន្ទាត់$(D)$ មានសមីការប៉ារ៉ាម៉ែត្រ$x=1+t, y=1-t, z=2-t, t\in\mathbb{R}$។

ក. បង្ហាញថាប្លង់ $(\alpha): x-y-z+4=0$ កាត់តាមចំណុច$A$ហើយកែងនឹងបន្ទាត់$(D)$។

ខ. ប្លង់$(\alpha)$ កាត់អ័ក្ស$\overrightarrow{ox}$ត្រង់$M$ កាត់អ័ក្ស$\overrightarrow{oy}$ត្រង់$N$ កាត់អ័ក្ស$\overrightarrow{oz}$ត្រង់$P$ ។ រកកូអរដោនេនៃចំណុច$M,N$ និង $P$ រួចសង់ចំណុច$A,M,N,P$។

គ. បង្ហាញថា$\triangle MNP$ជាត្រីកោណសម័ង្ស។

ឃ. គណនា $\overrightarrow{MP}\cdot\overrightarrow{MN}$រួចគណនាផ្ទៃក្រឡានៃត្រីកោណ$MNP$។

## ដំណោះស្រាយ

៤៩. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(1,1,0), B(0,2,2)$ និងបន្ទាត់ $C(1,-2,3)$។

ក. គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$។ ទាញថាចំណុច $A,B$ និង $C$ មិនស្ថិតនៅលើបន្ទាត់តែមួយ។

ខ. រកសមីការប្លង់ $(P)$ ដែលកាត់តាមចំណុច $A,B$ និង $C$។

គ. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(L)$ ដែលកាត់តាមចំណុច $D(1,-2,0)$ ហើយកែងនឹងប្លង់ $(P)$។ រកកូអរដោនេចំណុចប្រសព្វរវាងប្លង់ $(P)$ និងបន្ទាត់ $(L)$។

ឃ. រកសមីការស្វ៊ែដែលកាត់តាមចំណុច $A,B,C$ និង $D$។

## ដំណោះស្រាយ

៥០. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(2,0,1),B(0,1,3)$ និង$C(1,2,0)$។

ក. ចូរដៅចំណុច$A,B$ និង $C$។

ខ. គណនាផលគុណវ៉ិចទ័រ $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$។ ទាញថាចំណុច$A,B$និង $C$មិនស្ថិតនៅលើបន្ទាត់តែមួយ។ រួចគណនាផ្ទៃក្រឡាត្រីកោណ$ABC$។

គ. រកសមីការប្លង់$(ABC)$ដែលកាត់តាមចំណុច$A$ ហើយមានវ៉ិចទ័រណរម៉ាល់ $\vec{n}$។

ឃ. គណនា $(\overrightarrow{AB}\times\overrightarrow{AC})\cdot\overrightarrow{AO}$។ រកមាឌតេត្រាអ៊ែត$OABC$។

## ដំណោះស្រាយ

មេរៀនទី ៣ មេរៀនទី៣ អនុវត្តន៍នៃផលគុណវ៉ិចទ័រ

៥១. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(1,0,-2),B(0,2,0)$ និង$C(0,0,3)$។

ក. គណនាផលគុណវ៉ិចទ័រ $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$។

ខ. រកសមីការប្លង់$(ABC)$។ កំណត់ចម្ងាយពីគល់ $O$ទៅប្លង់$(ABC)$។

គ. កំណត់សមីការស្វ៊ែ$(S)$ដែលមានអង្កត់ផ្ចិត$AB$។ កំណត់សមីការប្លង់$(P)$ដែលប៉ះនិងស្វ៊ែ$(S)$ ត្រង់$A$។

## ដំណោះស្រាយ

៥២. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(1,0,1)$ និង$\overrightarrow{AB}(-1,2,1)$។

ក. គណនាកូអរដោនេចំណុច $B$។រកសមីការប្លង់$(P)$ដែលកាត់តាម$A$ហើយកែងនឹង$\overrightarrow{AB}$។

ខ. គេឱ្យចំណុច $C(2,1,0)$និង $D(1,3,1)$ ។ រកកូអរដោនេវ៉ិចទ័រ$\overrightarrow{AB}$ និង $\overrightarrow{CD}$។ គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\cdot\overrightarrow{AC}$ រួចបង្ហាញថា$ABCD$ជាចតុកោណកែង។

គ. គណនា $\overrightarrow{AB}\times\overrightarrow{AC}$។ទាញរកក្រឡាផ្ទៃចតុកោណ$ABDC$។

ឃ. រកមាឌចតុមុខ$OABC$។ទាញរកចម្ងាយពី $O$ទៅប្លង់$(ABC)$។

## ដំណោះស្រាយ

៥៣. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(2,0,1),B(0,1,3)$ និង$C(0,3,2)$។

ក. រកកូអរដោនេវ៉ិចទ័រ$\overrightarrow{AB}$ និង $\overrightarrow{BC}$។ បង្ហាញថា$\overrightarrow{AB}$ និង $\overrightarrow{BC}$ ជាវ៉ិចទ័រអរតូកូណាល់គ្នា។

ខ. គណនាផលគុណ $\overrightarrow{AB}\times\overrightarrow{BC}$។

គ. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(d)$ដែលកាត់តាមចំណុច $C$ហើយស្របនឹងវ៉ិចទ័រ$\overrightarrow{AB}$។

ឃ. រកសមីការប្លង់$(P)$ដែលកាត់តាមចំណុច$A$ហើយកែងនឹងវ៉ិចទ័រ$\overrightarrow{BC}$។

ង. រកសមីការស្វ៊ែ$(S)$ដែលមានអង្កត់ផ្ចិត$AC$។ ផ្ទៀងផ្ទាត់ថាចំណុច$B$នៅលើស្វ៊ែ$(S)$។

## ដំណោះស្រាយ

៥៤. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(1,1,1),B(2,0,3),C(-1,2,0)$ និង$D(2,4,2)$។

ក. គណនាផលគុណ $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$។ គណនាផ្ទៃក្រឡានៃត្រីកោណ$ABC$។

ខ. សមីការប្លង់$(ABC)$។ រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$ដែលកាត់តាមចំណុច$D$ហើយកែងនឹងប្លង់$(ABC)$។

គ. គណនា $\overrightarrow{AB}\cdot\overrightarrow{AD}$ និង $\overrightarrow{AC}\cdot\overrightarrow{AD}$ ។ ទាញថា $DA$ជាកម្ពស់នៃតេត្រាអ៊ែត$ABCD$។

ឃ. គណនាប្រវែង$DA$រួចគណនាមាឌនៃតេត្រាអ៊ែត$ABCD$។

## ដំណោះស្រាយ

៥៥. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$S(0,0,3)$ និង$\vec{u}(1,1,1)$។

ក. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$D$ដែលកាត់តាមចំណុច$S$ហើយស្របនឹងវ៉ិចទ័រ $\vec{u}$។

ខ. $M(x,y,z)$ ជាចំណុចនៅក្នុងតម្រុយ $(O,\vec{i},\vec{j},\vec{k})$។ គណនាផលគុណស្កាលែ$\vec{u}\cdot\overrightarrow{SM}$។ កំណត់សមីការមួយដែលជាប់ទាក់ទង$x,y,z$ដើម្បីឱ្យ$\overrightarrow{SM}$អរតូកូណាល់នៃ$\vec{u}$។ តើសំណុំចំណុច$M$ជាអ្វី?

គ. គេឱ្យចំណុច $A(3,0,0)$ និង $B(0,3,0)$។ បង្ហាញថា$SAB$ជាត្រីកោណសម័ង្ស។

ឃ. គណនាផលគុណ $\overrightarrow{SA}\times\overrightarrow{SB}$។ គណនាផ្ទៃនៃត្រីកោណ$SAB$។

ង. រកសមីការស្វ៊ែដែលមានផ្ចិត$O$ហើយកាត់តាមចំណុច$S,A$ និង $B$។

## ដំណោះស្រាយ

៥៦. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(-1,1,0),B(2,0,1),C(1,2,2),D(0,1,-2)$ និង$\vec{u}(x,y,z)$។

ក. កំណត់ទំនាក់ទំនង$x,y,z$ដើម្បីឱ្យ$\overrightarrow{AM}$ កែងនឹង $\overrightarrow{BM}$។ តើសំណុំនៃចំណុច$M$ ជាអ្វី?

ខ. គណនា $\overrightarrow{BC}\times\overrightarrow{BD}$។ រកចំនួនពិត$m$ដើម្បីឱ្យផ្ទៃក្រឡា$S$នៃត្រីកោណ$BCD$ផ្ទៀងផ្ទាត់ $S=\sqrt[3]{e^m}$។

គ. រកសមីការប្លង់$(BCD)$។រកកូអរដោនេប្រសព្វ$N$រវាងប្លង់$(BCD)$ និងបន្ទាត់$\frac{x-1}{1}=\frac{y+1}{-1}=\frac{z}{1}$។

ឃ. គណនាចម្ងាយពីចំណុច$A$ទៅប្លង់$(BCD)$រួចទាញរកមាឌនៃតេត្រាអ៊ែត$ABCD$។

## ដំណោះស្រាយ

៥៧. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានប្លង់ពីរ $(P): 3x+4y+6z-12=0$ និង $(Q): x+y+z=0$។

ក. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(D)$ ដែលជាប្រសព្វរវាងប្លង់ $(P)$ និង $(Q)$ ដោយយក $z=t$ ជាប៉ារ៉ាម៉ែត្រ ($t$ ជាចំនួនពិត)។ បញ្ជាក់កូអរដោនេវ៉ិចទ័រប្រាប់ទិស $\vec{u}$ នៃបន្ទាត់ $(D)$។

ខ. តាង $\vec{p}$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(P)$ និង $\vec{q}$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(Q)$។ គណនាផលគុណនៃ $\vec{p}\times\vec{q}$។ បង្ហាញថាវ៉ិចទ័រ $\vec{p}\times\vec{q}$ ស្របនឹងវ៉ិចទ័រ $\vec{u}$។

គ. យក $A, B$ និង $C$ ជាប្រសព្វរវាងប្លង់ $(P)$ និង អ័ក្ស $\overrightarrow{ox}, \overrightarrow{oy}, \overrightarrow{oz}$ រៀងគ្នា។ រកកូអរដោនេនៃចំណុច $A, B$ និង $C$។ គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$។

ឃ. គណនាចម្ងាយ $d$ ពីចំណុច $O$ ទៅប្លង់ $(P)$។ គណនាមាឌតេត្រាអ៊ែត $OABC$។

## ដំណោះស្រាយ

៥៨. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(2,0,0),B(2,3,0)$ និង$C(0,0,2)$។

ក. ដៅចំណុច$A,B$ និង $C$។ រកសមីការស្វ៊ែរ$S$ដែលមានអង្កត់ផ្ចិត$AC$។

ខ. គណនា $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$។ ទាញបញ្ជាក់ថា$A\neq(BC)$។គណនាផ្ទៃក្រឡាត្រីកោណ$ABC$។

គ. គណនាផលគុណស្កាលែ$\overrightarrow{AB}\cdot\overrightarrow{AC}$។ ទាញបញ្ជាក់ថា$ABC$ជាត្រីកោណកែងត្រង់$A$។

ឃ. រកសមីការប្លង់$P$ដែលកាត់តាមចំណុច$C$ ហើយមានវ៉ិចទ័រណរម៉ាល់$\vec{n}$។

ង. រកកូអរដោនេចំណុចប្រសព្វរវាងប្លង់$P$និង បន្ទាត់$(L): x=2t, y=1+3t, z=-t \quad (t\in\mathbb{R})$។

## ដំណោះស្រាយ

**៥៩**. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(2,2,0),B(0,2,2)$ និង$C(1,0,1)$។

**ក**. ដៅចំណុច$A,B$ និង $C$។ រកសមីការស្វ៊ែរ$S$ដែលមានអង្កត់ផ្ចិត$AB$។ រកកូអរដោនេចំណុចប្រសព្វរវាងស្វ៊ែរ$S$និង បន្ទាត់$(d)$: $x=1+t, y=1, z=1+t, \quad t\in\mathbb{R}$។

**ខ**. រកកូអរដោនេវ៉ិចទ័រ $\vec{n}=\overrightarrow{CA}\times\overrightarrow{CB}$។ គណនាផ្ទៃក្រឡានៃ$\triangle ABC$។ រកសមីការប្លង់$(ABC)$។

**គ**. ប្លង់$(ABC)$ជួប$\overrightarrow{ox}$ ត្រង់$M$ និង ជួប$\overrightarrow{oz}$ ត្រង់$N$។ រកកូអរដោនេចំណុច$M$ និង $N$។ បង្ហាញថា$\overrightarrow{AB}=\overrightarrow{MN}$ និង $\overrightarrow{MA}\cdot\overrightarrow{MN}=0$។ ទាញបញ្ជាក់ថា$ABMN$ជាចតុកោណកែង។

**ឃ**. គណនាចម្ងាយពីចំណុច$D(0,2,0)$ទៅប្លង់ $(ABC)$។ ទាញរកមាឌតេត្រាអ៊ែត$DBCA$។

## ដំណោះស្រាយ

៦០. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(1,2,-2),B(2,3,-2),C(0,3,-2)$ និង$D(1,2,-2+\sqrt{2})$។

ក. ចូរដៅកំពូលតេត្រាអ៊ែត $A,B,C,D$ នៃតេត្រាអ៊ែត$ABCD$។

ខ. បង្ហាញថា$AB=AC=AD$ហើយបង្ហាញថាបន្ទាត់$(AB),(AC),(AD)$កែងគ្នាពីរៗ។

គ. បង្ហាញថា$AD$ជាកម្ពស់ចំពោះបាតនៃតេត្រាអ៊ែត$ABCD$ហើយទាញរកមាឌតេត្រាអ៊ែត$ABCD$។

ឃ. គណនាផលគុណវ៉ិចទ័រ $\vec{N}=\overrightarrow{BC}\times\overrightarrow{BD}$ ។ និងផ្ទៃក្រឡានៃត្រីកោណ$BCD$។ រកសមីការប្លង់$(BCD)$។

ង. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$ កាត់តាមចំណុច$A$ហើយកែងប្លង់$(BCD)$ត្រង់ចំណុច$H$។ រកកូអរដោនេនៃចំណុច$H$។

## ដំណោះស្រាយ

៦១. គេឱ្យប្រលេពីប៉ែតកែង$ABCD-EFGH$គេមាន$\overrightarrow{DA}=i,\overrightarrow{DC}=3\vec{j}$ និង $\overrightarrow{DH}=2\vec{k}$។យក$(D,\vec{i},\vec{j},\vec{k})$ ជាតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន។

ក. គូសរូបប្រលេពីប៉ែតកែង $ABCD-EFGH$ ។បញ្ជាក់កូអរដោនេចំណុច$A,B,C,E,F,G,H$។

ខ. គណនាផលគុណវ៉ិចទ័រ $\overrightarrow{AC}\times\overrightarrow{AH}$រួចសរសេរសមីការប្លង់$(ACH)$។

គ. $d_1$ជាចម្ងាយពីចំណុច$F$ទៅប្លង់$(ACH)$និង $d_2$ជាចម្ងាយពីចំណុច$D$ទៅប្លង់$(ACH)$។ បង្ហាញថា $d_1=2d_2$។

ឃ. ប្រៀបធៀបមាឌ$V_1$ នៃចតុមុខ$FACH$ និង មាឌ$V_2$នៃចតុមុខ$DACH$។

ង. គណនាផ្ទៃក្រឡានៃ$\triangle ACH$រួចគណនាមាឌ$V_2$។ ទាញរកមាឌ$V_1$។

## ដំណោះស្រាយ

៦២. នៅក្នុង$(O,\vec{i},\vec{j},\vec{k})$ ជាតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន គេមានចំណុច$A(-2,0,1);B(0,10,3)$ ;$C(2,0,-1)$ និង $D(5,3,-1)$។

ក. រកសមីការប្លង់$(P)$ដែលកាត់តាមចំណុច$A,B,C$។

ខ. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$ដែលកាត់តាមចំណុច$D$ហើយកែងនឹងប្លង់$(P)$។

គ. រកសមីការស្វ៊ែរ$S$មានផ្ចិត$D$ហើយប៉ះនឹងប្លង់$(P)$។

## ដំណោះស្រាយ

៦៣. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(1,0,0),B(0,1,0)$ និង$C(0,0,1)$។

ក. បង្ហាញថា$\triangle ABC$ជាត្រីកោណសម័ង្ស។

ខ. គណនាផលគុណនៃពីរវ៉ិចទ័រ$\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$។

គ. រកសមីការស្វ៊ែ$(S)$ដែលមានអង្កត់ផ្ចិត$AC$។

ឃ. រកសមីការប្លង់$(P)$ដែលប៉ះស្វ៊ែ$(S)$ត្រង់ចំណុច$C$។

## ដំណោះស្រាយ

៦៤. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(2,2,6),B(2+2\sqrt{2},0,4)$ និង$C(2+2\sqrt{2},4,4)$។

ក. គណនា $AB,AC$ និង $\angle BAC$រួចរកប្រភេទនៃត្រីកោណ$ABC$។

ខ. គណនា $\overrightarrow{AB}\times\overrightarrow{AC}$ និងផ្ទៃក្រឡាត្រីកោណ$ABC$។

គ. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$កែងនឹងប្លង់$(ABC)$ ត្រង់ចំណុច$A$។

ឃ. ស្វ៊ែ$S$មានអង្កត់ផ្ចិត$AB$។រកសមីការប្លង់$P$ប៉ះស្វ៊ែ$S$ត្រង់ចំណុច$A$។

## ដំណោះស្រាយ

៦៥. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$M(-1,0,1),N(0,1,2),P(1,2,-1)$ និង $(\alpha): x-2y+z-4=0$។

ក. គណនា $\overrightarrow{MN}\times\overrightarrow{MP}$ និងផ្ទៃក្រឡាត្រីកោណ$MNP$។

ខ. រកសមីការប្លង់$\beta$កាត់តាមចំណុច$M,N,P$។ គណនាចម្ងាយពីចំណុច$O$ទៅប្លង់$(\beta)$។ រកមាឌតេត្រាអ៊ែត$ONMP$។

គ. រកសមីការស្វ៊ែរ$S$មានផ្ចិត$M$ហើយកាត់តាមចំណុច$N$។ តើប្លង់$(\alpha)$កាត់ស្វ៊ែរ$S$ដែរឬទេ?

## ដំណោះស្រាយ

៦៦. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមាន$(P): x+2y+2z+5=0$ និង$(S): x^2+y^2+z^2-2x-4y+4z=0$។

ក. កំណត់កូអរដោនេផ្ចិត និង កាំនៃស្វ៊ែ$(S)$។

ខ. បង្ហាញថាប្លង់ $P$កាត់ស្វ៊ែ $(S)$។

គ. រកគ្រប់សមីការប្លង់ដែលស្របនឹងប្លង់$P$ហើយប៉ះស្វ៊ែ$S$។

## ដំណោះស្រាយ

៦៧. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(1,0,2);B(-1,1,4)$ និង$C(5,-1,3)$។

ក. គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$។រកសមីការប្លង់$(ABC)$។

ខ. កំណត់កូអរដោនេនៃចំណុច$D$ដើម្បីឱ្យ$ABDC$ជាប្រលេឡូក្រាម។
គណនាផ្ទៃក្រឡានៃប្រលេឡូក្រាម$ABDC$។

គ. គេឱ្យចំណុច$F(3,10,-2)$។ បង្ហាញថាបន្ទាត់$(OF)$កែងនឹងប្លង់$(ABC)$។

ឃ. រកមាឌតេត្រាអ៊ែត$FABC$។ ទាញរកកម្ពស់$h$គូសចេញពីកំពូល$F$នៃតេត្រាអ៊ែត។

## ដំណោះស្រាយ

៦៨. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(2,2,2);B(2,0,1)$ និង$C(4,1,-1)$។

ក. គណនាផលគុណវ៉ិចទ័រ $\overrightarrow{BA}\cdot\overrightarrow{BC}$។បង្ហាញថា$(ABC)$ជាត្រីកោណកែង។

ខ. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$កាត់តាមចំណុច$A$ហើយស្របនឹងវ៉ិចទ័រ$BC$។

គ. រកសមីការ$P$កាត់តាមចំណុច$C$ហើយកែងនឹងបន្ទាត់$(L)$។ រកកូអរដោនេចំណុចប្រសព្វរវាងបន្ទាត់$(L)$ និង ប្លង់$P$។

ឃ. រកសមីការស្វ៊ែ$S$មានផ្ចិត$I(1,1,1)$និង កាំ$r=\sqrt{10}$។ រកកូអរដោនេចំណុចប្រសព្វរវាងបន្ទាត់$L$និង ស្វ៊ែ$S$។ រកចម្ងាយពីចំណុច$I$ទៅប្លង់$P$។

## ដំណោះស្រាយ

៦៩. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(1,1,1);B(-1,-2,-1)$ និង$C(1,2,0)$។

ក. គណនាផលគុណវ៉ិចទ័រ $\overrightarrow{BA}\times\overrightarrow{BC}$។ រកសមីការប្លង់$(\alpha)$ដែលកាត់តាមចំណុច$A,B$និង $C$។

ខ. គណនាផ្ទៃក្រឡានៃត្រីកោណ$ABC$។ គណនាចម្ងាយពីគល់$O$នៃតម្រុយទៅប្លង់$(\alpha)$។ រកមាឌតេត្រាអ៊ែត$OABC$។

គ. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$ដែលកែងនឹងប្លង់$(\alpha)$ត្រង់ $A$។ រកចម្ងាយពីចំណុច$C$ទៅបន្ទាត់$(L)$។

ឃ. រកសំណុំនៃចំណុច $M$ដែលផ្ទៀងផ្ទាត់$MA^2-MB^2=2$។

## ដំណោះស្រាយ

៧០. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(-2,0,1);B(0,10,3);C(2,0,-1)$ និង$D(5,3,-1)$។

ក. គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$។ រកផ្ទៃក្រឡានៃត្រីកោណ$ABC$។

ខ. រកសមីការប្លង់$P$កាត់តាមចំណុច$A,B,C$។

គ. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$កាត់តាមចំណុច$D$ហើយកែងនឹងប្លង់$P$។

ឃ. រកសមីការស្វ៊ែ$S$ មានផ្ចិត$D$ហើយប៉ះនឹងប្លង់$P$។

## ដំណោះស្រាយ

៧១. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(0,2,0);B(1,0,0)$ និង$C(0,0,3)$។

ក. រកកូអរដោនេនៃវ៉ិចទ័រ $\vec{n}=\overrightarrow{CA}\cdot\overrightarrow{CB}$។ រកផ្ទៃក្រឡានៃត្រីកោណ$ABC$។

ខ. រកសមីការប្លង់$P$កាត់តាមចំណុច$O$ ហើយស្របនឹងប្លង់$ABC$។

គ. គណនា $(\overrightarrow{OA}\times\overrightarrow{OC})\cdot\overrightarrow{OB}$។ ទាញរកមាឌចតុមុខ$OABC$និងចម្ងាយពីកំពូល$O$មកប្លង់បាត$ABC$

## ដំណោះស្រាយ

៧២. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(0,1,1);B(2,0,2)$ និង$C(3,-1,-1)$។

ក. គណនា$\overrightarrow{AB}\times\overrightarrow{AC}$ រួចបង្ហាញថាចំណុច $A,B,C$ មិនស្ថិតនៅលើបន្ទាត់តែមួយ។

ខ. រកសមីការប្លង់$(P)$ដែលកាត់តាមដែលកាត់តាមចំណុច$A,B,C$។

គ. បង្ហាញថា$O$មិនស្ថិតនៅលើប្លង់$P$។ គណនាចម្ងាយពីគល់$O$ទៅប្លង់$P$។ គណនាផ្ទៃក្រឡានៃត្រីកោណ $ABC$រួចទាញរកមាឌនៃតេត្រាអ៊ែត$OABC$។

ឃ. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$ដែលកាត់តាមចំណុច$D(1,1,2)$ហើយកែងនឹងប្លង់$P$។រកកូអរដោនេចំណុចប្រសព្វ$M$រវាងប្លង់$(P)$ និង បន្ទាត់$(L)$។

ង. រកសមីការស្វ៊ែរ$S$ដែលមានអង្កត់ផ្ចិត$AB$។

## ដំណោះស្រាយ

៧៣. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(1,0,0);B(0,2,0)$ និង $C(0,0,3)$។

ក. គណនា $\overrightarrow{AB}\times\overrightarrow{BC}$។ គណនាផ្ទៃក្រឡាត្រីកោណ $ABC$ ។

ខ. រកសមីការប្លង់ $(ABC)$។ គណនាចម្ងាយពី $OH$ ពីគល់ $O$ ទៅប្លង់ $(ABC)$។
ផ្ទៀងផ្ទាត់ថា $\dfrac{1}{OH^2}=\dfrac{1}{OA^2}+\dfrac{1}{OB^2}+\dfrac{1}{OC^2}$។

គ. រកកូអរដោនេនៃចំណុច $H$។ គណនាមាឌតេត្រាអ៊ែត $OABC$។

ឃ. រកសមីការស្វ៊ែរដែលកាត់តាមចំណុច $OABC$។

## ដំណោះស្រាយ

៧៤. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$I(1,2,-2)$ និងប្លង់$(P): 2x+2y+z+5=0$។

ក. សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$ដែលកាត់តាម$I$ហើយកែងនឹងប្លង់$(P)$។

ខ. រកចំណុចប្រសព្វ$J$រវាងប្លង់$(P)$និង បន្ទាត់$(L)$។

គ. គេឱ្យ$S$ជាស្វ៊ែដែលមានផ្ចិត$I$។ ដោយដឹងថាប្លង់$(P)$កាត់ស្វ៊ែ$(S)$មានរង្វង់មួយមានមរិមាត្រ$8\pi$ ចូររកសមីការស្វ៊ែ$(S)$។

ឃ. ស្រាយថាស្វ៊ែ$S$ប៉ះទៅនឹងបន្ទាត់$\dfrac{x-1}{1}=\dfrac{y+3}{2}=\dfrac{z}{2}$។

## ដំណោះស្រាយ

៧៥. ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(-1,3,2);B(-9,4,9)$ និងប្លង់$(P): 2x-y+z+1=0$។

ក. សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(L)$ដែលកាត់តាម$A$ហើយកែងនឹងប្លង់$(P)$។

ខ. រកចំណុចប្រសព្វ$H$រវាងប្លង់$(P)$និង បន្ទាត់$(L)$។

គ. រកកូអរដោនេចំណុច$A'$ ឆ្លុះនឹងចំណុច$A$ធៀបនឹងប្លង់$(P)$។

ឃ. រកចំណុចប្រសព្វ$K$រវាងប្លង់$(P)$នឹងបន្ទាត់$(A'B)$។

## ដំណោះស្រាយ

# លំហាត់ដែលធ្លាប់ចេញប្រឡងមធ្យមសិក្សាទុតិយភូមិនាឆ្នាំកន្លងមក

១. (២០០២) នៅក្នុងតម្រុយអរតូណរម៉ាល់$(O,\vec{i},\vec{j},\vec{k})$ ដែលមានទិសដៅវិជ្ជមានគេឱ្យចំណុច $A(3,0,1);B(2,4,0)$ និង $C(0,3,3)$។(បេក្ខជនមិនចាំបាច់សង់រូបទេ)។

ក. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(D)$ដែលកាត់តាមចំណុច$O$និងមានវ៉ិចទ័រប្រាប់ទិស$\vec{u}(1,1,1)$។

ខ. គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$។ទាញថាចំណុច$A,B,C$ មិនរត់ត្រង់គ្នា។

គ. រកសមីការប្លង់ $(ABC)$ដោយយកវ៉ិចទ័រ$\overrightarrow{AB}\times\overrightarrow{AC}$ ជាវ៉ិចទ័រណរម៉ាល់។

ឃ. រកផ្ទៃក្រឡាត្រីកោណ$ABC$។

ង. រកកូអរដោនេចំណុចប្រសព្វរវាងបន្ទាត់$(D)$ និង ប្លង់ $(ABC)$។

## ដំណោះស្រាយ

២. (២០០៣) នៅក្នុងតម្រុយអរតូណរម៉ាល់$(O,\vec{i},\vec{j},\vec{k})$ ដែលមានទិសដៅវិជ្ជមាន (ឯកតាលើអ័ក្ស$1cm$) ចូរដៅចំណុច$A(2,0,2);B(1$
និង $C(0,2,3)$។

ក. សរសេរសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់$(D)$ដែលកាត់តាម$A$ហើយស្របនឹងវ៉ិចទ័រ$\overrightarrow{BC}$។

ខ. គណនា $|\overrightarrow{AB}|$ និង $|\overrightarrow{AC}|$។ រួចប្រាប់ប្រភេទត្រីកោណ$ABC$។

គ. គណនាផលគុណវ៉ិចទ័រ $\overrightarrow{AB}\times\overrightarrow{AC}$។ ទាញថាចំណុច $A,B,C$មិនស្ថិតនៅលើបន្ទាត់តែមួយ។ រកសមីការប្លង់ $(ABC)$។ គណនាផ្ទៃក្រឡាត្រីកោណ$ABC$។

ឃ. រកមាឌតេត្រាអែត$OABC$។ទាញរកចម្ងាយពីចំណុច$O$ទៅប្លង់ $(ABC)$។

## ដំណោះស្រាយ

៣. (២០០៤) នៅក្នុងតម្រុយអរតូណរម៉ាល់$(O,\vec{i},\vec{j},\vec{k})$ ដែលមានទិសដៅវិជ្ជមាន(ឯកតាលើអ័ក្ស$1cm$) គេឲ្យចំណុច$A(3,2,0)$, $K(0$

ក. រកសមីការប្លង់$(P)$ ដែលកាត់តាម$A$ហើយកែងនឹងបន្ទាត់$AK$។

ខ. គេឱ្យចំណុច$B(5,0,0)$;$C(0,5,0)$ និង $D(0,0,-5)$។ ផ្ទៀងផ្ទាត់ថាចំណុច$B,C$ និង $D$ជាចំណុចនៅលើប្លង់$P$។

គ. គណនាផ្ទៃក្រឡាត្រីកោណ$BCD$។

ឃ. គណនាប្រវែង$AK$រួចទាញរកមាឌនៃតេត្រាអែត$KBCD$។

## ដំណោះស្រាយ

មេរៀនទី ៣ មេរៀនទី៣ អនុវត្តន៍នៃផលគុណវ៉ិចទ័រ

៤. (២០០៥) ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(0,2,2)$ និងបន្ទាត់$(D)$ មានសមីការប៉ារ៉ាម៉ែត្រ$x=1+t, y=1-t, z=2-t, t\in\mathbb{R}$។

ក. បង្ហាញថាប្លង់ $(\alpha): x-y-z+4=0$ កាត់តាមចំណុច$A$ហើយកែងនឹងបន្ទាត់$(D)$។

ខ. ប្លង់$(\alpha)$ កាត់អ័ក្ស$\overrightarrow{ox}$ត្រង់$M$ កាត់អ័ក្ស$\overrightarrow{oy}$ត្រង់$N$ កាត់អ័ក្ស$\overrightarrow{oz}$ត្រង់$P$ ។ រកកូអរដោនេនៃចំណុច$M,N$ និង $P$ រួចសង់ចំណុច$A,M,N,P$។

គ. បង្ហាញថា$\triangle MNP$ជាត្រីកោណសម័ង្ស។

ឃ. គណនា $\overrightarrow{MP}\cdot\overrightarrow{MN}$រួចគណនាផ្ទៃក្រឡានៃត្រីកោណ$MNP$។

## ដំណោះស្រាយ

៥. (២០០៦) ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច$A(1,0,1)$ និង$\overrightarrow{AB}=(-1,2,1)$។

ក. គណនាកូអរដោនេនៃចំណុច$B$។ រកសមីការប្លង់$(P)$ដែលកាត់តាមចំណុច$A$និង មានវ៉ិចទ័រណរម៉ាល់$\overrightarrow{AB}$។

ខ. គេឱ្យ$C(2,1,0)$ និង $D(1,3,1)$។ រកកូអរដោនេវ៉ិចទ័រ$\overrightarrow{AC}$ និង $\overrightarrow{CD}$។ គណនា $\overrightarrow{AB}\cdot\overrightarrow{AC}$ រួចបង្ហាញថា$ABCD$ជាចតុកោណកែង។

គ. គណនា $\overrightarrow{AB}\times\overrightarrow{AC}$ ទាញរកផ្ទៃក្រឡានៃចតុកោណ$ABCD$។

ឃ. រកមាឌចតុមុខ$OABC$។ ទាញរកចម្ងាយពីគល់$O$ទៅប្លង់$ABC$។

## ដំណោះស្រាយ

គ. គេឱ្យចំណុច $A(3,0,0)$ និង $B(0,3,0)$។ បង្ហាញថា $\triangle SAB$ ជាត្រីកោណសម័ង្ស។

ឃ. គណនា $\overrightarrow{SA}\times\overrightarrow{SB}$។ ទាញរកផ្ទៃក្រឡាត្រីកោណ $SAB$។

ង. រកសមីការស្វ៊ែដែលមានផ្ចិត $O$ ហើយកាត់តាមចំណុច $S,A$ និង $B$។

### ដំណោះស្រាយ

ក $(D):\begin{cases}x=t\\y=t\\z=3+t\end{cases}\quad(t\in\mathbb{R})$

ខ $\overrightarrow{SM}=(x,y,z-3)\implies\vec{u}\cdot\overrightarrow{SM}=1(x)+1(y)+1(z-3)=\boxed{x+y+z-3}$

$\overrightarrow{SM}\perp\vec{u}\iff\vec{u}\cdot\overrightarrow{SM}=0\iff\boxed{x+y+z-3=0}$

សំណុំចំណុច $M$ គឺជា **ប្លង់មួយកាត់តាមចំណុច $S$ ហើយកែងនឹងវ៉ិចទ័រ $\vec{u}$**។

គ $SA=\sqrt{3^2+0+(-3)^2}=\sqrt{18}=3\sqrt{2}$

$SB=\sqrt{0+3^2+(-3)^2}=\sqrt{18}=3\sqrt{2}$

$AB=\sqrt{(-3)^2+3^2+0}=\sqrt{18}=3\sqrt{2}$

ដោយ $SA=SB=AB=3\sqrt{2}\implies$ $\boxed{\triangle SAB \text{ ជាត្រីកោណសម័ង្ស}}$

ឃ $\overrightarrow{SA}=(3,0,-3)$, $\overrightarrow{SB}=(0,3,-3)$

$\overrightarrow{SA}\times\overrightarrow{SB}=(0-(-9),-(-9-0),9-0)=\boxed{(9,9,9)}$

$S_{SAB}=\frac{1}{2}\|\overrightarrow{SA}\times\overrightarrow{SB}\|=\frac{1}{2}\sqrt{81+81+81}=\boxed{\frac{9\sqrt{3}}{2}\text{ (ឯកតាផ្ទៃ)}}$

ង $OS=3, OA=3, OB=3\implies R=3$

សមីការស្វ៊ែផ្ចិត $O(0,0,0)$ កាំ $R=3$៖ $\boxed{x^2+y^2+z^2=9}$

## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០០៨

ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមាន $A(-1,1,0),B(2,0,1),C(1,2,2),D(0,1,-2)$។

ក. កំណត់ទំនាក់ទំនង $x,y,z$ ដើម្បីឱ្យ $\overrightarrow{AM}\perp\overrightarrow{BM}$។ តើសំណុំនៃចំណុច $M$ ជាអ្វី?

ខ. គណនា $\overrightarrow{BC}\times\overrightarrow{BD}$។ រកចំនួនពិត $m$ ដើម្បីឱ្យផ្ទៃក្រឡា $S$ នៃត្រីកោណ $BCD$ ផ្ទៀងផ្ទាត់ $S=\sqrt[3]{e^m}$។

គ. រកសមីការប្លង់ $(BCD)$។ រកចំណុចប្រសព្វ $N$ រវាង $(BCD)$ និងបន្ទាត់ $\frac{x-1}{1}=\frac{y+1}{-1}=\frac{z}{1}$។

ឃ. គណនាចម្ងាយពីចំណុច $A$ ទៅប្លង់ $(BCD)$ រួចទាញរកមាឌនៃតេត្រាអ៊ែត $ABCD$។

### ដំណោះស្រាយ

ក $\overrightarrow{AM}=(x+1,y-1,z),\overrightarrow{BM}=(x-2,y,z-1)$

$\overrightarrow{AM}\cdot\overrightarrow{BM}=(x+1)(x-2)+y(y-1)+z(z-1)=0$

ដូចនេះ $\boxed{x^2+y^2+z^2-x-y-z-2=0}$

សំណុំចំណុច $M$ គឺជា **ស្វ៊ែដែលមានអង្កត់ផ្ចិត** $[AB]$។

ខ $\overrightarrow{BC}=(-1,2,1),\ \overrightarrow{BD}=(-2,1,-3)$

$\overrightarrow{BC}\times\overrightarrow{BD}=(-6-1,-(3+2),-1+4)=\boxed{(-7,-5,3)}$

$S=\frac{1}{2}\|\overrightarrow{BC}\times\overrightarrow{BD}\|=\frac{\sqrt{49+25+9}}{2}=\frac{\sqrt{83}}{2}$

$S=\sqrt[3]{e^m}=e^{m/3}\implies\frac{m}{3}=\ln\left(\frac{\sqrt{83}}{2}\right)\implies$

$\boxed{m=3\ln\left(\frac{\sqrt{83}}{2}\right)}$

គ ប្លង់ $(BCD)$ កាត់ $B(2,0,1)$ មាន $\vec{n}=(-7,-5,3)$៖

$-7(x-2)-5(y-0)+3(z-1)=0$

ដូចនេះ $\boxed{(BCD):\ 7x+5y-3z-11=0}$

សមីការបន្ទាត់៖ $x=1+t,y=-1-t,z=t$

ជំនួសចូល៖ $7(1+t)+5(-1-t)-3t-11=0$

$-t-9=0\implies t=-9\implies\boxed{N(-8,8,-9)}$

ឃ ចម្ងាយពី $A(-1,1,0)$ ទៅប្លង់ $(BCD)$៖

$d(A,(BCD))=\frac{|7(-1)+5(1)-3(0)-11|}{\sqrt{7^2+5^2+(-3)^2}}=\boxed{\frac{13}{\sqrt{83}}}$

$V_{ABCD}=\frac{1}{3}S_{BCD}\cdot d=\frac{1}{3}\cdot\frac{\sqrt{83}}{2}\cdot\frac{13}{\sqrt{83}}=\boxed{\frac{13}{6}\text{ (ឯកតាមាឌ)}}$

## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០០៩

ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(2,2,0),B(0,2,2)$ និង $C(1,0,1)$។

ក. រកសមីការស្វ៊ែ $(S)$ ដែលមានអង្កត់ផ្ចិត $AB$។ រកកូអរដោនេនៃចំណុចប្រសព្វរវាងស្វ៊ែ និងបន្ទាត់ $(d): x=1+t, y=2, z=1+t$។

ខ. រក $\vec{n}=\overrightarrow{CA}\times\overrightarrow{CB}$។ គណនាផ្ទៃក្រឡាត្រីកោណ $ABC$។ រកសមីការប្លង់ $(ABC)$។

គ. ប្លង់ $(ABC)$ ជួប $Ox$ ត្រង់ $M$ និង $Oz$ ត្រង់ $N$។ រក $M,N$។ បង្ហាញថា $ABNM$ ជាចតុកោណកែង។

ឃ. រកចម្ងាយពី $D(0,2,0)$ ទៅប្លង់ $(ABC)$។ ទាញរកមាឌតេត្រាអែត $DCBA$។

### ដំណោះស្រាយ

ក ផ្ចិត $I=$ មធ្យម $AB=(1,2,1)$, កាំ $R=\frac{AB}{2}=\sqrt{2}$៖

$(S)$: $\boxed{(x-1)^2+(y-2)^2+(z-1)^2=2}$

ជំនួស $(d)$ ចូល៖ $t^2+0^2+t^2=2 \iff 2t^2=2 \implies t=\pm1$

ដូចនេះ ចំណុចប្រសព្វគឺ $\boxed{(2,2,2)}$ និង $\boxed{(0,2,0)}$

ខ $\overrightarrow{CA}=(1,2,-1)$, $\overrightarrow{CB}=(-1,2,1)$

$\vec{n}=\overrightarrow{CA}\times\overrightarrow{CB}=(2-(-2),-(1-1),2-(-2))=\boxed{(4,0,4)}$

$S_{ABC}=\frac{1}{2}\|\vec{n}\|=\frac{1}{2}\sqrt{16+0+16}=\boxed{2\sqrt{2}\text{ (ឯកតាផ្ទៃ)}}$

ប្លង់ $(ABC)$: $4(x-1)+0+4(z-1)=0 \iff \boxed{x+z-2=0}$

គ • $M=(ABC)\cap Ox(y=0,z=0) \implies \boxed{M(2,0,0)}$

• $N=(ABC)\cap Oz(x=0,y=0) \implies \boxed{N(0,0,2)}$

$\overrightarrow{AB}=(-2,0,2)$, $\overrightarrow{MN}=(-2,0,2) \implies \overrightarrow{AB}=\overrightarrow{MN}$

$\implies ABNM$ ជាប្រលេឡូក្រាម។

$\overrightarrow{AM}=(0,-2,0) \implies \overrightarrow{AB}\cdot\overrightarrow{AM}=0 \implies \angle A=90^\circ$

ដូចនេះ $\boxed{ABNM \text{ ជាចតុកោណកែង}}$

ឃ ចម្ងាយពី $D(0,2,0)$ ទៅប្លង់ $(ABC)$៖

$d(D,(ABC))=\frac{|0+0-2|}{\sqrt{1^2+0+1^2}}=\frac{2}{\sqrt{2}}=\boxed{\sqrt{2}}$

$V_{DCBA}=\frac{1}{3}S_{ABC}\cdot d=\frac{1}{3}(2\sqrt{2})\sqrt{2}=\boxed{\frac{4}{3}\text{ (ឯកតាមាឌ)}}$

## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០១០

ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(-1,2,1), B(1,-6,-1)$ និង $C(2,2,2)$។

ក. គណនា $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$។ កំណត់សមីការប្លង់ $(P)$ កាត់តាម $A,B,C$។ កំណត់សមីការប៉ារ៉ាម៉ែត្រនៃ $(d)$ កាត់តាម $J(-2,0,0)$ ទិស $\vec{u}(3,0,1)$។

ខ. រកកូអរដោនេផ្ចិត $I$ និងកាំ $r$ នៃស្វ៊ែ $x^2+y^2+z^2-2y+2z-2=0$។ រកចំណុចប្រសព្វរវាងស្វ៊ែ $(S)$ និងបន្ទាត់ $(d)$។

គ. គណនាផ្ទៃក្រឡាត្រីកោណ $ABC$។ គណនាចម្ងាយពីចំណុច $D(0,1,-1)$ ទៅប្លង់ $(P)$។

## ដំណោះស្រាយ

ក $\overrightarrow{AB}=(2,-8,-2)$, $\overrightarrow{AC}=(3,0,1)$

$\vec{n}=\overrightarrow{AB}\times\overrightarrow{AC}=(-8,-(2+6),24)=\boxed{(-8,-8,24)}$

$\vec{n}=-8(1,1,-3) \implies$ យក $(1,1,-3)$ ជាណរម៉ាល់នៃ $(P)$៖

$1(x+1)+1(y-2)-3(z-1)=0 \iff \boxed{(P): x+y-3z+2=0}$

បន្ទាត់ $(d)$: $\begin{cases} x=-2+3t \\ y=0 \\ z=t \end{cases} \quad (t\in\mathbb{R})$

ខ $x^2+(y-1)^2+(z+1)^2=2+1+1=4=2^2$

$\implies$ ផ្ចិត $\boxed{I(0,1,-1)}$, កាំ $\boxed{r=2}$

ប្រសព្វរវាង $(S)$ និង $(d)$៖

$(-2+3t)^2+(0-1)^2+(t+1)^2=4$

$4-12t+9t^2+1+t^2+2t+1=4 \iff 5t^2-5t+1=0$

$\Delta=25-20=5 \implies t=\frac{5\pm\sqrt{5}}{10}$

ដូចនេះ $\boxed{\left(-2+\frac{3(5\pm\sqrt{5})}{10}, 0, \frac{5\pm\sqrt{5}}{10}\right)}$

គ ផ្ទៃក្រឡាត្រីកោណ $ABC$៖

$S_{ABC}=\frac{1}{2}\|\vec{n}\|=\frac{1}{2}\sqrt{64+64+576}=\frac{\sqrt{704}}{2}=\boxed{4\sqrt{11}}$

ចម្ងាយពី $D(0,1,-1)$ ទៅប្លង់ $(P)$៖

$d(D,(P))=\frac{|0+1-3(-1)+2|}{\sqrt{1^2+1^2+(-3)^2}}=\frac{6}{\sqrt{11}}=\boxed{\frac{6\sqrt{11}}{11}}$

## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០១១

ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(1,2,4);B(2,-1,3)$ និង $C(-2,3,-2)$។

ក. រកសមីការស្វ៊ែ $(S)$ ដែលមានផ្ចិត $A$ និងកាំ $r=\frac{\|\overrightarrow{BC}\|}{2}$។

ខ. រកសមីការប្លង់ $(P)$ ដែលមានវ៉ិចទ័រណរម៉ាល់ $\overrightarrow{AC}$ ហើយកាត់តាមចំណុច $B$។

គ. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(d)$ ដែលកាត់តាមចំណុច $C$ ហើយមានវ៉ិចទ័រប្រាប់ទិស $\overrightarrow{AB}$។

ឃ. រកចម្ងាយ $d(B,A)$ និងចម្ងាយ $d(B,(d))$ ពីចំណុច $B$ ទៅបន្ទាត់ $(d)$។

ង. រកផ្ទៃក្រឡាប្រលេឡូក្រាម និងផ្ទៃក្រឡាត្រីកោណដែលសង់លើវ៉ិចទ័រ $\overrightarrow{BA}$ និង $\overrightarrow{BC}$។

## ដំណោះស្រាយ

ក $\overrightarrow{BC}=(-4,4,-5) \implies \|\overrightarrow{BC}\|=\sqrt{16+16+25}=\sqrt{57}$

$r=\frac{\sqrt{57}}{2} \implies r^2=\frac{57}{4}$៖

ដូចនេះ $\boxed{(S):\ (x-1)^2+(y-2)^2+(z-4)^2=\frac{57}{4}}$

ខ $\overrightarrow{AC}=(-3,1,-6)$។ ប្លង់ $(P)$ កាត់តាម $B(2,-1,3)$៖

$-3(x-2)+1(y+1)-6(z-3)=0$

ដូចនេះ $\boxed{(P):\ 3x-y+6z-25=0}$

គ $\overrightarrow{AB}=(1,-3,-1)$។ បន្ទាត់ $(d)$ កាត់តាម $C(-2,3,-2)$៖

$$(d):\begin{cases} x=-2+t \\ y=3-3t \\ z=-2-t \end{cases} \quad (t\in\mathbb{R})$$

ឃ $d(B,A)=\|\overrightarrow{AB}\|=\sqrt{1+9+1}=\boxed{\sqrt{11}}$

$\overrightarrow{CB}=(4,-4,5) \implies \overrightarrow{CB}\times\overrightarrow{AB}=(19,9,-8)$

$\|\overrightarrow{CB}\times\overrightarrow{AB}\|=\sqrt{361+81+64}=\sqrt{506}$

$d(B,(d))=\frac{\|\overrightarrow{CB}\times\overrightarrow{AB}\|}{\|\overrightarrow{AB}\|}=\frac{\sqrt{506}}{\sqrt{11}}=\boxed{\sqrt{46}}$

ង $\overrightarrow{BA}=(-1,3,1)$, $\overrightarrow{BC}=(-4,4,-5)$

$\overrightarrow{BA}\times\overrightarrow{BC}=(-19,-9,8)$

$S_{\text{ប្រលេ}}=\|\overrightarrow{BA}\times\overrightarrow{BC}\|=\boxed{\sqrt{506}\ (\text{ឯកតាផ្ទៃ})}$

$S_{\triangle}=\frac{1}{2}S_{\text{ប្រលេ}}=\boxed{\frac{\sqrt{506}}{2}\ (\text{ឯកតាផ្ទៃ})}$

## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០១២

ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមាន $M(-1,0,1), N(0,1,2), P(1,2,-1)$ និង $(\alpha): x-2y+z-4=0$។

ក. រកកូអរដោនេ $\vec{n}=\overrightarrow{MN}\times\overrightarrow{MP}$ ហើយទាញរកសមីការប្លង់ $(\beta)$ ដែលកាត់តាម $M,N$ និង $P$។

ខ. រកសមីការស្វ៊ែ $(S)$ មួយមានផ្ចិត $M$ ហើយកាត់តាមចំណុច $N$។ តើប្លង់ $(\alpha)$ ជួបស្វ៊ែ $(S)$ ឬទេ?

### ដំណោះស្រាយ

ក $\overrightarrow{MN}=(1,1,1)$, $\overrightarrow{MP}=(2,2,-2)$

$\vec{n}=\overrightarrow{MN}\times\overrightarrow{MP}=(-2-2,-(-2-2),2-2)=\boxed{(-4,4,0)}$

យក $\vec{n}_\beta=(1,-1,0)$ ជាវ៉ិចទ័រណរម៉ាល់នៃ $(\beta)$៖

$1(x+1)-1(y-0)+0(z-1)=0$

ដូចនេះ $\boxed{(\beta): x-y+1=0}$

ខ កាំ $R=MN=\sqrt{1^2+1^2+1^2}=\sqrt{3}\implies R^2=3$

សមីការស្វ៊ែ $(S)$ ផ្ចិត $M(-1,0,1)$៖

ដូចនេះ $\boxed{(S): (x+1)^2+y^2+(z-1)^2=3}$

ចម្ងាយពីផ្ចិត $M$ ទៅប្លង់ $(\alpha)$៖

$d=\frac{|-1-2(0)+1-4|}{\sqrt{1^2+(-2)^2+1^2}}=\frac{4}{\sqrt{6}}=\frac{2\sqrt{6}}{3}$

ប្រៀបធៀប៖ $d^2=\frac{16}{6}=\frac{8}{3}<3=R^2\implies d<R$

ដូចនេះ ប្លង់ $(\alpha)$ កាត់ស្វ៊ែ $(S)$ បានជាខ្សែរង្វង់មួយ។

## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០១៣

ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(1,0,1), B(0,2,2)$ និង $C(2,1,0)$។

ក. បង្ហាញថាត្រីកោណ $ABC$ ជាត្រីកោណកែងត្រង់កំពូល $A$។

ខ. គណនា $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}$ រួចរកសមីការប្លង់ $(ABC)$។

គ. រកសមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(d)$ ដែលកាត់តាមចំណុច $D(1,-1,3)$ ហើយកែងនឹងប្លង់ $(ABC)$ ត្រង់ $M$។ រកកូអរដោនេចំណុច $M$។

## ដំណោះស្រាយ

ក $\overrightarrow{AB}=(-1,2,1),\ \overrightarrow{AC}=(1,1,-1)$

$\overrightarrow{AB}\cdot\overrightarrow{AC}=-1(1)+2(1)+1(-1)=0$

ដូចនេះ $\boxed{\triangle ABC \text{ ជាត្រីកោណកែងត្រង់កំពូល } A}$

ខ $\vec{n}=\overrightarrow{AB}\times\overrightarrow{AC}=(-2-1,-(1-1),-1-2)=\boxed{(-3,0,-3)}$

យក $\vec{n}_{ABC}=(1,0,1)$ ជាណរម៉ាល់កាត់ $A(1,0,1)$៖

$1(x-1)+0(y-0)+1(z-1)=0 \iff \boxed{x+z-2=0}$

គ បន្ទាត់ $(d)\perp(ABC) \implies \vec{u}_d=(1,0,1)$៖

$$(d):\begin{cases}x=1+t\\ y=-1\\ z=3+t\end{cases}\qquad (t\in\mathbb{R})$$

$M=(d)\cap(ABC)$៖ ជំនួស $(d)$ ចូលក្នុង $(ABC)$៖

$(1+t)+(3+t)-2=0 \iff 2t+2=0 \implies t=-1$

ដូចនេះ $\boxed{M(0,-1,2)}$

## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០១៤ (លើកទី២)

គេមាន $A(2,2,1), B(4,-2,0), C(3,1,1), D(1,5,2)$។ ក. បង្ហាញថា $ABCD$ ជាប្រលេឡូក្រាម រួចរកផ្ទៃក្រឡាវា។
ខ. រកសមីការប៉ារ៉ាម៉ែត្របន្ទាត់កាត់ $A, B$។ គ. រកសមីការប្លង់កាត់ $A, B, D$។

### ដំណោះស្រាយ

ក $\overrightarrow{AB} = (2,-4,-1)$, $\overrightarrow{DC} = (2,-4,-1)$

$\Longrightarrow \overrightarrow{AB} = \overrightarrow{DC} \Longrightarrow$ $\boxed{ABCD \text{ ជាប្រលេឡូក្រាម}}$

$\overrightarrow{AD} = (-1,3,1) \Longrightarrow \overrightarrow{AB} \times \overrightarrow{AD} = (-1,-1,2)$

$S_{ABCD} = \|\overrightarrow{AB} \times \overrightarrow{AD}\| = \sqrt{1+1+4} = \boxed{\sqrt{6}}$

ខ $(AB): x = 2+2t,\ y = 2-4t,\ z = 1-t\ (t \in \mathbb{R})$

គ ប្លង់ $(ABD)$ កាត់ $A(2,2,1)$ មាន $\vec{n} = (-1,-1,2)$៖
$-(x-2)-(y-2)+2(z-1) = 0 \iff$ $\boxed{x+y-2z-2=0}$

## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០១៥

គេឱ្យ $\vec{u} = \vec{i} - \vec{j} + 2\vec{k}$, $\vec{v} = -\vec{i} + 2\vec{j} + 2\vec{k}$, $\vec{w} = \vec{i} + \vec{j} - 2\vec{k}$។ រកវ៉ិចទ័រ៖ ក. $\vec{u} + \vec{v}$ ខ. $\vec{w} \times \vec{u}$ គ. $\vec{w} \times \vec{v}$

### ដំណោះស្រាយ

ក $\vec{u} + \vec{v} = (1-1, -1+2, 2+2) = \boxed{(0,1,4)}$

ខ $\vec{w} \times \vec{u} = \boxed{-4\vec{j} - 2\vec{k} = (0,-4,-2)}$

គ $\vec{w} \times \vec{v} = \boxed{6\vec{i} + 3\vec{k} = (6,0,3)}$

## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០១៦

ក្នុងតម្រុយអរតូណរម៉ាល់ $(O, \vec{i}, \vec{j}, \vec{k})$ គេមានចំណុច $M(2,3,4), N(3,5,6), P(4,6,7)$ និង $Q(3,4,5)$។
ក. រកវ៉ិចទ័រ $\overrightarrow{MN}$ និង $\overrightarrow{QP}$។ ខ. ទាញបង្ហាញថា $MNPQ$ ជាប្រលេឡូក្រាម។

### ដំណោះស្រាយ

ក $\overrightarrow{MN} = (3-2, 5-3, 6-4) = \boxed{(1,2,2)}$

$\overrightarrow{QP} = (4-3, 6-4, 7-5) = \boxed{(1,2,2)}$

ខ ដោយ $\overrightarrow{MN} = \overrightarrow{QP} = (1,2,2)$

$\Longrightarrow$ $\boxed{MNPQ \text{ ជាប្រលេឡូក្រាម}}$

## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០១៧

ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមាន $A(-2,1,0),B(0,1,1),C(1,2,2)$ និង $D(0,3,-4)$។

ក. រកវ៉ិចទ័រ $\overrightarrow{AB},\overrightarrow{AC},\overrightarrow{AD},\overrightarrow{BC},\overrightarrow{BD}$ និង $\overrightarrow{CD}$។

ខ. គណនាប្រវែង $AB,AC,AD,BC,BD$ និង $CD$។ ទាញថាត្រីកោណ $ABD$ និង $ACD$ កែងត្រង់ $A$។

### ដំណោះស្រាយ

ក $\overrightarrow{AB}=(2,0,1)$, $\overrightarrow{AC}=(3,1,2)$

$\overrightarrow{AD}=(2,2,-4)$, $\overrightarrow{BC}=(1,1,1)$

$\overrightarrow{BD}=(0,2,-5)$, $\overrightarrow{CD}=(-1,1,-6)$

ខ $AB=\sqrt{4+0+1}=\boxed{\sqrt{5}}$

$AC=\sqrt{9+1+4}=\boxed{\sqrt{14}}$

$AD=\sqrt{4+4+16}=\boxed{2\sqrt{6}}$

$BC=\sqrt{1+1+1}=\boxed{\sqrt{3}}$

$BD=\sqrt{0+4+25}=\boxed{\sqrt{29}}$

$CD=\sqrt{1+1+36}=\boxed{\sqrt{38}}$

• $AB^2+AD^2=5+24=29=BD^2$

$\Longrightarrow$ $\boxed{\triangle ABD \text{ ជាត្រីកោណកែងត្រង់ } A}$

• $AC^2+AD^2=14+24=38=CD^2$

$\Longrightarrow$ $\boxed{\triangle ACD \text{ ជាត្រីកោណកែងត្រង់ } A}$

## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០១៨

ក្នុងតម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ គេមានចំណុច $A(1,2,3),B(3,0,1),C(-1,0,1)$ និង $D(2,1,2)$។

ក. រកវ៉ិចទ័រ $\overrightarrow{AB},\overrightarrow{AC},\overrightarrow{AD}$ និង $\overrightarrow{BC}$។

ខ. បង្ហាញថាវ៉ិចទ័រ $\vec{n}=(0,1,-1)$ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ $(ABC)$។

### ដំណោះស្រាយ

ក $\overrightarrow{AB}=(2,-2,-2)$

$\overrightarrow{AC}=(-2,-2,-2)$

$\overrightarrow{AD}=(1,-1,-1)$

$\overrightarrow{BC}=(-4,0,0)$

ខ $\vec{n}\cdot\overrightarrow{AB}=0(2)+1(-2)-1(-2)=\boxed{0}$

$\vec{n}\cdot\overrightarrow{AC}=0(-2)+1(-2)-1(-2)=\boxed{0}$

ដោយ $\vec{n}\neq\vec{0}$ កែងនឹងវ៉ិចទ័រពីរ $\overrightarrow{AB},\overrightarrow{AC}$ មិនកូលីនេអ៊ែរ

$\Longrightarrow$ $\boxed{\vec{n}=(0,1,-1) \text{ ជាវ៉ិចទ័រណរម៉ាល់នៃប្លង់ } (ABC)}$

## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០១៩

**ផ្នែក A៖** គេមាន $A(1,-1,4), B(7,-1,-2), C(1,5,-2)$។

ក. គណនា $\overrightarrow{AB}, \overrightarrow{AC}, \overrightarrow{BC}$។ បង្ហាញថា $A,B,C$ កំណត់បានប្លង់មួយ។ បង្ហាញ $\vec{n}=(1,1,1)$ ជាណរម៉ាល់នៃ $(ABC)$ និងរកសមីការប្លង់។ ខ. បង្ហាញថា $\triangle ABC$ សម័ង្ស។

**ផ្នែក B៖** គេមានប៉ារ៉ាបូល $y^2+4y-8x-12=0$។ បម្លែងជាស្តង់ដា រកកំពូល កំណុំ បន្ទាត់ប្រាប់ទិស រួចសង់។

### ដំណោះស្រាយ

**ផ្នែក A៖**

ក $\overrightarrow{AB}=(6,0,-6)$, $\overrightarrow{AC}=(0,6,-6)$, $\overrightarrow{BC}=(-6,6,0)$

$\overrightarrow{AB}\times\overrightarrow{AC}=(36,36,36)\neq\vec{0}$

$\Longrightarrow A,B,C$ កំណត់បានប្លង់មួយ

$\vec{n}\cdot\overrightarrow{AB}=6-6=0$, $\vec{n}\cdot\overrightarrow{AC}=6-6=0$

$\Longrightarrow \vec{n}(1,1,1)$ ជាវ៉ិចទ័រណរម៉ាល់នៃ $(ABC)$។

$(ABC): 1(x-1)+1(y+1)+1(z-4)=0$

$\Longleftrightarrow \boxed{x+y+z-4=0}$

ខ $\|\overrightarrow{AB}\|=\|\overrightarrow{AC}\|=\|\overrightarrow{BC}\|=6\sqrt{2}$

$\Longrightarrow$ $\boxed{\triangle ABC \text{ ជាត្រីកោណសម័ង្ស}}$

**ផ្នែក B៖**

$(y+2)^2-4-8x-12=0 \Longleftrightarrow \boxed{(y+2)^2=8(x+2)}$

ទម្រង់ $(y-k)^2=4p(x-h) \Longrightarrow p=2$

- កំពូល $\boxed{V(-2,-2)}$ • កំណុំ $\boxed{F(0,-2)}$
- បន្ទាត់ប្រាប់ទិស $\boxed{x=-4}$



## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០២១

ក. គេមាន $A(0,-2,0), B(-4,1,2), C(0,3,7), D(4,0,5)$។ រក $\overrightarrow{AB}, \overrightarrow{BC}, \overrightarrow{CD}, \overrightarrow{AD}$ រួចបង្ហាញ $ABCD$ ជាចតុកោណកែងតែមិនមែនការេ។

ខ. សមីការ $9y^2 = 25(3-x)(3+x)$។ បង្ហាញថាជាអេលីប រកប្រវែងអ័ក្សធំ អ័ក្សតូច កំពូល កំណុំ រួចសង់។

## ដំណោះស្រាយ

ក $\overrightarrow{AB} = (-4,3,2)$, $\overrightarrow{BC} = (4,2,5)$

$\overrightarrow{CD} = (4,-3,-2)$, $\overrightarrow{AD} = (4,2,5)$

- $\overrightarrow{AB} = \overrightarrow{DC} \implies ABCD$ ជាប្រលេឡូក្រាម
- $\overrightarrow{AB} \cdot \overrightarrow{BC} = -16+6+10 = 0 \implies \angle B = 90^\circ$
- $AB = \sqrt{16+9+4} = \sqrt{29}$

  $BC = \sqrt{16+4+25} = 3\sqrt{5} \neq AB$

$\implies$ $\boxed{ABCD \text{ ចតុកោណកែង មិនមែនការេ}}$

ខ $9y^2 = 25(9-x^2) \iff 25x^2 + 9y^2 = 225$

$\iff \boxed{\frac{x^2}{9} + \frac{y^2}{25} = 1}$ (អេលីបឈរ ផ្ចិត $O$)

$a = 5, b = 3, c = \sqrt{25-9} = 4$៖

- អ័ក្សធំ $2a = \boxed{10}$, អ័ក្សតូច $2b = \boxed{6}$
- កំពូល $\boxed{V(0,\pm 5)}$ • កំណុំ $\boxed{F(0,\pm 4)}$



## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០២២

ក. គេមាន $M(0,1,1), N(1,2,2), P(0,3,-4), Q(-2,1,0)$។

1. រក $\overrightarrow{MN}, \overrightarrow{NP}, \overrightarrow{NQ}, \overrightarrow{PQ}$ និងប្រវែង។ 2. បង្ហាញ $\triangle NPQ$ កែងត្រង់ $Q$ និងរកផ្ទៃក្រឡា។

ខ. រកកំពូល កំណុំ បន្ទាត់ប្រាប់ទិសនៃប៉ារ៉ាបូល $(y+2)^2 = -8(x-2)$ រួចសង់។

### ដំណោះស្រាយ

ក 1. $\overrightarrow{MN} = (1,1,1) \implies MN = \boxed{\sqrt{3}}$

$\overrightarrow{NP} = (-1,1,-6) \implies NP = \boxed{\sqrt{38}}$

$\overrightarrow{NQ} = (-3,-1,-2) \implies NQ = \boxed{\sqrt{14}}$

$\overrightarrow{PQ} = (-2,-2,4) \implies PQ = \boxed{2\sqrt{6}}$

2. $\overrightarrow{NQ} \cdot \overrightarrow{PQ} = 6+2-8 = \boxed{0} \implies$ $\boxed{\triangle NPQ \text{ កែងត្រង់ } Q}$

$S_{NPQ} = \frac{1}{2} NQ \cdot PQ = \frac{1}{2}\sqrt{14} \cdot 2\sqrt{6} = \boxed{2\sqrt{21}}$

ខ $(y+2)^2 = -8(x-2) \implies (y-k)^2 = 4p(x-h)$

$h = 2, k = -2, 4p = -8 \implies p = -2 < 0$

• កំពូល $\boxed{V(2,-2)}$ • កំណុំ $\boxed{F(0,-2)}$

• បន្ទាត់ប្រាប់ទិស $\boxed{x = 4}$



## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០២៣

ក. គេមាន $A(5,-5,2), B(-1,1,0), C(0,1,2), D(6,6,-1)$។

1. បង្ហាញថា $A,B,C$ មិននៅលើបន្ទាត់តែមួយ។ 2. បង្ហាញ $\triangle BCD$ កែង និងរកផ្ទៃក្រឡា។

ខ. សមីការ $12(xy+3)-(3x+2y)^2=0$។ បង្ហាញថាជាអេលីប រកអ័ក្សធំ អ័ក្សតូច កំពូល រួចសង់។

### ដំណោះស្រាយ

ក 1. $\overrightarrow{AB}=(-6,6,-2), \overrightarrow{AC}=(-5,6,0)$

$\overrightarrow{AB}\times\overrightarrow{AC}=(12,10,-6)\neq\vec{0} \implies A,B,C$ មិនរត់ត្រង់គ្នា

2. $\overrightarrow{BC}=(1,0,2), \overrightarrow{CD}=(6,5,-3)$

$\overrightarrow{BC}\cdot\overrightarrow{CD}=6+0-6=0 \implies$ $\boxed{\triangle BCD \text{ កែងត្រង់ } C}$

$BC=\sqrt{5}, CD=\sqrt{70}$

$S_{BCD}=\frac{1}{2}\sqrt{5}\sqrt{70}=\boxed{\frac{5\sqrt{14}}{2} \text{ (ឯកតាផ្ទៃ)}}$

ខ $12xy+36-(9x^2+12xy+4y^2)=0$

$\iff 9x^2+4y^2=36 \iff \boxed{\frac{x^2}{4}+\frac{y^2}{9}=1}$

អេលីបឈរ $a=3, b=2$៖

- អ័ក្សធំ $2a=\boxed{6}$, អ័ក្សតូច $2b=\boxed{4}$
- កំពូល $\boxed{V(0,\pm3)}$



## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០២៤

ក. គេមាន $A(2,0,0), B(-1,\sqrt{3},0), C(-1,-\sqrt{3},0)$។ រក $\overrightarrow{AB}, \overrightarrow{AC}, \overrightarrow{BC}$។ បង្ហាញ $\triangle ABC$ សម័ង្ស និងរកផ្ទៃវា។

ខ. សមីការ $(2x-3y)^2 = 6(3y^2-2xy-6)$។ បង្ហាញថាជាអ៊ីពែរបូល រកកំពូល កំណុំ អាសុីមតូត រួចសង់។

### ដំណោះស្រាយ

ក $\overrightarrow{AB} = (-3,\sqrt{3},0), \overrightarrow{AC} = (-3,-\sqrt{3},0)$

$\overrightarrow{BC} = (0,-2\sqrt{3},0)$

$AB = AC = BC = \sqrt{9+3} = 2\sqrt{3}$

$\Longrightarrow$ $\boxed{\triangle ABC \text{ ជាត្រីកោណសម័ង្ស}}$

$S_{ABC} = \frac{\sqrt{3}}{4}(2\sqrt{3})^2 = \boxed{3\sqrt{3} \text{ (ឯកតាផ្ទៃ)}}$

ខ $4x^2 - 12xy + 9y^2 = 18y^2 - 12xy - 36$

$\Longleftrightarrow\ -4x^2 + 9y^2 = 36 \Longleftrightarrow \boxed{\frac{y^2}{4} - \frac{x^2}{9} = 1}$

អ៊ីពែរបូលឈរ $a = 2, b = 3, c = \sqrt{13}$៖

• កំពូល $\boxed{V(0,\pm 2)}$ • កំណុំ $\boxed{F(0,\pm\sqrt{13})}$

• អាសុីមតូត $\boxed{y = \pm\frac{2}{3}x}$



## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០២៥

**ផ្នែក A៖** គេមាន $A(1,-2,0),B(-2,0,-1),C(-2,-1,2),D(-2,1,-2),E(2,5,-2),F(-1,0,-2)$។

1. គណនា $\overrightarrow{AC},\overrightarrow{AE},\overrightarrow{BD},\overrightarrow{BF},\overrightarrow{DF}$។ 2. បង្ហាញ $\triangle ACE$ កែងត្រង់ $A$ និង $\triangle BDF$ សម័ង្ស។

**ផ្នែក B៖** ប៉ារ៉ាបូលមានកំណុំលើអ័ក្សអាប់ស៊ីស និងកំពូល $O(0,0)$ កាត់តាម $A(2,4)$។ រកសមីការស្តង់ដា និងរក $x_1$ បើ $B(x_1,-8)$ នៅលើប៉ារ៉ាបូល។

## ដំណោះស្រាយ

**ផ្នែក A៖**

1. $\overrightarrow{AC}=(-3,1,2),\overrightarrow{AE}=(1,7,-2)$

$\overrightarrow{BD}=(0,1,-1),\overrightarrow{BF}=(1,0,-1),\overrightarrow{DF}=(1,-1,0)$

2. $\overrightarrow{AC}\cdot\overrightarrow{AE}=-3+7-4=0 \Longrightarrow$ $\boxed{\triangle ACE \text{ កែងត្រង់ } A}$

$BD=BF=DF=\sqrt{2} \Longrightarrow$ $\boxed{\triangle BDF \text{ ជាត្រីកោណសម័ង្ស}}$

**ផ្នែក B៖**

កំពូល $O(0,0)$, កំណុំលើ $Ox \Longrightarrow y^2=4px$

កាត់ $A(2,4) \Longrightarrow 4^2=4p(2) \Longrightarrow p=2$

ដូចនេះ សមីការស្តង់ដាគឺ $\boxed{y^2=8x}$

ចំណុច $B(x_1,-8)$ នៅលើប៉ារ៉ាបូល៖

$(-8)^2=8x_1 \Longleftrightarrow 64=8x_1 \Longrightarrow \boxed{x_1=8}$

## វិញ្ញាសាប្រឡងបាក់ឌុប ឆ្នាំ ២០២៦

1. គេមានចំណុច $A(-3,1,4), B(-2,-1,7), C(-4,-1,-2), D(-2,-5,4)$។

ក. រកវ៉ិចទ័រ $\overrightarrow{AB}, \overrightarrow{AC}, \overrightarrow{AD}$។ ខ. រកចំនួនពិត $a,b$ ដែល $\overrightarrow{AB} = a\overrightarrow{AC} + b\overrightarrow{AD}$ រួចទាញថា $A,B,C,D$ លើប្លង់តែមួយ។

2. ប៉ារ៉ាបូលកំពូល $O(0,0)$ កាត់តាម $A(-2,6)$ និង $B(x_1,6)$ ដែល $x_1 > 0$។ រកសមីការស្តង់ដា និងរកតម្លៃនៃ $x_1$។

## ដំណោះស្រាយ

1. ក $\overrightarrow{AB} = (1,-2,3)$, $\overrightarrow{AC} = (-1,-2,-6)$

$\overrightarrow{AD} = (1,-6,0)$

ខ $\overrightarrow{AB} = a\overrightarrow{AC} + b\overrightarrow{AD} \Longrightarrow \begin{cases} 1 = -a + b \\ -2 = -2a - 6b \\ 3 = -6a \end{cases}$

$\Longrightarrow \boxed{a = -\dfrac{1}{2},\ b = \dfrac{1}{2}}$

ដោយ $\overrightarrow{AB} = -\frac{1}{2}\overrightarrow{AC} + \frac{1}{2}\overrightarrow{AD}$

$\Longrightarrow$ $\boxed{A,B,C,D \text{ ស្ថិតនៅលើប្លង់តែមួយ}}$

2. ដោយ $A(-2,6)$ និង $B(x_1,6)$ មាន $y = 6$

$\Longrightarrow$ អ័ក្សឆ្លុះគឺអ័ក្សអរដោនេ $Oy$៖

សមីការមានរាង $x^2 = 4py$៖

$(-2)^2 = 4p(6) \Longrightarrow 4 = 24p \Longrightarrow 4p = \frac{2}{3}$

ដូចនេះ សមីការស្តង់ដាគឺ $\boxed{x^2 = \dfrac{2}{3}y}$

ចំណុច $B(x_1,6)$ នៅលើប៉ារ៉ាបូល៖

$x_1^2 = \frac{2}{3}(6) = 4 \Longrightarrow \boxed{x_1 = 2}$ (ដោយ $x_1 > 0$)



# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ទី១ ៖ តារាងសង្ខេបរូបមន្តធរណីមាត្រក្នុងលំហ ថ្នាក់ទី១២

### ១. កូអរដោនេចំណុច និងវ៉ិចទ័រក្នុងលំហ

- តម្រុយអរតូណរម៉ាល់ $(O,\vec{i},\vec{j},\vec{k})$ ៖ $\vec{i}\perp\vec{j}\perp\vec{k}$ និង $\|\vec{i}\|=\|\vec{j}\|=\|\vec{k}\|=1$
- កូអរដោនេនៃចំណុច និងវ៉ិចទ័រ ៖ $\overrightarrow{OM}=x\vec{i}+y\vec{j}+z\vec{k} \iff M(x,y,z) \quad ; \quad \vec{u}=(x,y,z)$
- ម៉ូឌុល (ប្រវែង) ៖ $\|\vec{u}\|=\sqrt{x^2+y^2+z^2}$
- វ៉ិចទ័រ និងចម្ងាយរវាងពីរចំណុច $A,B$ ៖

$$\overrightarrow{AB}=(x_B-x_A,\, y_B-y_A,\, z_B-z_A), \quad AB=\|\overrightarrow{AB}\|=\sqrt{(x_B-x_A)^2+(y_B-y_A)^2+(z_B-z_A)^2}$$

- ចំណុចកណ្ដាល $I$ នៃ $[AB]$ ៖ $I\left(\frac{x_A+x_B}{2},\frac{y_A+y_B}{2},\frac{z_A+z_B}{2}\right)$
- ទីប្រជុំទម្ងន់ត្រីកោណ $ABC$ ៖ $G\left(\frac{x_A+x_B+x_C}{3},\frac{y_A+y_B+y_C}{3},\frac{z_A+z_B+z_C}{3}\right)$
- ទីប្រជុំទម្ងន់ចតុមុខ $ABCD$ ៖ $G\left(\frac{x_A+x_B+x_C+x_D}{4},\frac{y_A+y_B+y_C+y_D}{4},\frac{z_A+z_B+z_C+z_D}{4}\right)$
- ប្រមាណវិធី ៖ $\vec{u}\pm\vec{v}=(x\pm x',\, y\pm y',\, z\pm z'), \quad k\vec{u}=(kx,\, ky,\, kz)$
- លក្ខខណ្ឌកូលីនេអ៊ែរ (ស្របគ្នា) ៖ $\vec{u}\parallel\vec{v} \iff \exists k\in\mathbb{R},\vec{u}=k\vec{v} \iff \frac{x}{x'}=\frac{y}{y'}=\frac{z}{z'}\ (x',y',z'\neq 0)$

### ២. ផលគុណស្កាលែ និងមុំរវាងពីរវ៉ិចទ័រ

- និយមន័យ និងរូបមន្តវិភាគ ៖ $\vec{u}\cdot\vec{v}=\|\vec{u}\|\|\vec{v}\|\cos(\vec{u},\vec{v})=xx'+yy'+zz'$
- លក្ខខណ្ឌកែងគ្នា ៖ $\vec{u}\perp\vec{v} \iff \vec{u}\cdot\vec{v}=0 \iff xx'+yy'+zz'=0$
- កូស៊ីនុសមុំរវាងពីរវ៉ិចទ័រ ៖ $\cos\theta=\frac{\vec{u}\cdot\vec{v}}{\|\vec{u}\|\|\vec{v}\|}=\frac{xx'+yy'+zz'}{\sqrt{x^2+y^2+z^2}\cdot\sqrt{x'^2+y'^2+z'^2}} \quad (0^\circ\leq\theta\leq 180^\circ)$
- កូស៊ីនុសប្រាប់ទិសនៃ $\vec{u}(x,y,z)$ ៖ $\cos\alpha=\frac{x}{\|\vec{u}\|},\ \cos\beta=\frac{y}{\|\vec{u}\|},\ \cos\gamma=\frac{z}{\|\vec{u}\|} \implies \cos^2\alpha+\cos^2\beta+\cos^2\gamma=1$

## ៣. ផលគុណនៃពីរវ៉ិចទ័រ ( Cross Product )

- និយមន័យក្នុងកូអរដោនេ ៖

$$\vec{u}\times\vec{v}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ x & y & z\\ x' & y' & z'\end{vmatrix}=\left(\begin{vmatrix}y & z\\ y' & z'\end{vmatrix},-\begin{vmatrix}x & z\\ x' & z'\end{vmatrix},\begin{vmatrix}x & y\\ x' & y'\end{vmatrix}\right)=(yz'-zy',\,zx'-xz',\,xy'-yx')$$

- លក្ខណៈសំខាន់ៗ ៖
  - $\vec{u}\times\vec{v}=-(\vec{v}\times\vec{u})$ (វិសមមាត្រ) ; $\vec{u}\times\vec{u}=\vec{0}$
  - $(\vec{u}\times\vec{v})\perp\vec{u}$ និង $(\vec{u}\times\vec{v})\perp\vec{v}$
  - $\|\vec{u}\times\vec{v}\|=\|\vec{u}\|\|\vec{v}\|\sin(\vec{u},\vec{v})$
  - $\vec{u}\parallel\vec{v}\iff\vec{u}\times\vec{v}=\vec{0}$
  - ចំណុច $A,B,C$ រត់ត្រង់ជួរគ្នា $\iff\overrightarrow{AB}\times\overrightarrow{AC}=\vec{0}$
- ផ្ទៃក្រឡាប្រលេឡូក្រាមដែលសង់លើ $\vec{u}$ និង $\vec{v}$ ៖ $S=\|\vec{u}\times\vec{v}\|$
- ផ្ទៃក្រឡាត្រីកោណ $ABC$ ៖ $S_{ABC}=\dfrac{1}{2}\|\overrightarrow{AB}\times\overrightarrow{AC}\|$

## ៤. ផលគុណចម្រុះ និងមាឌ ( Scalar Triple Product & Volume )

- រូបមន្តផលគុណចម្រុះ ៖

$$(\vec{u}\times\vec{v})\cdot\vec{w}=\begin{vmatrix}x & y & z\\ x' & y' & z'\\ x'' & y'' & z''\end{vmatrix}=x(y'z''-z'y'')-y(x'z''-z'x'')+z(x'y''-y'x'')$$

- លក្ខខណ្ឌ ៣ វ៉ិចទ័រកូប្លាណែ (ស្ថិតក្នុងប្លង់តែមួយ) ៖ $(\vec{u}\times\vec{v})\cdot\vec{w}=0$
- លក្ខខណ្ឌ ៤ ចំណុច $A,B,C,D$ ស្ថិតក្នុងប្លង់តែមួយ ៖ $(\overrightarrow{AB}\times\overrightarrow{AC})\cdot\overrightarrow{AD}=0$
- មាឌប្រលេឡេពីប៉ែតសង់លើ $\vec{u},\vec{v},\vec{w}$ ៖ $V=|(\vec{u}\times\vec{v})\cdot\vec{w}|$
- មាឌចតុមុខ $ABCD$ ៖ $V_{ABCD}=\dfrac{1}{6}|(\overrightarrow{AB}\times\overrightarrow{AC})\cdot\overrightarrow{AD}|$
- ប្រវែងកម្ពស់ចតុមុខគូសចេញពី $D$ មកបាត $(ABC)$ ៖ $h_D=\dfrac{3V_{ABCD}}{S_{ABC}}=\dfrac{|(\overrightarrow{AB}\times\overrightarrow{AC})\cdot\overrightarrow{AD}|}{\|\overrightarrow{AB}\times\overrightarrow{AC}\|}$

## ៥. សមីការបន្ទាត់ក្នុងលំហ

- បន្ទាត់ $(L)$ កាត់តាម $A(x_0, y_0, z_0)$ មានវ៉ិចទ័រប្រាប់ទិស $\vec{u} = (a, b, c) \neq \vec{0}$ ៖
  - សមីការវ៉ិចទ័រ ៖ $\overrightarrow{OM} = \overrightarrow{OA} + t\vec{u} \quad (t \in \mathbb{R})$
  - សមីការប៉ារ៉ាម៉ែត្រ ៖ $\begin{cases} x = x_0 + at \\ y = y_0 + bt \\ z = z_0 + ct \end{cases} \quad (t \in \mathbb{R})$
  - សមីការឆ្លុះ (បើ $a, b, c \neq 0$) ៖ $\dfrac{x - x_0}{a} = \dfrac{y - y_0}{b} = \dfrac{z - z_0}{c}$
- ទីតាំងធៀបនៃពីរបន្ទាត់ $(L_1)$ (កាត់ $A_1$, ទិស $\vec{u}_1$) និង $(L_2)$ (កាត់ $A_2$, ទិស $\vec{u}_2$) ៖
  - ត្រួតស៊ីគ្នា ៖ $\vec{u}_1 \parallel \vec{u}_2$ និង $A_1 \in (L_2)$
  - ស្របគ្នាដាច់ខាត ៖ $\vec{u}_1 \parallel \vec{u}_2$ និង $A_1 \notin (L_2)$
  - កាត់គ្នាត្រង់ចំណុចមួយ ៖ $\vec{u}_1 \nparallel \vec{u}_2$ និង $(\vec{u}_1 \times \vec{u}_2) \cdot \overrightarrow{A_1A_2} = 0$
  - ទ្រេតគ្នា (មិនកាត់គ្នា មិនស្របគ្នា) ៖ $\vec{u}_1 \nparallel \vec{u}_2$ និង $(\vec{u}_1 \times \vec{u}_2) \cdot \overrightarrow{A_1A_2} \neq 0$

## ៦. សមីការប្លង់ក្នុងលំហ

- ប្លង់ $(P)$ កាត់តាម $M_0(x_0, y_0, z_0)$ មានវ៉ិចទ័រណរម៉ាល់ $\vec{n} = (a, b, c) \neq \vec{0}$ ៖

$$a(x - x_0) + b(y - y_0) + c(z - z_0) = 0 \iff ax + by + cz + d = 0 \quad (d = -(ax_0 + by_0 + cz_0))$$

- ប្លង់កាត់តាមបីចំណុចមិនរត់ត្រង់ជួរ $A, B, C$ ៖ មានវ៉ិចទ័រណរម៉ាល់ $\vec{n} = \overrightarrow{AB} \times \overrightarrow{AC}$
- ទីតាំងធៀបនៃពីរប្លង់ $(P_1) : a_1x + b_1y + c_1z + d_1 = 0$ និង $(P_2) : a_2x + b_2y + c_2z + d_2 = 0$ ៖
  - ត្រួតស៊ីគ្នា ៖ $\dfrac{a_1}{a_2} = \dfrac{b_1}{b_2} = \dfrac{c_1}{c_2} = \dfrac{d_1}{d_2}$
  - ស្របគ្នាដាច់ខាត ៖ $\dfrac{a_1}{a_2} = \dfrac{b_1}{b_2} = \dfrac{c_1}{c_2} \neq \dfrac{d_1}{d_2}$
  - កាត់គ្នាជាបន្ទាត់ $(d)$ ៖ $\vec{n}_1 \nparallel \vec{n}_2$ (បន្ទាត់ $(d)$ មានទិស $\vec{u} = \vec{n}_1 \times \vec{n}_2$)
  - កែងគ្នា ៖ $(P_1) \perp (P_2) \iff \vec{n}_1 \cdot \vec{n}_2 = 0 \iff a_1a_2 + b_1b_2 + c_1c_2 = 0$

## ៧. ចម្ងាយ និងមុំក្នុងលំហ

- ចម្ងាយពីចំណុច $M_0(x_0,y_0,z_0)$ ទៅប្លង់ $(P): ax+by+cz+d=0$ ៖ $d(M_0,(P)) = \dfrac{|ax_0+by_0+cz_0+d|}{\sqrt{a^2+b^2+c^2}}$
- ចម្ងាយពីចំណុច $M_0(x_0,y_0,z_0)$ ទៅបន្ទាត់ $(L)$ (កាត់ $A$, ទិស $\vec{u}$) ៖ $d(M_0,(L)) = \dfrac{\|\overrightarrow{AM_0}\times\vec{u}\|}{\|\vec{u}\|}$
- ចម្ងាយរវាងបន្ទាត់ទ្រេតគ្នាពីរ $(L_1)$ និង $(L_2)$ ៖ $d(L_1,L_2) = \dfrac{|(\vec{u}_1\times\vec{u}_2)\cdot\overrightarrow{A_1A_2}|}{\|\vec{u}_1\times\vec{u}_2\|}$
- ចម្ងាយរវាងពីរប្លង់ស្របគ្នា $(P_1): ax+by+cz+d_1=0$ និង $(P_2): ax+by+cz+d_2=0$ ៖ $d(P_1,P_2) = \dfrac{|d_1-d_2|}{\sqrt{a^2+b^2+c^2}}$
- មុំរវាងពីរបន្ទាត់ $(L_1),(L_2)$ ៖ $\cos\theta = \dfrac{|\vec{u}_1\cdot\vec{u}_2|}{\|\vec{u}_1\|\|\vec{u}_2\|} \quad (0^\circ \le \theta \le 90^\circ)$
- មុំរវាងពីរប្លង់ $(P_1),(P_2)$ ៖ $\cos\theta = \dfrac{|\vec{n}_1\cdot\vec{n}_2|}{\|\vec{n}_1\|\|\vec{n}_2\|} \quad (0^\circ \le \theta \le 90^\circ)$
- មុំរវាងបន្ទាត់ $(L)$ និងប្លង់ $(P)$ ៖ $\sin\alpha = \dfrac{|\vec{u}\cdot\vec{n}|}{\|\vec{u}\|\|\vec{n}\|} \quad (0^\circ \le \alpha \le 90^\circ)$

## ៨. សមីការស្វ៊ែរ និងទីតាំងធៀប

- សមីការស្តង់ដា (ផ្ចិត $I(a,b,c)$, កាំ $R$) ៖ $(x-a)^2+(y-b)^2+(z-c)^2=R^2$
- សមីការទូទៅ ៖ $x^2+y^2+z^2-2ax-2by-2cz+d=0$

  លក្ខខណ្ឌជាស្វ៊ែរ ៖ $a^2+b^2+c^2-d>0 \Longrightarrow$ ផ្ចិត $I(a,b,c)$, កាំ $R=\sqrt{a^2+b^2+c^2-d}$

- សមីការស្វ៊ែរមានអង្កត់ផ្ចិត $[AB]$ ៖ $\overrightarrow{MA}\cdot\overrightarrow{MB}=0 \iff (x-x_A)(x-x_B)+(y-y_A)(y-y_B)+(z-z_A)(z-z_B)=0$
- សមីការប្លង់ប៉ះស្វ៊ែរត្រង់ចំណុច $M_0(x_0,y_0,z_0)\in(S)$ ៖ $(x_0-a)(x-x_0)+(y_0-b)(y-y_0)+(z_0-c)(z-z_0)=0$
- ទីតាំងធៀបរវាងស្វ៊ែរផ្ចិត $I$ កាំ $R$ និងប្លង់ $(P)$ (តាង $d=d(I,(P))$) ៖
  - $d>R$ ៖ ប្លង់មិនកាត់ស្វ៊ែរ ; $d=R$ ៖ ប្លង់ប៉ះស្វ៊ែរត្រង់ $H$
  - $d<R$ ៖ ប្លង់កាត់ស្វ៊ែរបានជារង្វង់ផ្ចិត $H$ កាំ $r=\sqrt{R^2-d^2}$
- ទីតាំងធៀបរវាងស្វ៊ែរពីរ $(S_1)$ និង $(S_2)$ $(d=I_1I_2)$ ៖
  - $d>R_1+R_2$ ៖ នៅក្រៅគ្នា ; $d=R_1+R_2$ ៖ ប៉ះគ្នាខាងក្រៅ
  - $|R_1-R_2|<d<R_1+R_2$ ៖ កាត់គ្នា ; $d=|R_1-R_2|$ ៖ ប៉ះគ្នាខាងក្នុង ; $d<|R_1-R_2|$ ៖ នៅខាងក្នុងគ្នា

# ឧបសម្ពន្ធ ទី២ ៖ រូបមន្តធរណីមាត្រប្លង់ និងត្រីកោណមាត្រគ្រឹះ

## ១. ផ្ទៃក្រឡា និងបរិមាត្រនៃរូបធរណីមាត្រប្លង់

| រូបធរណីមាត្រ | បរិមាត្រ $(P)$ | ផ្ទៃក្រឡា $(S)$ |
|---|---|---|
| ត្រីកោណទូទៅ | $P=a+b+c$ | $S=\frac{1}{2}ah=\frac{1}{2}ab\sin C=\sqrt{p(p-a)(p-b)(p-c)}$ |
| ត្រីកោណកែង | $P=a+b+c$ | $S=\frac{1}{2}ab$ ; $c^2=a^2+b^2$ (ពីតាករ) |
| ត្រីកោណសម័ង្ស (ជ្រុង $a$) | $P=3a$ | $h=\frac{a\sqrt{3}}{2}$ ; $S=\frac{a^2\sqrt{3}}{4}$ |
| ការេ (ជ្រុង $a$) | $P=4a$ | $S=a^2$ ; អង្កត់ទ្រូង $d=a\sqrt{2}$ |
| ចតុកោណកែង $(a\times b)$ | $P=2(a+b)$ | $S=ab$ ; អង្កត់ទ្រូង $d=\sqrt{a^2+b^2}$ |
| ប្រលេឡូក្រាម | $P=2(a+b)$ | $S=ah=ab\sin\theta$ |
| ចតុកោណស្មើ (អង្កត់ទ្រូង $d_1,d_2$) | $P=4a$ | $S=\frac{1}{2}d_1d_2$ |
| ចតុកោណព្នាយ (បាត $a,b$) | $P=a+b+c+d$ | $S=\frac{(a+b)h}{2}$ |
| រង្វង់ (កាំ $R$) | $C=2\pi R=\pi d$ | $S=\pi R^2$ |
| ចម្រៀករង្វង់ (មុំ $\theta$ ជា rad) | $L=R\theta$ | $S=\frac{1}{2}R^2\theta$ |

## ២. តារាងតម្លៃត្រីកោណមាត្រនៃមុំពិសេស

| មុំជាដឺក្រេ | $0^\circ$ | $30^\circ$ | $45^\circ$ | $60^\circ$ | $90^\circ$ | $120^\circ$ | $180^\circ$ |
|---|---|---|---|---|---|---|---|
| មុំជារ៉ាដ្យង់ | $0$ | $\frac{\pi}{6}$ | $\frac{\pi}{4}$ | $\frac{\pi}{3}$ | $\frac{\pi}{2}$ | $\frac{2\pi}{3}$ | $\pi$ |
| $\sin x$ | $0$ | $\frac{1}{2}$ | $\frac{\sqrt{2}}{2}$ | $\frac{\sqrt{3}}{2}$ | $1$ | $\frac{\sqrt{3}}{2}$ | $0$ |
| $\cos x$ | $1$ | $\frac{\sqrt{3}}{2}$ | $\frac{\sqrt{2}}{2}$ | $\frac{1}{2}$ | $0$ | $-\frac{1}{2}$ | $-1$ |
| $\tan x$ | $0$ | $\frac{\sqrt{3}}{3}$ | $1$ | $\sqrt{3}$ | $\times$ | $-\sqrt{3}$ | $0$ |

## ៣. រូបមន្តត្រីកោណមាត្រគ្រឹះ

- ទំនាក់ទំនងគ្រឹះ ៖ $\sin^2 x+\cos^2 x=1$, $1+\tan^2 x=\frac{1}{\cos^2 x}$, $\tan x=\frac{\sin x}{\cos x}$
- រូបមន្តបូក-ដក ៖ $\cos(a\pm b)=\cos a\cos b\mp\sin a\sin b$, $\sin(a\pm b)=\sin a\cos b\pm\cos a\sin b$
- រូបមន្តមុំទ្វេ ៖ $\sin 2a=2\sin a\cos a$, $\cos 2a=\cos^2 a-\sin^2 a=2\cos^2 a-1=1-2\sin^2 a$
- ទ្រឹស្តីបទស៊ីនុស និងកូស៊ីនុស ៖ $\frac{a}{\sin A}=\frac{b}{\sin B}=\frac{c}{\sin C}=2R$, $a^2=b^2+c^2-2bc\cos A$

# ឧបសម្ពន្ធ ទី៣ ៖ តារាងពាក្យបច្ចេកទេសគណិតវិទ្យា ខ្មែរ–អង់គ្លេស–បារាំង

| ល.រ | ភាសាខ្មែរ | English | Français |
|---|---|---|---|
| 1 | វ៉ិចទ័រ | Vector | Vecteur |
| 2 | តម្រុយអរតូណរម៉ាល់ | Orthonormal coordinate system | Repère orthonormé |
| 3 | កូអរដោនេ | Coordinates | Coordonnées |
| 4 | អាប់ស៊ីស $(x)$ | Abscissa ($x$-coordinate) | Abscisse |
| 5 | អរដោនេ $(y)$ | Ordinate ($y$-coordinate) | Ordonnée |
| 6 | កូត $(z)$ | Applicate ($z$-coordinate) | Cote |
| 7 | ម៉ូឌុល / ប្រវែងវ៉ិចទ័រ | Magnitude / Norm | Norme d'un vecteur |
| 8 | វ៉ិចទ័រឯកតា | Unit vector | Vecteur unitaire |
| 9 | ផលគុណស្កាលែ | Dot product / Scalar product | Produit scalaire |
| 10 | ផលគុណនៃពីរវ៉ិចទ័រ | Cross product / Vector product | Produit vectoriel |
| 11 | ផលគុណចម្រុះ | Scalar triple product | Produit mixte |
| 12 | កូប្លាណែ (ក្នុងប្លង់តែមួយ) | Coplanar | Coplanaires |
| 13 | កូលីនេអ៊ែរ (ស្របគ្នា) | Collinear / Parallel | Colinéaires / Parallèles |
| 14 | អរតូកូណាល់ / កែងគ្នា | Orthogonal / Perpendicular | Orthogonal / Perpendiculaire |
| 15 | ចំណោលកែង | Orthogonal projection | Projection orthogonale |
| 16 | វ៉ិចទ័រប្រាប់ទិស | Direction vector | Vecteur directeur |
| 17 | វ៉ិចទ័រណរម៉ាល់ | Normal vector | Vecteur normal |
| 18 | សមីការប៉ារ៉ាម៉ែត្រ | Parametric equations | Équations paramétriques |
| 19 | សមីការឆ្លុះ | Symmetric equations | Équations symétriques |
| 20 | សមីការទូទៅនៃប្លង់ | General equation of a plane | Équation générale d'un plan |

## ឧបសម្ពន្ធ ទី៣ ៖ តារាងពាក្យបច្ចេកទេសគណិតវិទ្យា (ត)

| ល.រ | ភាសាខ្មែរ | English | Français |
|---|---|---|---|
| 21 | បន្ទាត់ទ្រេត | Skew lines | Droites non coplanaires |
| 22 | បន្ទាត់ស្រប | Parallel lines | Droites parallèles |
| 23 | បន្ទាត់កាត់គ្នា | Intersecting lines | Droites sécantes |
| 24 | មុំរវាងពីរបន្ទាត់ | Angle between two lines | Angle entre deux droites |
| 25 | មុំរវាងពីរផ្លង់ | Angle between two planes | Angle entre deux plans |
| 26 | មុំរវាងបន្ទាត់ និងប្លង់ | Angle between line and plane | Angle entre droite et plan |
| 27 | ចម្ងាយពីចំណុចទៅប្លង់ | Distance from point to plane | Distance d'un point à un plan |
| 28 | ចម្ងាយពីចំណុចទៅបន្ទាត់ | Distance from point to line | Distance d'un point à une droite |
| 29 | ចម្ងាយរវាងបន្ទាត់ទ្រេតពីរ | Distance between skew lines | Distance entre droites gauches |
| 30 | ស្វ៊ែរ | Sphere | Sphère |
| 31 | ផ្ចិត និងកាំ | Center and radius | Centre et rayon |
| 32 | ប្លង់ប៉ះស្វ៊ែរ | Tangent plane to a sphere | Plan tangent à une sphère |
| 33 | រង្វង់ធំ | Great circle | Grand cercle |
| 34 | ចតុមុខ | Tetrahedron | Tétraèdre |
| 35 | ចតុមុខនិយ័ត | Regular tetrahedron | Tétraèdre régulier |
| 36 | ប្រលេឡេពីប៉ែត | Parallelepiped | Parallélépipède |
| 37 | ទីប្រជុំទម្ងន់ | Centroid / Center of gravity | Centre de gravité |
| 38 | ដេទែមីណង់ | Determinant | Déterminant |
| 39 | កូស៊ីនុសប្រាប់ទិស | Direction cosines | Cosinus directeurs |
| 40 | ផ្ទៃក្រឡា និងមាឌ | Surface area and volume | Aire et volume |

# ឧបសម្ពន្ធ ទី៤ ៖ តារាងអក្សរក្រិក និងនិមិត្តសញ្ញាគណិតវិទ្យា

## ១. តារាងអក្សរក្រិក ( Greek Alphabet )

| តូច | ធំ | ឈ្មោះអាន (ខ្មែរ) | ការប្រើប្រាស់ទូទៅក្នុងធរណីមាត្រ |
|---|---|---|---|
| $\alpha$ | $A$ | អាល់ហ្វា (Alpha) | វង្វាស់មុំ, មេគុណស្កាលែ, មុំប្រាប់ទិសអ័ក្ស $Ox$ |
| $\beta$ | $B$ | បេតា (Beta) | វង្វាស់មុំ, មេគុណស្កាលែ, មុំប្រាប់ទិសអ័ក្ស $Oy$ |
| $\gamma$ | $\Gamma$ | ហ្គាម៉ា (Gamma) | វង្វាស់មុំ, មុំប្រាប់ទិសអ័ក្ស $Oz$ |
| $\delta$ | $\Delta$ | ដេលតា (Delta) | បន្ទាត់ ($\Delta$), ឌីសគ្រីមីណង់ $\Delta = b^2 - 4ac$ |
| $\theta$ | $\Theta$ | ថេតា (Theta) | មុំរវាងពីរវ៉ិចទ័រ, មុំរវាងពីរប្លង់ |
| $\lambda$ | $\Lambda$ | ឡាំដា (Lambda) | ប៉ារ៉ាម៉ែត្រក្នុងសមីការបន្ទាត់ |
| $\mu$ | $M$ | មី (Mu) | ប៉ារ៉ាម៉ែត្រទីពីរនៃបន្ទាត់ |
| $\pi$ | $\Pi$ | ពី (Pi) | ចំនួនថេរ $\pi \approx 3.14159$, ឈ្មោះប្លង់ ($\Pi$) |
| $\rho$ | $P$ | រ៉ូ (Rho) | កាំប្លែ, ចម្ងាយពីគល់តម្រុយ |
| $\sigma$ | $\Sigma$ | ស៊ិកម៉ា (Sigma) | ផលបូក ($\sum$), ឈ្មោះប្លង់ ($\Sigma$) |
| $\phi$ | $\Phi$ | ហ្វី (Phi) | មុំក្នុងកូអរដោនេស្វ៊ែរ ឬកូអរដោនេប៉ូលែ |
| $\omega$ | $\Omega$ | អូមេហ្គា (Omega) | ផ្ចិតស្វ៊ែរ ($\Omega$), លំហាត់រ |

## ២. តារាងនិមិត្តសញ្ញាគណិតវិទ្យាក្នុងធរណីមាត្រលំហ

| និមិត្តសញ្ញា | ការអាន | អត្ថន័យក្នុងធរណីមាត្រលំហ |
|---|---|---|
| $\vec{u}, \overrightarrow{AB}$ | វ៉ិចទ័រ $u$, វ៉ិចទ័រ $AB$ | វ៉ិចទ័រក្នុងលំហ |
| $\lVert\vec{u}\rVert$ | ម៉ូឌុលនៃ $\vec{u}$ | ប្រវែងនៃវ៉ិចទ័រ $\vec{u}$ (ចំនួនពិតវិជ្ជមាន) |
| $\vec{u}\cdot\vec{v}$ | $\vec{u}$ ស្កាលែ $\vec{v}$ | ផលគុណស្កាលែនៃពីរវ៉ិចទ័រ (ជាចំនួនពិត) |
| $\vec{u}\times\vec{v}$ | $\vec{u}$ វ៉ិចទ័រ $\vec{v}$ | ផលគុណនៃពីរវ៉ិចទ័រ (កែងនឹង $\vec{u}$ និង $\vec{v}$) |
| $(\vec{u}\times\vec{v})\cdot\vec{w}$ | ផលគុណចម្រុះ | ផលគុណចម្រុះនៃបីវ៉ិចទ័រ (ជាចំនួនពិត) |
| $\perp$ | កែងនឹង | បន្ទាត់កែងបន្ទាត់, បន្ទាត់កែងប្លង់, ប្លង់កែងប្លង់ |
| $\parallel$ | ស្របនឹង | ពីរបន្ទាត់ស្របគ្នា, ឬពីរប្លង់ស្របគ្នា |
| $d(M,(P))$ | ចម្ងាយពី $M$ ទៅ $(P)$ | ប្រវែងកាត់កែងខ្លីបំផុតពីចំណុច $M$ ទៅប្លង់ $(P)$ |
| $(S)$ | ស្វ៊ែរ $S$ | ផ្ទៃស្វ៊ែរក្នុងលំហ |
| $\in, \notin$ | ជាធាតុនៃ, មិនជាធាតុនៃ | ចំណុចស្ថិតនៅលើ ឬមិននៅលើបន្ទាត់/ប្លង់ |
| $\cap$ | ប្រសព្វ | ចំណុច ឬបន្ទាត់ប្រសព្វរវាងរូបធរណីមាត្រ |

# ឯកសារយោង


1. **ក្រសួងអប់រំ យុវជន និងកីឡា** (២០១០-២០២៥) ៖ សៀវភៅសិក្សាគោល គណិតវិទ្យា ថ្នាក់ទី១២ កម្រិតខ្ពស់, នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា, រាជធានីភ្នំពេញ។

2. **ក្រសួងអប់រំ យុវជន និងកីឡា** (២០១០-២០២៥) ៖ សៀវភៅសិក្សាគោល គណិតវិទ្យា ថ្នាក់ទី១២ កម្រិតមូលដ្ឋាន, នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា, រាជធានីភ្នំពេញ។

3. **ក្រសួងអប់រំ យុវជន និងកីឡា** ៖ សៀវភៅគ្រូ គណិតវិទ្យា ថ្នាក់ទី១២, នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា, រាជធានីភ្នំពេញ។

4. **នាយកដ្ឋានជានាគុណភាពអប់រំ** ៖ កម្រងវិញ្ញាសាប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) គណិតវិទ្យា (២០១៤-២០២៦), ក្រសួងអប់រំ យុវជន និងកីឡា។

5. **នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ** ៖ កម្រងវិញ្ញាសាប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកគណិតវិទ្យា ថ្នាក់ទី១២, រាជធានីភ្នំពេញ។

6. **Stewart, James, Clegg, Daniel, & Watson, Saleem** (2020) ៖ *Calculus: Early Transcendentals* (9th Edition - Vectors and the Geometry of Space), Cengage Learning, Boston, USA.

7. **Thomas, George B., Weir, Maurice D., & Hass, Joel** (2018) ៖ *Thomas' Calculus* (14th Edition - Vectors and Analytic Geometry in Space), Pearson, Boston, USA.

8. **Larson, Ron, & Edwards, Bruce H.** (2022) ៖ *Calculus* (12th Edition - Vectors and Surfaces in Space), Cengage Learning, Boston, USA.

9. **Spiegel, Murray R., Lipschutz, Seymour, & Spellman, Dennis** (2009) ៖ *Schaum's Outline of Vector Analysis* (2nd Edition), McGraw-Hill Education, New York, USA.

10. **Anton, Howard, Bivens, Irl, & Davis, Stephen** (2021) ៖ *Calculus: Early Transcendentals* (12th Edition - Three-Dimensional Space and Vectors), John Wiley & Sons, Hoboken, New Jersey.